អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

# កម្រងខ្លឹមសារសង្ខេបនៃនីតិវិធីនិង សាលក្រម/សាលដីកាក្នុងសំណុំរឿង០០១ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា




(ឯកសារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី)

# កម្រងខ្លឹមសារសង្ខេបនៃនីតិវិធីនិងសាលក្រម/សាលដីកា
# ក្នុងសំណុំរឿង០០១ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

(ឯកសារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី)

# កម្រងខ្លឹមសារសង្ខេបនៃនីតិវិធីនិងសាលក្រម/សាលដីកា
# ក្នុងសំណុំរឿង០០១ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា


**ចងក្រងដោយ**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**អត្ថបទជាភាសាខ្មែរ**

ISBN: 978-9924-9747-8-9



**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

អគារលេខ៤០ មហាវិថីសហព័ន្ធរុស្សី សង្កាត់មិត្តភាព

ខណ្ឌ៧មករា រាជធានីភ្នំពេញ P.O. Box 71, Postal Code 120306

ទូរស័ព្ទ: ០២៣ ៨៦១ ៥០០

ទូរសារ: ០២៣ ៨៦១ ៥៥៥

អ៊ីម៉ែល: pas@eccc.gov.kh

គេហទំព័រ: www.eccc.gov.kh


អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា




# មាតិកា

**១.** អារម្ភកថារបស់ឯកឧត្តមប្រធានរដ្ឋបាលស្ដីទី........................................................................៩

**២.** សេចក្ដីសង្ខេបអំពីដំណើរការនីតិវិធីសំណុំរឿង០០១ ប្រឆាំងនឹង
លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច..........................................................................................១០

**៣.** កម្រងរូបថតថ្នាក់ដឹកនាំ ចៅក្រម ភាគី និងមេធាវី.......................................................................១៨

**៤.** សេចក្ដីសង្ខេបនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង.......................................៣៧

**៥.** សេចក្ដីសង្ខេបនៃសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ....................................៦៤

**៦.** ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ ..................................................................៩៤

**៧.** ការចងក្រងនិងបោះពុម្ពផ្សាយសេចក្ដីថ្លែងសុំអភ័យទោស និងការទទួលស្គាល់
ការទទួលខុសត្រូវរបស់ ឌុច.....................................................................................១០០

**៨.** ការបញ្ជូន ឌុច ទៅអនុវត្តទោសនៅពន្ធនាគារខេត្តកណ្ដាល.........................................១២៦

**៩.** សេចក្ដីប្រកាសព័ត៌មានអំពីមរណភាពរបស់ ឌុច...................................................១៣១


សាលសវនាការ
Courtroom
Salle d'Audience




# ១. អារម្ភកថារបស់ ឯកឧត្តមប្រធានរដ្ឋបាលស្តីទី



អ៊ំ ពូ មីង និងបងប្អូនទាំងអស់ជាទីគោរពរាប់អាន!

នៅពេលដែលមានការលើកឡើងអំពីឧក្រិដ្ឋកម្ម ការបាត់បង់ និងការឈឺចាប់ ជាចាំបាច់ត្រូវតែមានការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃអំពើទាំងនោះ ដើម្បីផ្សះផ្សាដល់ការខូចខាតផ្នែករូបរាងកាយ ផ្នែកសម្ភារៈ និងផ្លូវចិត្តរបស់ពួកគេ ក្នុងគោលដៅដោះស្រាយបញ្ហាសង្គមនិងលុបបំបាត់និទណ្ឌភាព។ ក្នុងរយៈកាលដែលប្រទេសកម្ពុជាគ្រប់គ្រងដោយរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ខ្មែរក្រហមបានប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗគ្នាមកលើប្រជាពលរដ្ឋកម្ពុជានៅទូទាំងប្រទេស។ ដើម្បីទទួលបានជោគជ័យក្នុងការគ្រប់គ្រងនិងអនុវត្តការងារតាមគោលការណ៍របស់ខ្លួន ខ្មែរក្រហមបានបង្កើតឱ្យមានមន្ទីរសន្តិសុខនៅតាមតំបន់ផ្សេងៗគ្នា ដើម្បីបោសសម្អាតផ្ទៃក្នុងនិងកម្ទេចអ្នកដែលពួកគេយល់ថាជាខ្មាំងរបស់អង្គការ។ ក្នុងចំណោមមន្ទីរសន្តិសុខទាំងនោះ មន្ទីរសន្តិសុខស២១ឬគុកទួលស្លែងជាគុកមជ្ឈឹមរបស់ខ្មែរក្រហមត្រូវបានបង្កើតឡើងដើម្បីជាកន្លែងឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃ ដើម្បីបង្ខំឱ្យពួកគេសារភាពទោសកំហុស បើទោះបីជាពួកគេមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះក៏ដោយ។ បន្ទាប់ពីទទួលបានព័ត៌មានសព្វគ្រប់ពីការសួរចម្លើយដោយបង្ខំនោះ ពួកគេត្រូវបានគេយកទៅសម្លាប់យ៉ាងព្រៃផ្សៃបំផុត ក្រោយពេលបានបំពេញសំណុំឯកសារអំពីការសារភាពចប់សព្វគ្រប់។ មន្ទីរសន្តិសុខនេះ ដឹកនាំដោយលោក អ៊ិន លន ហៅ ណាត ចាប់ពីក្រោយថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ រហូតដល់ខែមីនា ឆ្នាំ១៩៧៦ បន្ទាប់មក កិច្ចការនេះ ត្រូវបានជំនួសដោយលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ហើយត្រូវបានធ្វើវិសោធនកម្មនិងប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។ នីតិវិធីដែលត្រូវអនុវត្តចំពោះមុខ អ.វ.ត.ក. គឺបទប្បញ្ញត្តិនីតិវិធីរបស់ព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែច្បាប់បង្កើត អ.វ.ត.ក. ក៏អនុញ្ញាតផងដែរឱ្យ អ.វ.ត.ក. អាចស្វែងរកការបកស្រាយក្នុងបទដ្ឋាននីតិវិធីបង្កើតឡើងក្នុងកម្រិតអន្តរជាតិ កាលណាបទប្បញ្ញត្តិនីតិវិធីរបស់កម្ពុជា មានភាពខ្វះចន្លោះ មិនច្បាស់លាស់ ឬមិនសមស្របសម្រាប់អនុវត្តក្នុងដំណើរការជំនុំជម្រះ។

ចៅក្រម ភាគី បុគ្គលិកគាំទ្រ ព្រមទាំងអង្គភាពនានានៃការិយាល័យរដ្ឋបាល សុទ្ធតែមានការចូលរួមជាលក្ខណៈចម្រុះ ប្រកបដោយបទពិសោធ និងចំណេះដឹង ដែលមានទាំងសមាសភាពខាងជាតិនិងអន្តរជាតិ។ ការចូលរួមទាំងនេះបានជំរុញឱ្យការជំនុំជម្រះក្តីប្រព្រឹត្តិទៅដោយភាពត្រឹមត្រូវ យុត្តិធម៌ និងជឿជាក់ដ៏ពិតប្រាកដសម្រាប់គ្រប់ភាគីទាំងអស់ រួមទាំងជនរងគ្រោះផងដែរ សំដៅឈានទៅធ្វើឱ្យមានភាពស្ងប់ស្ងៀមក្នុងសង្គមនិងចូលរួមចំណែកក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មនានាកុំឱ្យមានការកើតឡើងសារជាថ្មី។

**ឯកឧត្តម ក្រាញ់ តូនី**
**ប្រធានរដ្ឋបាលស្តីទី អ.វ.ត.ក.**




# ២. សេចក្ដីសង្ខេបអំពី ដំណើរការនីតិវិធី សំណុំរឿង០០១ ប្រឆាំងនឹង លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច

(ឯកសារជំនួយស្មារតីសម្រាប់
ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១)



# ២. សេចក្តីសង្ខេបអំពីដំណើរការនីតិវិធីសំណុំរឿង០០១ ប្រឆាំងនឹងលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច

## (ឯកសារជំនួយស្មារតីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១)

សំណុំរឿង០០១ ជាករណីដំបូងនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ដែលក្នុងនោះ លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរសន្តិសុខស២១ ក្នុងទីក្រុងភ្នំពេញ ជាជនជាប់ចោទតែមួយគត់។ បន្ទាប់ពីនោះ មានសំណុំរឿង០០២/០១ សំណុំរឿង០០២/០២ (នួន ជា ខៀវ សំផន អៀង សារី និងអៀង ធីរិទ្ធ) សំណុំរឿង០០៣ (មាស មុត) សំណុំរឿង០០៤ (យឹម ទិត) សំណុំរឿង០០៤/១ (អោ អាន) និងសំណុំរឿង០០៤/២ (អ៊ឹម ចែម)។

### ១. ប្រវត្តិរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច និងនីតិវិធីក្នុងដំណាក់កាលបុរេជំនុំជម្រះ

ឌុច កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ។ លោកបានរៀននៅអនុវិទ្យាល័យកំពង់ធំ វិទ្យាល័យសៀមរាប និងនៅវិទ្យាល័យស៊ីសុវត្ថិ(ភ្នំពេញ)។ លោកបានចូលរួមជាមួយខ្មែរក្រហមនៅខែតុលា ឆ្នាំ១៩៦៤។ នៅឆ្នាំ១៩៦៥ ឌុច ត្រូវបានតែងតាំងជាគ្រូគណិតវិទ្យានៅវិទ្យាល័យស្គន់ ខេត្តកំពង់ចាម ហើយបានបោះបង់ការងារនេះនៅឆ្នាំ១៩៦៧ ដើម្បីបម្រើការងារយ៉ាងសកម្មក្នុងចលនាខ្មែរក្រហម។

ឌុច ត្រូវបានចាប់ខ្លួននៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៦៨ ដោយនគរបាលរបស់សម្តេចសីហនុ និងត្រូវដោះលែងនៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧០ ដែលជាពេលគាត់ចាប់បន្តសកម្មភាពជាខ្មែរក្រហម។ នាខែកក្កដា ឆ្នាំ១៩៧១ ឌុច បានទទួលភារកិច្ចក្នុងការគ្រប់គ្រងមន្ទីរម១៣ រហូតដល់ខែមករា ឆ្នាំ១៩៧៥ ក្រោមបញ្ជារបស់ វន វ៉េត បន្ទាប់មក ក្រោមបញ្ជារបស់ សុន សេន។ នៅចុងឆ្នាំ១៩៧៥ ឌុច ត្រូវបានតែងតាំងជាអនុប្រធានមន្ទីរសន្តិសុខស២១ រីឯ ណាត ជាប្រធាន។ នៅពេល ណាត ត្រូវបានផ្លាស់ចេញទៅសេនាធិការនៅខែមីនា ឆ្នាំ១៩៧៦ ឌុច បានឡើងជាប្រធានមន្ទីរស២១ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

ឌុច បានប្រគល់ខ្លួនឱ្យអាជ្ញាធរនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩៩ និងត្រូវស្ថិតនៅមន្ទីរឃុំឃាំងតុលាការយោធា ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតត្រូវបានផ្ទេរមកមន្ទីរឃុំឃាំងបណ្តោះអាសន្នរបស់ អ.វ.ត.ក. នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា (D3) ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ បាន

ចោទប្រកាន់ ឌុច ក៏ដូចជាបុគ្គលដទៃទៀត មានលោក នួន ជា លោក ខៀវ សំផន លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ អំពីករណី៖

១. អំពើមនុស្សឃាត អំពើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងសាសនាព្រះពុទ្ធនិង សាសនាអ៊ីស្លាម

២. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើ ពុទ្ធសាសនិកជន ជនជាតិចាម និងជនជាតិ វៀតណាម

៣. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង

៤. ឧក្រិដ្ឋកម្មដែលមានចែងក្នុងអនុសញ្ញានៃទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត (D99) ត្រូវបានចេញនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ដែលចោទប្រកាន់ ឌុច ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ប៉ុន្តែដីកានេះត្រូវបានកែប្រែផ្នែកខ្លះដោយអង្គបុរេជំនុំជម្រះនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ (D9/3/41)។ ដូច្នេះ បទចោទលើ ឌុច ដែលប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង មានអំពើប្រព្រឹត្តក្នុងនាមជាមេកើយ ក្នុងរយៈពេល ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នៅព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម៖

១. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

២. ឧក្រិដ្ឋកម្មដែលមានចែងក្នុងអនុសញ្ញានៃទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និង

៣. អំពើទារុណកម្មនិងអំពើមនុស្សឃាតគិតទុកជាមុន ក្រោមក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦។

## ២. បទចោទនិងសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង

បទល្មើសទាំងនេះមានបញ្ចូលនៅក្នុងមាត្រា៣(ថ្មី) មាត្រា៥ មាត្រា៦ មាត្រា២៩(ថ្មី) មាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ និងច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

សវនាការក្នុងសំណុំរឿង០០១ របស់អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តទៅអស់រយៈពេល៧៧ថ្ងៃ នៅក្នុងនោះមានសវនាការបឋមនៅថ្ងៃទី១៧និង១៨ ខែកុម្ភៈ ឆ្នាំ២០០៩ សវនាការលើអង្គសេចក្តីចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ តទៅ និងសវនាការលើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងកំលុងពេលសវនាការនេះ មានការផ្តល់សក្ខីកម្មរបស់សាក្សីជំនាញ៩រូប សាក្សីអង្គហេតុ១៧រូប សាក្សីអត្តចរិត៧រូប និងដើមបណ្តឹងរដ្ឋប្បវេណី២២រូប។ ប្រធានបទសំខាន់ៗចំនួន៧ ត្រូវបានយកមកពិនិត្យនិងពិភាក្សា គឺ៖

- កិច្ចដំណើរការនីតិវិធីដែលទាក់ទងទៅនឹងបញ្ហាមន្ទីរម១៣
- ការបង្កើតមន្ទីរស២១ និងពន្ធនាគារតាខ្មៅ
- ការអនុវត្តគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅមន្ទីរស២១
- ជម្លោះប្រដាប់អាវុធ
- ដំណើរការនៃមន្ទីរស២១ រួមទាំងវាលពិឃាតជើងឯក
- ការបង្កើតនិងដំណើរការមន្ទីរស២៤ (ព្រៃស) និង
- បញ្ហាពាក់ព័ន្ធនឹងអង្គហេតុរបស់ជនជាប់ចោទ។

ឯកសារប្រហែល ១ ០០០ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងត្រូវបានដាក់ឱ្យពិនិត្យ។ មនុស្សជាង ៣១ ០០០ នាក់បានចូលរួមដំណើរការនីតិវិធីនៅតុលាការ។

## ៣. ខ្លឹមសារនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង

តាមរយៈសាលក្រមចុះនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ឌុច មានពិរុទ្ធភាពលើករណីប្រព្រឹត្តនៅទីក្រុងភ្នំពេញនិងលើទឹកដីកម្ពុជា ក្នុងកំលុងពេលចន្លោះចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ អំពី៖

- បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ: ការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយដែលរួមបញ្ចូលនូវបទល្មើសការសម្លាប់រង្គាល(រួមបញ្ចូលទាំងការធ្វើមនុស្សឃាត) ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណីផងដែរ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត និង

- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ចំពោះឧក្រិដ្ឋកម្មមួយចំនួន ដូចជា៖
  - ▶ ការធ្វើមនុស្សឃាតដោយចេតនា
  - ▶ ការធ្វើទារុណកម្មនិងការធ្វើបាបដោយអមនុស្សធម៌
  - ▶ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរឬឱ្យមានការឈឺចាប់លើរាងកាយ ឬសុខភាព
  - ▶ ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបាន ការកាត់ទោសដោយយុត្តិធម៌និងទៀតទាត់ និង
  - ▶ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

អង្គជំនុំជម្រះសាលាដំបូងបានកាត់ទោសឱ្យ ឌុច ជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំនិងបានបន្ថយទោសជាប់ពន្ធនាគារ៥ឆ្នាំ ចេញ គឺមកត្រឹមរយៈពេល៣០ឆ្នាំ ដែលជាការទូទាត់សងចំពោះការរំលោភសិទ្ធិក្នុងអំឡុងពេលឃុំខ្លួនខុសច្បាប់កន្លងមក ដោយតុលាការយោធាកម្ពុជា ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ។

ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩០រូប ដែលត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូង មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន៧៦រូប ត្រូវបានអង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ពិតជាបានទទួលរងគ្រោះដោយបទឧក្រិដ្ឋ ដែលឌុចត្រូវបានរកឃើញថា មានពិរុទ្ធភាព។

ទន្ទឹមនឹងនេះ អង្គជំនុំជម្រះសាលាដំបូង បានផ្តល់សំណងផ្លូវចិត្តនិងសមូហភាពតែមួយគត់ គឺការចងក្រងនិងផ្សព្វផ្សាយលើគេហទំព័ររបស់ អ.វ.ត.ក. នូវសេចក្តីថ្លែងសុំអភ័យទោសនិងការទទួលស្គាល់ការទទួលខុសត្រូវ ដែលធ្វើឡើងដោយ ឌុច ក្នុងកំលុងពេលសវនាការ។

## ៤. ការប្តឹងសាទុក្ខ

ទាំងបីភាគីបានដាក់ពាក្យបណ្តឹងសាទុក្ខ។ សហព្រះរាជអាជ្ញា និង ឌុច បានដាក់បណ្តឹងសាទុក្ខទៅកាន់អង្គជំនុំជម្រះតុលាការកំពូល។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីសំណងនិងពាក្យសុំតាំងខ្លួនជា

ដើមបណ្តឹងរដ្ឋប្បវេណីដែរ។

អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការផ្ទាល់មាត់ លើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០១ កាលពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១។

អង្គជំនុំជម្រះតុលាការកំពូល បានប្រកាសសាលដីកាលើបណ្តឹងសាទុក្ខនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២។

សរុបជារួមមានប្រជាជនចំនួន៣៦ ៤៩៣នាក់ បានចូលរួមសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងនិងសវនាការបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង០០១ ក្នុងកំលុងពេលសវនាការដែលមានរយៈពេលសរុប៨០ថ្ងៃ។

## ៥. ខ្លឹមសារនៃសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល

អង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ បានបញ្ជាក់និងកែប្រែផ្នែកខ្លះនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសម្រេចៈ

**ក.** ចំពោះវិសាលភាពលើបុគ្គលៈ អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលបណ្តឹងសាទុក្ខរបស់ កាំង ហ្គេកអ៊ាវ ដែលលើកឡើងថា រូបលោកមិនមែនស្ថិតនៅក្នុងដែនសមត្ថកិច្ចផ្ទាល់របស់ អ.វ.ត.ក. នោះទេ។ មូលហេតុនៃការច្រានចោល គឺលក្ខណៈវិនិច្ឆ័យសមត្ថកិច្ចលើបុគ្គលគឺជាគោលការណ៍ណែនាំនៃការចោទប្រកាន់និងការស៊ើបអង្កេតសម្រាប់សហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនមានយុត្តាធិការពិនិត្យថា តើជនជាប់ចោទ គឺជាមេដឹកនាំជាន់ខ្ពស់ឬជាជនមួយក្នុងចំណោមជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតឬយ៉ាងណានោះឡើយ។

**ខ.** ចំពោះពិរុទ្ធភាពៈ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចៈ

- តម្កល់ការដាក់ពិរុទ្ធភាពលើ ឌុច ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
- ដាក់ពិរុទ្ធបន្ថែមលើ ឌុច ចំពោះបទសម្លាប់រង្គាល (រួមបញ្ចូលទាំងអំពើមនុស្សឃាត) បទធ្វើឱ្យទៅជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំង បទធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត

- រក្សាការសម្រេចលើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩

**គ.** ចំពោះទោសៈ អង្គជំនុំជម្រះតុលាកំពូលសម្រេច កែប្រែការដាក់ទោសពន្ធនាគារពី ៣០ឆ្នាំ ដែលអង្គជំនុំជម្រះសាលាដំបូងបានចេញកាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០ ឱ្យទៅជាទោសដាក់ពន្ធនាគារអស់មួយជីវិត តាមសេចក្តីសម្រេចនៃសម្លេងភាគច្រើនរបស់ចៅក្រម ដោយតុលាការកំពូលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តខុសដោយមិនបានពិនិត្យគ្រប់គ្រាន់អំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់ កាំង ហ្គេកអ៊ាវ ក៏ដូចជាការឈឺចាប់របស់ជនរងគ្រោះ ព្រមទាំងក្រុមគ្រួសារដែលមិនត្រឹមតែជារឿងអតីតកាលទេ តែនៅតែបន្តរហូតអស់មួយជីវិត។ ឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ បានប្រព្រឹត្តគឺជាបញ្ហាប្រឈមមិនដែលជួបប្រទះពីមុនរបស់មនុស្សជាតិទាំងមូល ហើយដែលបង្កឱ្យមានការឈឺចាប់មិនអាចព្យាបាលជាសះស្បើយបាន។

**ឃ.** ចំពោះបណ្តឹងសាទុក្ខអំពីការបដិសេធភាពរងគ្រោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីនិងសំណង៖

អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១០នាក់បន្ថែមទៀត ក្នុងចំណោមអ្នកដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសាលក្រមនៃសំណុំរឿង០០១ ថាពិតជាបានទទួលរងគ្រោះ ដែលជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋដែលឌុច ត្រូវបានរកឃើញថាមានពិរុទ្ធភាព។

ចំពោះបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើសំណើសុំសំណងផ្លូវចិត្តនិងសមូហភាព អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចរក្សាខ្លឹមសារនៃសេចក្តីសម្រេចរបស់សាលាដំបូងដដែល លើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចងក្រង និងបោះពុម្ពផ្សាយនៅលើគេហទំព័រ អ.វ.ត.ក. នូវសេចក្តីថ្លែងសុំអភ័យទោសនិងការទទួលស្គាល់នូវការទទួលខុសត្រូវ ដែលបានធ្វើឡើងដោយ ឌុច ក្នុងពេលជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូងផង និងនៅអង្គជំនុំជម្រះតុលាការកំពូលផង។

## ៦. ការអនុវត្តទោស

ឌុចបានចាប់ផ្តើមអនុវត្តទោសនៅក្នុងពន្ធនាគារក្នុងមន្ទីរឃុំខ្លួនរបស់ អ.វ.ត.ក. នៅឆ្នាំ២០១២ ហើយត្រូវបានបញ្ជូនទៅអនុវត្តទោសរបស់ខ្លួនជាបន្តនៅពន្ធនាគារខេត្តកណ្តាលកាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ ដើម្បីអនុវត្តទោសដែលនៅសល់រហូតទទួលមរណភាពវេលាម៉ោង ០០ និង៥១ នាទី នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២០ នៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត រាជធានីភ្នំពេញ។


UNITED NATIONS



# ៣. កម្រងរូបថត ថ្នាក់ដឹកនាំ ចៅក្រម ភាគី និងមេធាវី

# ៣.១. កម្រងរូបថតថ្នាក់ដឹកនាំតំណាង រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ










# ៣.២. រូបថតចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល









# ៣.៣. រូបថតចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង












# ៣.៤. រូបថតចៅក្រមនៃអង្គបុរេជំនុំជម្រះ









# ៣.៥. រូបថតសហចៅក្រមស៊ើបអង្កេត









# ៣.៦. កម្រងរូបថតសហព្រះរាជអាជ្ញា













# ៣.៧. រូបថតមេធាវីការពារក្តីនិងឌុច


















# ៣.៨. កម្រងរូបថតមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណី











# ៣.៩. កម្រងរូបថតដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងសាធារណជន

## ៣.៩.១. កម្រងរូបថតដើមបណ្តឹងរដ្ឋប្បវេណី



**១. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ជុំ មី
**ថ្ងៃផ្តល់សក្ខីកម្ម៖**
៣០ មិថុនា ២០០៩



**២. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ប៊ូ ម៉េង
**ថ្ងៃផ្តល់សក្ខីកម្ម៖**
១ កក្កដា ២០០៩



**៣. ដើមបណ្តឹងរដ្ឋប្បវេណី៖**
លី ហ៊ *ហៅ* អ៊ារ ហ៊
**ថ្ងៃផ្តល់សក្ខីកម្ម៖**
៦ កក្កដា ២០០៩



**៤. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ឡាយ ចាន់
**ថ្ងៃផ្តល់សក្ខីកម្ម៖**
៧ កក្កដា ២០០៩



**៥. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ភោគ ខន
**ថ្ងៃផ្តល់សក្ខីកម្ម៖**
៨ កក្កដា ២០០៩



**៦. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ជិន ម៉េត
**ថ្ងៃផ្តល់សក្ខីកម្ម៖**
៨និង៩ កក្កដា ២០០៩



**៧. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ណាំ ម៉ុន
**ថ្ងៃផ្តល់សក្ខីកម្ម៖**
៩និង១៣ កក្កដា ២០០៩



**៨. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ម៉ាទីន លើហ្វ៊ីវ
(Martine LEFEUVRE)
**ថ្ងៃផ្តល់សក្ខីកម្ម៖**
១៧ សីហា ២០០៩



**៩. ដើមបណ្តឹងរដ្ឋប្បវេណី៖**
អ៊ុក នារី
**ថ្ងៃផ្តល់សក្ខីកម្ម៖**
១៧ សីហា ២០០៩



**១០. ដើមបណ្តឹងរដ្ឋប្បវេណី៖**
លោក រ៉ូបឺត ហាមីល
(Robert HAMILL)
**ថ្ងៃផ្តល់សក្ខីកម្ម៖**
១៧ សីហា ២០០៩



**១១. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ជូឡុង អង់តូនីញ៉ា
(TIOULONG Antonya)
**ថ្ងៃផ្តល់សក្ខីកម្ម៖**
១៨ សីហា ២០០៩



**១២. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ហាវ សោភា
**ថ្ងៃផ្តល់សក្ខីកម្ម៖**
១៨ សីហា ២០០៩



**១៣. ដើមបណ្តឹងរដ្ឋប្បវេណី៖**
សូ សុង
**ថ្ងៃផ្តល់សក្ខីកម្ម៖**
១៨ សីហា ២០០៩



**១៤. ដើមបណ្តឹងរដ្ឋប្បវេណី៖**
នេត ផល្លី
**ថ្ងៃផ្តល់សក្ខីកម្ម៖**
១៨ សីហា ២០០៩



**១៥. ដើមបណ្តឹងរដ្ឋប្បវេណី៖**
អ៊ឹម ស៊ុន្នី
**ថ្ងៃផ្តល់សក្ខីកម្ម៖**
១៩ សីហា ២០០៩



**១៦. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ភឹង ហ្គុត ស៊ុនថារី
(PHUNG Guth Sunthary)
**ថ្ងៃផ្តល់សក្ខីកម្ម៖**
១៩ សីហា ២០០៩



**១៧. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ស៊ាង វ៉ាន់ឌី
**ថ្ងៃផ្តល់សក្ខីកម្ម៖**
១៩ សីហា ២០០៩



**១៨. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ជុំ ស៊ីរ៉ាត់
**ថ្ងៃផ្តល់សក្ខីកម្ម៖**
២០ សីហា ២០០៩



**១៩. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ជុំ នៅ
**ថ្ងៃផ្តល់សក្ខីកម្ម៖**
២០និង២៤ សីហា ២០០៩



**២០. ដើមបណ្តឹងរដ្ឋប្បវេណី៖**
អ៊ូ សាវរិត
**ថ្ងៃផ្តល់សក្ខីកម្ម៖**
២០ សីហា ២០០៩



**២១. ដើមបណ្តឹងរដ្ឋប្បវេណី៖**
ឈិន ណារី
**ថ្ងៃផ្តល់សក្ខីកម្ម៖**
២៤ សីហា ២០០៩



**២២. ដើមបណ្តឹងរដ្ឋប្បវេណី៖**
តួច មុនិន្ទ
**ថ្ងៃផ្តល់សក្ខីកម្ម៖**
២៤ សីហា ២០០៩

## ៣.៩.២. កម្រងរូបថតសាក្សី



**១. សាក្សី៖**
លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ
(BIZOT François)



**២. សាក្សី៖**
លោកស្រី ប៊ូ ថុន



**៣. សាក្សី៖**
លោក ចាន់ ខន



**៤. សាក្សី៖**
លោក ចាន់ វឿន



**៥. សាក្សីជំនាញ៖**
លោក ណាយ៉ាន់ ចាន់ដា
(CHANDA Nayan)



**៦. សាក្សីជំនាញ៖**
លោកសាស្ត្រាចារ្យ
ដេវីដ ឆេនដល័រ
(CHANDLER David)



**៧. សាក្សី៖**
លោក ចៀម សឿ



**៨. សាក្សីជំនាញ៖**
លោកវេជ្ជៈបណ្ឌិត
ឈឹម សុធារ៉ា



**៩. សាក្សី៖**
លោក ឈួន ផល



**១០. សាក្សី៖**
លោក ឆូវ រិន



**១១. សាក្សីជំនាញ៖**
លោក ក្រេក អេតឆេសាន់
(ETCHESON Craig)



**១២. សាក្សីជំនាញ៖**
លោក រីឆាត ជេ. ហ្គោលស្តូន
(GOLDSTONE Richard)



**១៣.** **សាក្សី៖**
លោក ហ៊ឹម ហ៊ុយ



**១៤.** **សាក្សី៖**
លោក ហ៊ិន ស្មៀន



**១៥.** **សាក្សីជំនាញ៖**
លោក រ៉ាអ៊ូល ម៉ាកចេនណា
(JENNAR Raoul)



**១៦.** **សាក្សីជំនាញ៖**
វេជ្ជបណ្ឌិត កា ស៊ុនបូណាត



**១៧.** **សាក្សី៖**
លោក កូក ស្រស់



**១៨.** **សាក្សី៖**
លោក ឡាច មាន



**១៩.** **សាក្សី៖**
គ្រីស្តូហ្វឺ ឡាបែល
(LAPEL Christopher)



**២០.** **សាក្សី៖**
លោក ម៉ម ណៃ



**២១.** **សាក្សី៖**
លោក នង ចាន់ផល



**២២.** **សាក្សី៖**
ប៉េង ពាន់



**២៣.** **សាក្សី៖**
លោក ប្រាក់ ខន



**២៤.** **សាក្សី៖**
សេក ដន



**២៥.** សាក្សី៖
លោក សោម ម៉េត



**២៦.** សាក្សីជំនាញ៖
វេជ្ជបណ្ឌិត
ហ្វ្រង់ស័រ ស៊ីរ៉ូនី ហ្គៀលបូ
(Dr. SIRONI-GUILBARD Francoise)



**២៧.** សាក្សី៖
អ្នកស្រី សោ សាត



**២៨.** សាក្សីជំនាញ៖
លោក ស្ទីហ្វែន ហាស្សែល
(Stéphane HESSEL)



**២៩.** សាក្សី៖
លោក សួស ធី



**៣០.** សាក្សី៖
លោក ទេព សឹម



**៣១.** សាក្សី៖
លោក ទេព សុក្រ



**៣២.** សាក្សី៖
លោក អូច សន



**៣៣.** សាក្សី៖
លោក វ៉ាន់ ណាត




# ៣.១០. កម្រងរូបថតទទួលសាលក្រម

## ៣.១០.១. បញ្ចូលឈ្មោះជនរងគ្រោះនៅក្នុងសាលក្រមនិងផ្សព្វផ្សាយលើគេហទំព័រ អ.វ.ត.ក.







## ៣.១០.២. ការចងក្រងនិងបោះពុម្ពផ្សាយសេចក្តីថ្លែងសុំអភ័យទោសនិងការទទួលស្គាល់ ដែលធ្វើឡើងដោយ ឌុច (សំណង)








## ៣.១០.៣. កម្រងរូបថតសកម្មភាពផ្សព្វផ្សាយ



































# ៤. សេចក្តីសង្ខេប នៃសាលក្រមរបស់ អង្គជំនុំជម្រះ សាលាដំបូង






# ៤. សេចក្ដីសង្ខេបនៃសាលក្រម របស់អង្គជំនុំជម្រះសាលាដំបូង

## កិច្ចដំណើរការនីតិវិធី

### ប្រធានអង្គជំនុំ៖

សូមអង្គុយចុះ!

ថ្ងៃនេះថ្ងៃចន្ទទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រកាសបន្តកិច្ចដំណើរការសវនាការជាសាធារណៈ ប្រកាសសាលក្រមវិនិច្ឆ័យសេចក្ដី លើសំណុំរឿងក្ដីករណី០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ អ.វ.ត.ក\អ.ជ.ស.ដ ដែលមានជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ភេទប្រុស អាយុ៦៨ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។ ការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦មាន៖ បទមនុស្សឃាតទុកគិតជាមុនមានបញ្ញត្តិក្នុងមាត្រា៥០១ និង ៥០៦ និងបទទារុណកម្មមានបញ្ញត្តិក្នុងមាត្រា៥០០។ បទល្មើសដែល មានចែងនិងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣(ថ្មី) មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ នៅទីក្រុងភ្នំពេញនិងនៅលើទឹកដីនៃប្រទេសកម្ពុជា ដែលបានប្រព្រឹត្តនៅក្នុងរយៈកាលកម្ពុជា ប្រជាធិបតេយ្យក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

ក្រឡាបញ្ជីនៃសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមានអវត្តមានភាគីទាំងឡាយដែលត្រូវអញ្ជើញចូលរួមក្នុងសវនាការនេះ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន, ភាគីដែលត្រូវចូលរួម នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះ មានវត្តមានគ្រប់ចំនួន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ កាំង ហ្គេកអ៊ាវ ទៅកាន់ឈើរាងវង្ង់ក្រចកចេះដែលរៀប ចំទុកសម្រាប់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះ។

មុននឹងចូលដល់ការប្រកាសសាលក្រម អង្គជំនុំជម្រះសាលាដំបូងសូមជម្រាបដល់ភាគី និង សាធារណជនទាំងអស់បានជ្រាបថាអង្គជំនុំជម្រះនាពេលនេះ ប្រកាសនៅសេចក្តីសង្ខេបនៃសេចក្តីសាលក្រមតែប៉ុណ្ណោះ និងសូមជម្រាបផងដែរថា នៅក្នុងសេចក្តីសង្ខេបនេះអង្គជំនុំជម្រះ នឹងប្រើពាក្យ អ.វ.ត.ក ជាអក្សរកាត់ជំនួសឱ្យពាក្យថា «អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា»។ សេចក្តីសង្ខេប នៃសាលក្រម សំណុំរឿងលេខ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ អ.វ.ត.ក/អ.ជ.ស.ដ ករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។

## ក) សេចក្តីផ្តើម

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបផ្នែកសំអាងហេតុនៃសាលក្រម សំអាងហេតុពិស្តារនៃបទល្មើសមាននៅក្នុងសាលក្រម លាយលក្ខណ៍អក្សរ ដែលនឹងត្រូវផ្សព្វផ្សាយជាភាសាខ្មែរ ភាសាបារាំង និងភាសាអង់គ្លេស បន្ទាប់ពីសវនាការប្រកាសសាលក្រមនេះ។ ជាបឋម អង្គជំនុំជម្រះសូមសម្តែងនូវការដឹងគុណដល់មេធាវី អ្នកបកប្រែផ្ទាល់មាត់ អ្នកបកប្រែឯកសារ មន្ត្រីតុលាការ និងមន្ត្រីប្រតិចារឹក បុគ្គលិករដ្ឋបាលរបស់ អ.វ.ត.ក បុគ្គលិកផ្នែកសន្តិសុខ និងសោតទស្សន៍ បុគ្គលិកផ្ទាល់របស់អង្គជំនុំជម្រះ និងបុគ្គលទាំងអស់ដទៃទៀត ដែលបានចូលរួម ចំណែកធ្វើឱ្យដំណើរការជំនុំជម្រះក្តីនេះ ប្រព្រឹត្តទៅយ៉ាងរលូន និងប្រកបដោយប្រសិទ្ធភាព។

ដំណើរការជំនុំជម្រះក្តីបានចាប់ផ្តើមនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ និងបានបញ្ចប់នៅ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងអំឡុងសវនាការរយៈពេល៧២ថ្ងៃ អង្គជំនុំជម្រះបានស្តាប់ការផ្តល់សក្ខីកម្មរបស់សាក្សីចំនួន២៤នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន

២៣នាក់ និងអ្នកជំនាញចំនួន៩នាក់។ ឯកសារប្រហែល១.០០០ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដែលជាកម្មវត្ថុនៃការពិនិត្យ។ រយៈពេលនៃដំណើរការនីតិវិធី និងទំហំនៃសាលក្រម បានឆ្លុះបញ្ចាំងនូវការជំនុំជម្រះជាប្រវត្តិសាស្ត្រ ដែល ជាលើកដំបូងនៅចំពោះមុខ អ.វ.ត.ក ផង និងវិសាលភាពនៃការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាប់ចោទផង។

ជនជាប់ចោទ ត្រូវបានចោទប្រកាន់តាមទម្រង់ទាំងអស់នៃការទទួលខុសត្រូវ ដែលមានចែងនៅក្នុងមាត្រា២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក ចំពោះតួនាទីរបស់គាត់ក្នុងឧក្រិដ្ឋកម្មទាំងឡាយ ដែលគាត់បានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នៅមន្ទីរសន្តិសុខស-២១។ ជាពិសេស ជនជាប់ចោទត្រូវបានចោទប្រកាន់ថា បានបំពេញការងារជាអនុប្រធាននិងក្រោយមកជាប្រធានមន្ទីរស-២១ និងបានទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានបទល្មើសការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ គាត់ក៏ត្រូវបានចោទប្រកាន់ផងដែរ ចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដែលមានបទល្មើសការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ព្រមទាំងការធ្វើមនុស្សឃាតដោយគិតទុកជាមុន និងការធ្វើទារុណកម្ម ដែលជាការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

នៅក្នុងសេចក្ដីសម្រេចដាច់ដោយឡែករបស់ខ្លួនដែលជា «សេចក្ដីសម្រេចស្ដីអំពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្ដី» ដែលត្រូវចេញនៅថ្ងៃនេះដែរផងនោះ អង្គជំនុំជម្រះបង្ហាញថា អង្គជំនុំជម្រះមិនបានពិនិត្យអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះបទចោទនៃការធ្វើមនុស្សឃាតគិតទុកជាមុន និងការធ្វើទារុណកម្ម ដែលជាការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលអាចផ្ដន្ទាទោសបាននៅចំពោះមុខ អ.វ.ត.ក អនុលោមតាមមាត្រា៣(ថ្មី) នៃច្បាប់ អ.វ.ត.ក ទេ។ ដូចមានការលើកឡើងនៅក្នុងសេចក្ដីសម្រេច គឺចៅក្រមនៃអង្គជំនុំជម្រះបានមានមតិយោបល់ដាច់ដោយឡែកពីគ្នា អំពីបញ្ហាថាតើមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានផុតរលត់ឬមិនទាន់ផុតរលត់ចិរវេលានៃអាជ្ញាយុកាល នៅមុនពេលមានការស៊ើបអង្កេតរបស់ អ.វ.ត.ក ទៅលើជនជាប់ចោទដែរឬទេ។ ការមិនមានសំឡេងភាគច្រើននៃចៅក្រមបួនរូបយ៉ាងតិចគាំទ្រចំពោះបញ្ហា

នេះ បានបង្កើតជាឧបសគ្គក្នុងការបន្តការវិនិច្ឆ័យលើជនជាប់ចោទចំពោះបទឧក្រិដ្ឋជាតិនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក។

នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះ បានផ្តល់នូវសំអាងហេតុពិស្តារគាំទ្រដល់ការអនុវត្តយុត្តាធិការរបស់អង្គជំនុំជម្រះលើជនជាប់ចោទ។ អង្គជំនុំជម្រះយល់ស្របជាមួយនឹងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតដែលថា កាំង ហ្គេកអ៊ាវ ហៅ ឌុច គឺជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលផ្សេងទៀតដែលត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

ច្បាប់ដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក មិនដូចក្របខណ្ឌគតិយុត្តនៃតុលាការអន្តរជាតិដទៃទៀតឡើយ គឺមិនបានចែងអំពីនីតិវិធីសម្រាប់ទទួលយក និងការកត់ត្រាការទទួលស្គាល់ពិរុទ្ធភាពដែលធ្វើឡើងដោយជនជាប់ចោទឡើយ។ ដូច្នេះ ជាទូទៅទោះបីជាជនជាប់ចោទបានយល់ព្រមឬមិនបានជំទាស់ទៅនឹងអង្គហេតុភាគច្រើន ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានធ្វើការកែប្រែក៏ដោយ ក៏អង្គជំនុំជម្រះត្រូវតែស្តាប់ចម្លើយ និងវាយតម្លៃរាល់ភស្តុតាងទាំងអស់ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ រួមទាំងបញ្ហាដែលមិនមានការជំទាស់តវ៉ាផងដែរ។

## ខ) បរិបទប្រវត្តិសាស្រ្តនិងនយោបាយ

ជាបឋម អង្គជំនុំជម្រះបានពិនិត្យលើបរិបទ ដែលរបបកម្ពុជាប្រជាធិបតេយ្យបានឡើងកាន់អំណាច។ អង្គជំនុំជម្រះបានយល់ឃើញថា ការប៉ះទង្គិចគ្នានៅតាមព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម បានកើតឡើងភ្លាមបន្ទាប់ពីទីក្រុងភ្នំពេញធ្លាក់ចូលក្នុងកណ្តាប់ដៃកងទ័ពបក្សកុម្មុយនីស្តកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅស្ទើរតែគ្រប់ពេលទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យ កងទ័ពកម្ពុជា និងកងទ័ពវៀតណាមបង្កអរិភាពហិង្សាកាន់តែធ្ងន់ធ្ងរឡើងៗ ដែលទីបំផុតនាំឱ្យមានការដួលរលំទីក្រុងភ្នំពេញនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ហើយនាំឱ្យមេដឹកនាំកម្ពុជាប្រជាធិបតេយ្យរត់ភៀសខ្លួនចេញពីទីក្រុងភ្នំពេញ។

អង្គជំនុំជម្រះក៏បានពិនិត្យរចនាសម្ព័ន្ធទូទៅនិងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងពេលដែលពាក់ព័ន្ធ ជាពិសេសរចនាសម្ព័ន្ធនិងគោលនយោបាយដែលបានអនុវត្តសម្រាប់ប្រតិបត្តិការមន្ទីរស-២១។ បក្សកុម្មុយនីស្តកម្ពុជាបានជួបប្រជុំនៅឯសមាជក្នុងខែមករា ឆ្នាំ១៩៧៦ ដើម្បី រៀបចំនូវរចនាសម្ព័ន្ធដ៏ស្មុគស្មាញមួយតាមលក្ខន្តិកៈ

បក្ស ដែលគ្រប់គ្រងដោយគណៈកម្មាធិការមជ្ឈិម ដែលដាក់បរិធានរដ្ឋាភិបាលទាំងមូល និងកងកម្លាំងប្រដាប់អាវុធឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យទាំងស្រុងរបស់បក្សកុម្មុយនីស្ត កម្ពុជា។ តាមការអនុវត្តជាក់ស្តែង អំណាចរបស់កម្ពុជាប្រជាធិបតេយ្យត្រូវអនុវត្តដោយ គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាស្ថាប័នប្រតិបត្តិរបស់គណៈកម្មាធិការមជ្ឈិម ដែល សមាជិកភាពរបស់គណៈកម្មាធិការមជ្ឈិមនេះរួមមាន ប៉ុល ពត ជាលេខា និងជា នាយករដ្ឋមន្ត្រី និងសមាជិកជាន់ខ្ពស់មួយចំនួនទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ដែល ត្រូវបានជ្រើសតាំង។ ស្ថាប័នទាំងអស់ រួមទាំងស្ថាប័នយោធា តម្រូវឱ្យរាយការណ៍ទៅ គណៈកម្មាធិការមជ្ឈិម តាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍។ លើសពីនេះទៀត ប្រជាជន ស៊ីវិលទាំងអស់ ត្រូវបានគ្រប់គ្រងដោយបណ្តាញអង្គភាពដែលត្រួតពិនិត្យយ៉ាងហ្មត់ចត់ ដោយគណៈកម្មាធិការមជ្ឈិម តាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍។ គោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានផ្សព្វផ្សាយទូទាំងកម្ពុជាប្រជាធិបតេយ្យ តាមរយៈ មធ្យោបាយនានា រួមមាន សេចក្តីណែនាំ ការប្រជុំមហាជន ការបណ្តុះបណ្តាល ការផ្សាយ តាមវិទ្យុ តាមទស្សនាវដ្តីនានា។ ផ្នែកដ៏សំខាន់បំផុតនៃគោលនយោបាយរបស់បក្ស កុម្មុយនីស្តកម្ពុជាទាក់ទងនឹងការជំនុំជម្រះក្តីនេះគឺ «ការកម្ទេច» ជាពាក្យដែលត្រូវបានគេ ប្រើប្រាស់ដើម្បីពិពណ៌នាអំពីការចាប់ខ្លួន ការសួរចម្លើយ និងការសម្លាប់បុគ្គលដែលត្រូវ បានគេយល់ថាជាខ្មាំងឬជាគិញ។

អង្គជំនុំជម្រះបានពិនិត្យបទចោទប្រឆាំងនឹង កាំង ហ្គេកអ៊ាវ តាមរយៈការឆ្លុះបញ្ចាំងអំពី ស្ថានភាពនយោបាយ និងប្រវត្តិសាស្ត្រទាំងនេះ។

## គ) មន្ទីរស-២១ និងតួនាទីរបស់ជនជាប់ចោទ

ជនជាប់ចោទកើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ។ បន្ទាប់ពីគាត់បានបញ្ចប់ការសិក្សា គាត់ត្រូវបានតែងតាំងជា គ្រូបង្រៀនគណិតវិទ្យានៅអនុវិទ្យាល័យស្គន់ ខេត្តកំពង់ចាម ក្នុងឆ្នាំ១៩៦៥ មុនពេល គាត់ចូលរួមក្នុងចលនាតស៊ូក្នុងឆ្នាំ១៩៦៧។ នៅឆ្នាំ១៩៧១ ជនជាប់ចោទត្រូវបាន ប្រគល់ភារកិច្ចឱ្យដឹកនាំមន្ទីរសន្តិសុខម-១៣ របស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់បាន យកវិធីសាស្ត្រ និងគោលនយោបាយដែលគាត់បានប្រើនៅមន្ទីរម-១៣ ទៅប្រើប្រាស់ នៅមន្ទីរស-២១ ដែលរួមបញ្ចូលទាំងការធ្វើទារុណកម្មនៅក្នុងអំឡុងពេលសួរចម្លើយ ការ ជ្រើសរើស បុគ្គលិក និងការបំពាក់បំប៉នមនោគមវិជ្ជាដល់ក្មេងជំទង់ៗ ដែលជាបុគ្គលិក និងការសម្លាប់អ្នកជាប់ឃុំជាប្រព័ន្ធ ក្រោយពីការសួរចម្លើយអ្នកជាប់ឃុំទាំងនោះបានចប់ សព្វគ្រប់។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានធ្វើការកែប្រែបានចែងថា ជនជាប់ចោទបាន

បំពេញការងារជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស-២១ ដែលជាមន្ទីរសន្តិសុខ មានភារកិច្ចក្នុងការសួរចម្លើយនិងសម្លាប់បុគ្គល ដែលបក្សកុម្មុយនីស្តកម្ពុជាយល់ថាជាខ្មាំងរបស់កម្ពុជាប្រជាធិបតេយ្យ ហើយជនជាប់ចោទក៏បានទទួលស្គាល់ដែរ។ មន្ទីរស-២១ បានដំណើរការពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

បន្ទាប់ពីជួបប្រជុំដំបូងជាមួយ សុន សេន ជនជាប់ចោទក្នុងឋានៈជាអនុប្រធានមន្ទីរស-២១ និង អ៊ិន លន ហៅ ណាត ជាប្រធាន បានបង្កើតនិងចាប់ផ្តើមគ្រប់គ្រងអង្គភាពសួរចម្លើយមន្ទីរស-២១ ក្នុងខែតុលា ឆ្នាំ១៩៧៥។ ក្នុងឋានៈជាប្រធានអង្គភាពសួរចម្លើយ ជនជាប់ចោទមានតួនាទីសំខាន់ចំនួនបួនៈ (i) ចងក្រងឯកសារដែលប្រមូលបានពីស្ថាប័នរបស់រដ្ឋាភិបាល លន់ នល់, (ii) រៀបចំរបាយការណ៍ឱ្យថ្នាក់លើរបស់គាត់ដោយផ្អែកតាមឯកសារទាំងនោះ, (iii) បង្រៀនវិធីសាស្ត្រនៃការសួរចម្លើយដល់បុគ្គលិកនៃអង្គភាពសួរចម្លើយ និង (iv) រាយការណ៍អំពីចម្លើយសារភាពរបស់អ្នកជាប់ឃុំទៅថ្នាក់លើរបស់គាត់។ ជនជាប់ចោទបានទទួលស្គាល់ថា ក្នុងឋានៈជាអនុប្រធាន គាត់បានអនុញ្ញាតឱ្យអ្នកសួរចម្លើយនៅមន្ទីរស-២១ ធ្វើទារុណកម្ម។ ជនជាប់ចោទក៏បានដឹងផងដែរថា បន្ទាប់ពីការសួរចម្លើយបានចប់សព្វគ្រប់ អ្នកជាប់ឃុំត្រូវបានគេយកទៅសម្លាប់ចោល។

ក្នុងខែមីនា ឆ្នាំ១៩៧៦ ជនជាប់ចោទបានធ្វើជាប្រធានមន្ទីរស-២១ ជំនួស អ៊ិន លន ហៅ ណាត។ ក្នុងតួនាទីជាប្រធាន ជនជាប់ចោទបានរាយការណ៍ជូន សុន សេន ចាប់ពីខែមីនា ឆ្នាំ១៩៧៦ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៧ និងក្រោយមកទៀតរាយការណ៍ជូន នួន ជា ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។ ស្របពេលជាមួយនឹងការតែងតាំងគាត់ជាប្រធានមន្ទីរស-២១ ជនជាប់ចោទក៏មានតួនាទីជាលេខាគណៈកម្មាធិការមន្ទីរស-២១ ផងដែរ។ ក្នុងនាមជាប្រធាន និងជាលេខា ជនជាប់ចោទមានអំណាចពេញលេញលើបុគ្គលិកមន្ទីរស-២១ ទាំងអស់ ដែលរួមទាំងសមាជិកពីររូបផ្សេងទៀតរបស់គណៈកម្មាធិការមន្ទីរស-២១ គឺ ឃឹម វ៉ាក ហៅ ហ៊ា និង នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ។ តួនាទីរបស់ជនជាប់ចោទក្នុងនាមជាប្រធានមន្ទីរស-២១ ដែលមិនត្រូវបានគេជំទាស់ ត្រូវបានបញ្ជាក់ដោយចម្លើយសារភាពរបស់ជនជាប់ចោទខ្លួនឯង សក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីព្រម ទាំងឯកសារផ្សេងៗដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី។

នៅខែមេសា ឆ្នាំ១៩៧៦ តាមសេចក្តីសម្រេចរបស់ជនជាប់ចោទ អ្នកជាប់ឃុំនៅមន្ទីរស-២១ ត្រូវបានគេយកទៅឃុំឃាំងនៅក្នុងបរិវេណវិទ្យាល័យពញាយ៉ាត ដែលជាវិទ្យាល័យមួយស្ថិតនៅក្នុងទីក្រុងភ្នំពេញ។ មន្ទីរស-២១ បានដំណើរការនៅលើទីតាំងនេះ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលជាបរិវេណនៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងសព្វថ្ងៃនេះ។

អ្នកជាប់ឃុំនៅមន្ទីរស-២១ មានអតីតអ្នករដ្ឋការ និងទាហាននៃរបប លន់ នល់ យុទ្ធជនរបស់កងទ័ពបដិវត្តកម្ពុជា កម្មាភិបាលជាន់ខ្ពស់ និងជាន់ទាបនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជាជាច្រើន សមាជិកគ្រួសារ និងអ្នកដែលធ្លាប់មានទំនាក់ទំនងជាមួយអ្នកទាំងនោះ ដែលរួមមានស្ត្រី កុមារ ជនបរទេសមកពីប្រទេសនានា ជាពិសេស ទាហាន និងជនស៊ីវិលវៀតណាម ព្រមទាំងបុគ្គលិកមន្ទីរស-២១ និងសាច់ញាតិរបស់ពួកគេផងដែរ។ ទោះបីជាឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះបង្ហាញថា មានមនុស្សមិនតិចជាង ១២.២៧៣ នាក់ ត្រូវបានឃុំខ្លួននៅមន្ទីរស-២១ ក្តី ក៏ចំនួនអ្នកជាប់ឃុំពិតប្រាកដទំនងជាមានច្រើនជាងចំនួនដែលមាននៅក្នុងបញ្ជីនេះទៅទៀត។

ជនជាប់ចោទបានរៀបចំមន្ទីរស-២១ តាមឋានានុក្រម និងបានបង្កើតប្រព័ន្ធនៃការរាយការណ៍គ្រប់ជាន់ថ្នាក់ ដើម្បីធានាថារាល់បទបញ្ជារបស់គាត់ពិតជាត្រូវបានអនុវត្តភ្លាមៗនិងជាក់លាក់។ មន្ទីរស-២១ ត្រូវបានបែងចែកជាអង្គភាពជាច្រើន រួមមានអង្គភាពឯកសារ អង្គភាពសួរចម្លើយ និងអង្គភាពការពារ ដែលអង្គភាពនីមួយៗប្រតិបត្តិការក្រោមការបញ្ជារបស់ជនជាប់ចោទ។ ក្រៅពីការគ្រប់គ្រងអង្គភាពនានា ដែលបានលើកឡើងខាងលើ ជនជាប់ចោទបានបំពេញភារកិច្ចពិសេសៗមួយចំនួនទៀត នៅក្នុងមន្ទីរស-២១។ ភារកិច្ចសំខាន់បំផុតក្នុងចំណោមភារកិច្ចទាំងនោះ មានដូចខាងក្រោមនេះ៖

**ការជ្រើសរើសបុគ្គលិក៖** ជនជាប់ចោទបានទទួលស្គាល់ថា បុគ្គលិកមន្ទីរស-២១ មួយចំនួន គឺជាអតីតអ្នកក្រោមបង្គាប់របស់គាត់នៅមន្ទីរម-១៣។ លើសពីនេះទៀត ក្នុងឋានៈជាប្រធានមន្ទីរស-២១ គាត់បានបន្តការអនុវត្តវិធីសាស្ត្រដែលបានអនុវត្តនៅមន្ទីរម-១៣ ក្នុងការជ្រើសរើសបុគ្គលិកជាក្មេងជំទង់ៗ ដែលងាយនឹងអប់រំឱ្យធ្វើជាអ្នកក្រោមបង្គាប់របស់គាត់។

**ការបណ្តុះបណ្តាលបុគ្គលិក៖** ការបង្រៀន ជាពិសេសការបណ្តុះបណ្តាលនយោបាយ គឺជាភារកិច្ចមួយដ៏ចម្បងបំផុតរបស់ កាំង ហ្កេកអ៊ាវ នៅមន្ទីរស-២១ ដែលគាត់បានកត់សម្គាល់ថា មានតែគាត់ម្នាក់ឯងប៉ុណ្ណោះដែលទទួលបន្ទុកអប់រំដល់បុគ្គលិកដែលធ្វើការនៅទីនោះ។ វគ្គបណ្តុះបណ្តាលបន្ថែម ជាប្រចាំនៅសាលាបណ្តុះបណ្តាល រួមបញ្ចូលនូវការបណ្តុះបណ្តាលអនុវត្តអំពីវិធីសាស្ត្រសួរចម្លើយ ដែលវគ្គបណ្តុះបណ្តាលនោះ បានកើនឡើងពីការបណ្តុះបណ្តាលប្រចាំឆ្នាំ ក្នុងឆ្នាំ១៩៧៧ ទៅជាការបណ្តុះបណ្តាលប្រចាំខែ និងប្រចាំសប្តាហ៍វិញក្នុងឆ្នាំ១៩៧៨។ ជនជាប់ចោទបានបណ្តុះបណ្តាលអ្នកសួរចម្លើយរបស់គាត់ឱ្យប្រើអំពើហិង្សាលើរាងកាយ និងផ្លូវចិត្ត ប៉ុន្តែបានបញ្ជាឱ្យអ្នកសួរចម្លើយទុកអ្នកជាប់ឃុំ

ឱ្យនៅរស់រហូតដល់គាត់យល់ថាចម្លើយសារភាពរបស់អ្នកជាប់ឃុំទាំងនោះបានចប់សព្វគ្រប់ហើយ។

**តួនាទីក្នុងការចាប់ខ្លួន៖** ជាទូទៅ ថ្នាក់លើរបស់ជនជាប់ចោទជាអ្នកសម្រេចថាតើត្រូវចាប់ខ្លួននិងបញ្ជូនអ្នកណាទៅមន្ទីរស-២១។ ប៉ុន្តែមានភស្តុតាងបញ្ជាក់ថាជនជាប់ចោទមានតួនាទីយ៉ាងសកម្មក្នុងការរៀបចំឱ្យមានការចាប់ខ្លួន និងមានភស្តុតាងបង្ហាញថាថ្នាក់លើរបស់ជនជាប់ចោទបានសុំយោបល់ ពីជនជាប់ចោទហើយជនជាប់ចោទបានធ្វើតាមបញ្ជាថ្នាក់លើរបស់គាត់។ លើសពីនេះទៀត ជនជាប់ចោទមានឥទ្ធិពលយ៉ាងខ្លាំងទាក់ទងទៅនឹងការចាប់ខ្លួនបុគ្គលិកមន្ទីរស-២១ និងមានវត្តមានក្នុងពេលចាប់ខ្លួនអ្នកជាប់ឃុំសំខាន់ៗមួយចំនួន។

**តួនាទីទាក់ទងនឹងចម្លើយសារភាព៖** ជនជាប់ចោទបានពិនិត្យចម្លើយសារភាពរបស់អ្នកជាប់ឃុំ និងបញ្ជាជាប់ជាប្រចាំទៅអ្នកសួរចម្លើយ រួមទាំងការឱ្យធ្វើទារុណកម្ម រហូតទាល់តែគាត់គិតថា ចម្លើយសារភាពបានចប់សព្វគ្រប់អស់ហើយ។ ចម្លើយសារភាពមិនអាចចាត់ទុកថាពេញលេញនោះទេ ប្រសិនបើព័ត៌មានដែលទទួលបានមិនទាន់លម្អិតគ្រប់គ្រាន់ ឬមិនទាន់បានឆ្លើយដាក់ឈ្មោះ «ជនក្បត់» ផ្សេងទៀត។ បន្ទាប់ពីការពិនិត្យមើលរួចហើយ ជនជាប់ចោទជាមនុស្សតែម្នាក់គត់ ដែលទទួលខុសត្រូវចំពោះការបញ្ជូនចម្លើយសារភាពរបស់អ្នកជាប់ឃុំ និងបញ្ជីឈ្មោះអ្នក ដែលត្រូវបានគេឆ្លើយដាក់ទៅឱ្យថ្នាក់លើរបស់គាត់។ ជនជាប់ចោទបានដឹងថា ព័ត៌មានភាគច្រើននៅក្នុងចម្លើយសារភាព ដែលគាត់បានបញ្ជូនឱ្យថ្នាក់លើរបស់គាត់គឺជាព័ត៌មានប្រឌិត។ ទោះជាបែបនេះក្តី ចម្លើយសារភាពរបស់មន្ទីរស-២១ ត្រូវបានយកមកប្រើ ដើម្បីសម្រេចចាប់ខ្លួនអ្នក ដែលត្រូវបានឆ្លើយដាក់ថាជាខ្មាំង ហើយជាញឹកញាប់ ចម្លើយសារភាពទាំងនោះត្រូវបានគេប្រើប្រាស់ដើម្បីចាប់ខ្លួនអ្នកផ្សេងជាច្រើននាក់ទៀត ដោយសារតែមានការឆ្លើយដាក់ថាជាជនក្បត់។

**តួនាទីក្នុងការសម្លាប់៖** ពីដំបូង ជនជាប់ចោទបានអនុញ្ញាតឱ្យ ឃឹម វ៉ាក ហៅ ហ៊ោ ចាត់ចែងពេលវេលានៃការសម្លាប់អ្នកជាប់ឃុំ។ ប៉ុន្តែ ក្រោយពីមានឧប្បត្តិហេតុមួយដែលអ្នកជាប់ឃុំម្នាក់ត្រូវបានសម្លាប់ មុនពេលគាត់ផ្តល់ចម្លើយសារភាពចប់សព្វគ្រប់មក ជនជាប់ចោទបានតម្រូវថា គាត់ត្រូវតែបានដឹងថា ការសួរចម្លើយបានចប់សព្វគ្រប់មុននឹងយកអ្នកជាប់ឃុំទៅសម្លាប់ចោល។

លើសពីនេះទៀត ក្នុងឋានៈជាប្រធានមន្ទីរស-២១ ជនជាប់ចោទបានជ្រើសរើសផ្លាស់ទីកន្លែងសម្លាប់ និងទីកន្លែងកប់សាកសពរបស់មន្ទីរស-២១ ទៅដាក់នៅជើងឯក ដែល

ស្ថិតនៅចម្ងាយប្រហែល១៥គ.ម ភាគនិរតីនៃទីក្រុងភ្នំពេញ។ បន្ទាប់ពីបានចម្លើយសារភាពចប់សព្វគ្រប់ អ្នកជាប់ឃុំនៅក្នុងមន្ទីរស-២១ ជាធម្មតា ត្រូវបានដឹកយកទៅជើងឯក ដែលជាទីកន្លែងដែលអ្នកជាប់ឃុំទាំងនោះ ត្រូវបានគេសម្លាប់យ៉ាងទាន់ហន់ជាទីបំផុត។

ជនជាប់ចោទក៏បានអនុវត្តអំណាចទៅលើស-២៤ ដែលគេស្គាល់ថាជាព្រៃសផងដែរ។ ព្រៃសមានទីតាំងស្ថិតនៅក្រៅទីក្រុងភ្នំពេញ ហើយត្រូវបានប្រើប្រាស់ជាមណ្ឌលលត់ដំខ្លួន។ នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ធ្វើការតែនៅស-២៤ ជាអ្នកមើលប្រតិបត្តិការការងារប្រចាំថ្ងៃនៅទីនោះដោយផ្ទាល់។ បន្ទាប់ ពីការចាប់ខ្លួន ហ៊ុយ ស្រែ នៅខែធ្នូ ឆ្នាំ១៩៧៨ ផល ត្រូវបានតែងតាំងឱ្យទៅមើលការខុសត្រូវស-២៤ រហូតដល់ពេលមន្ទីរនេះត្រូវបានបោះបង់ចោលនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។ ក្នុងអំឡុងពេលនោះ ជនជាប់ចោទបានទទួលរបាយការណ៍ជាប្រចាំ ទាក់ទងនឹងប្រតិបត្តិការស-២៤។ អ្នកជាប់ឃុំនៅស-២៤ ភាគច្រើនជាសាច់ញាតិ ឬអ្នកនៅក្រោមបង្គាប់របស់អ្នកដែលត្រូវបានឃុំខ្លួននៅមន្ទីរស-២១ និងជាយុទ្ធជន និងបុគ្គលិកមកពីក្រសួង មន្ទីរ ឬស្ថាប័នសាធារណៈនានា។ ផ្អែកលើឯកសារផ្សេងៗពីគ្នា និងមានចំនួនតិចតួច ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះយល់ឃើញថា ចំនួនអ្នកជាប់ឃុំសរុបនៅស-២៤ មានមិនតិចជាង ១.៣០០ នាក់ឡើយ។

## ឃ) អង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅមន្ទីរស-២១

ក្នុងអំឡុងពេលនៃការជំនុំជម្រះក្តី ភស្តុតាងដូចខាងក្រោមនេះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅមន្ទីរស-២១។ អង្គហេតុផ្សេងៗទៀត ដែលពាក់ព័ន្ធជាពិសេសទៅនឹងឈ្លើយសឹក និងជនស៊ីវិលវៀតណាម ព្រមទាំងអ្នកគាំទ្រវៀតណាម ដែលត្រូវបានជាប់ឃុំនៅមន្ទីរស-២១ ក៏ត្រូវបានលើកឡើងផងដែរ ដោយអង្គជំនុំជម្រះ ដែលទាក់ទងទៅនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។

**ការធ្វើមនុស្សឃាត និង ការសម្លាប់រង្គាលៈ** ជនគ្រប់រូបដែលត្រូវបានឃុំខ្លួននៅមន្ទីរស-២១ (ទួលស្លែង) សុទ្ធតែរង់ចាំការសម្លាប់ទាំងអស់ អនុលោមទៅតាមគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាក្នុងការ «កម្ទេច» ខ្មាំង។ ក្នុងចំណោមអ្នកទាំងឡាយដែលត្រូវបានសម្លាប់ គឺជាអតីតអ្នកគាំទ្ររបប លន់ នល់ ជនបរទេស កុមារ អ្នកជាប់ឃុំដែលមានឋានៈខ្ពស់ និងអតីតបុគ្គលិកមន្ទីរស-២១។ ការសម្លាប់អ្នកជាប់ឃុំជាទ្រង់ទ្រាយធំ ត្រូវ

បានបញ្ជាដោយគណៈកម្មាធិការមជ្ឈិមបក្ស និងបានធ្វើឡើងជាច្រើនដង។ ក្រៅពីអ្នកទាំងឡាយដែលត្រូវបានសម្លាប់ អ្នកជាប់ឃុំជាច្រើនទៀតបានស្លាប់ដោយសារតែការធ្វើទារុណកម្ម និងស្ថានភាពនៃការឃុំខ្លួន។ លើសពីនេះទៀត យ៉ាងហោចណាស់ក៏មានអ្នកជាប់ឃុំនៅមន្ទីរស-២១ ចំនួន១០០នាក់ដែរ ដែលបានស្លាប់ បន្ទាប់ពីត្រូវបានគេបូមយកឈាមអស់ដោយអង្គភាពពេទ្យមន្ទីរស-២១។ ជនជាប់ចោទបានទទួលស្គាល់ថាអ្នកជាប់ឃុំដែលបានស្លាប់ ឬត្រូវបានសម្លាប់មានចំនួនច្រើនជាង ១២.២៧៣នាក់ ដែលមាននៅក្នុងបញ្ជីអ្នកទោសដែលត្រូវបានកែសម្រួល។

**ការធ្វើឱ្យទៅជាទាសករ៖** ជនជាប់ចោទក៏បានយល់ស្របថា ស-២៤ គឺជាកន្លែងដែលធ្វើឱ្យទៅជាទាសករ ដែលនៅទីនោះអ្នកជាប់ឃុំដែលត្រូវបានគេស្គាល់ថាជា «ពួកសមាសភាព» ត្រូវបានលត់ដំខាងការងារពលកម្ម។ សាក្សី ប៊ូ ថុន និង មាស ប៉េងគ្រី ព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណី ជិន ម៉េត បានពិពណ៌នាអំពីស្ថានភាពការងារធ្ងន់ធ្ងរ ដែលពួកគាត់ ត្រូវបានបង្ខំឱ្យប្រឈមក្នុងអំឡុងពេល ដែលពួកគាត់ត្រូវបានឃុំខ្លួននៅ ស-២៤។ លើសពីនេះទៀត អ្នកជាប់ឃុំមួយចំនួនតូចបំផុត ត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងមន្ទីរស-២១(ទួលស្លែង)។ អ្នកទាំងនោះ រួមមាន សាក្សី វ៉ាន់ ណាត និងដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង និង ជុំ ម៉ី។ ដំបូង អ្នកទាំងនោះត្រូវបានចាប់ខ្លួន ដាក់ខ្នោះ និងឃុំខ្លួននៅមន្ទីរស-២១ មុនពេលពួកគាត់ត្រូវបានជ្រើសរើសឱ្យធ្វើការនៅក្នុងមន្ទីរស-២១ (ទួលស្លែង)។

**ការដាក់ក្នុងមន្ទីរឃុំឃាំង៖** យ៉ាងហោចណាស់ក៏មានមនុស្សចំនួន ១២.២៧៣ នាក់ ដែលក្នុងនោះរួមមានទាំងបុរស ស្ត្រី និងកុមារ ត្រូវបានឃុំខ្លួននៅមន្ទីរស-២១។ បុគ្គលមួយចំនួន ដែលត្រូវបានគេកំណត់មុខសញ្ញាឱ្យនាំខ្លួនមកមន្ទីរស-២១ ត្រូវបានគេចាប់ខ្លួនជាសម្ងាត់ ចំណែកឯអ្នកផ្សេងទៀត ត្រូវបានគេដាក់ខ្នោះដៃ ចងមុខ បង្ខំឱ្យបំពេញបែបបទមួយចំនួន មុននឹងត្រូវបានគេយកទៅឃុំខ្លួននៅក្នុងបន្ទប់ឃុំឃាំងតូចៗ ឬបន្ទប់ឃុំឃាំងរួម ដែលជាកន្លែងអ្នកជាប់ឃុំទាំងនោះ ត្រូវបានគេដាក់ខ្នោះជើងជារនងបន្តជាប់ៗគ្នា។ ស-២៤ ក៏បានឃុំខ្លួនមនុស្សរាប់រយនាក់ ដែលរួមមានទាំងបុរស ស្ត្រី និងកុមារនៅក្នុងពេលតែមួយផងដែរ។ អ្នកជាប់ឃុំកម្រនឹងត្រូវបានគេដោះលែងណាស់។ មិនមានការជំនុំជម្រះក្តី ឬក៏យន្តការដទៃទៀត ក្នុងការជំទាស់តវ៉ាទៅនឹងការចាប់ខ្លួន ការឃុំខ្លួន ឬការសម្លាប់ឡើយ។ ជនជាប់ចោទយល់ស្របថា ការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់ដោយគ្មានការជំនុំជម្រះគឺជា «[...] វិសមិតភាពជាមួយនឹងអត្ថិភាពនៃតុលាការ និងការជានាផ្នែកនីតិវិធី»។

**ការធ្វើទារុណកម្មនិងការរំលោភលើផ្លូវភេទ៖** បច្ចេកទេសធ្វើទារុណកម្មជាច្រើនត្រូវបានអនុវត្តនៅក្នុងមន្ទីរស-២១ (ទួលស្លែង)។ ជនជាប់ចោទបានទទួលស្គាល់ថា អ្នកសួរ

ចម្លើយត្រូវបានអនុញ្ញាតឱ្យប្រើបច្ចេកទេសសួរចម្លើយ ដោយប្រើហិង្សាចំនួនបួនយ៉ាង គឺ ការវាយ ការឆក់ខ្សែភ្លើង ការប្រកក្បាលក្នុងថង់ប្លាស្ទិក និងការ«បន្តក់ទឹកចូលក្នុងច្រមុះ»។ ក្រៅពីវិធីសាស្ត្រដែលត្រូវបានអនុញ្ញាតទាំងនេះ ជនជាប់ចោទបានទទួលស្គាល់ថា បច្ចេកទេសបន្ថែមទៀតត្រូវបានអនុវត្តដោយអ្នកសួរចម្លើយ រួមមាន មួយករណីដែលបុគ្គលិកមន្ទីរស-២១ បានយកឈើរុកចូលទៅក្នុងប្រដាប់ភេទអ្នកជាប់ឃុំស្ត្រីម្នាក់ក្នុងអំឡុងពេលសួរចម្លើយ។ ការប្រើប្រាស់បច្ចេកទេសនានាក្នុងការសួរចម្លើយ គឺធ្វើឡើងដើម្បីទទួលបានចម្លើយសារភាព ដែលមានរៀបរាប់លម្អិតអំពីជីវប្រវត្តិរបស់អ្នកជាប់ឃុំ ចរិតលក្ខណៈនៃបទឧក្រិដ្ឋ និងសកម្មភាព «ក្បត់» ផ្សេងៗទៀត ដែលជាប់ពាក់ព័ន្ធដោយផ្ទាល់រវាងអ្នកជាប់ឃុំក្នុងអំពើនោះ និងបណ្តាញ «ជនក្បត់» ដទៃទៀត។

អង្គជំនុំជម្រះបានស្តាប់ការផ្តល់សក្ខីកម្មរបស់អតីតអ្នកជាប់ឃុំម្នាក់នៅមន្ទីរស-២១ ដែលបានទទួលរងនូវដំណើរការនៃការសួរចម្លើយរបៀបនេះ។ ដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានគេធ្វើទារុណកម្មពីរដងក្នុងមួយថ្ងៃ ចំនួនពីរសប្តាហ៍ជាប់គ្នា។ គេបានដាក់ខ្នោះជើងគាត់ និងបានបង្ខំគាត់ឱ្យដេកផ្កាប់មុខទៅលើឥដ្ឋ ហើយគេប្រើសម្តីអសុរោះមកលើគាត់។ អ្នកសួរចម្លើយបង្ហាញគាត់នូវឧបករណ៍ធ្វើទារុណកម្ម និងបានប្រាប់គាត់ ឱ្យជ្រើសរើសនូវឧបករណ៍ណាមួយដែលនឹងត្រូវយកមកប្រើសម្រាប់ធ្វើទារុណកម្មលើរូបគាត់។ អ្នកសួរចម្លើយបានប្តូរវេនគ្នាវាយខ្នងគាត់នឹងខ្សែតីរំពាត់ផ្តៅ ដែលបណ្តាលឱ្យមានឈាមហូរពាសពេញលើឥដ្ឋ។ អ្នកសួរចម្លើយក៏បានប្រើខ្សែភ្លើងឆក់ គាត់រហូតដល់សន្លប់ផងដែរ។ ដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង នៅមានសម្លាកដោយសារតែការវាយទាំងនោះ។ គ្រប់ពេលដែលគេវាយគាត់ គេបានសួរសំណួរគាត់ទាក់ទងនឹងការពាក់ព័ន្ធរបស់គាត់ជាមួយ សេអ៊ីអា (CIA) និង កាហ្សេបេ (KGB)។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ដែលជាអតីតអ្នកជាប់ឃុំនៅមន្ទីរស-២១ ម្នាក់ទៀតដែរនោះ បាននិយាយថា គេបានសួរចម្លើយគាត់អស់រយៈពេល១២ថ្ងៃ និង១២យប់។ នៅក្នុងអំឡុងពេលសួរចម្លើយ គេបានវាយគាត់នឹងរំពាត់ខ្សែតីជាច្រើនលើកច្រើនសា។ នៅពេលគាត់ព្យាយាមបដិសេធចំពោះការចោទប្រកាន់ថាគាត់មានការពាក់ព័ន្ធជាមួយ សេអ៊ីអា (CIA) ឬកាហ្សេបេ (KGB)នោះ អ្នកសួរចម្លើយម្នាក់បានដកក្រចកជើងគាត់ទាំងសងខាង ដែលបណ្តាលឱ្យគាត់ «ឈឺញ័រតតាក់»។ គាត់បានទទួលរងនូវការឆក់ខ្សែភ្លើងចំនួនពីរលើក ហើយគាត់បានដួលសន្លប់បន្ទាប់ពីការឆក់មួយលើកៗ។ ការសួរចម្លើយបានបញ្ឈប់ក្រោយពេលដែលគាត់ «បានសារភាព» ថា ពិតជាបានចូលរួមជាមួយ សេអ៊ីអា (CIA) និង កាហ្សេបេ (KGB) មែន។

ការធ្វើទារុណកម្មនៅស-២៤ ត្រូវបានគេយកមកប្រើ ដើម្បីដាក់ទណ្ឌកម្មដល់អ្នកជាប់ឃុំទប់ស្កាត់ពួកគេកុំឱ្យលួចរត់គេចខ្លួន និងនៅក្នុងអំឡុងពេលសួរចម្លើយដែលត្រូវបានគេអនុវត្តម្តងម្កាលនៅទីនោះ។

បុគ្គលិកមន្ទីរស-២១ និងបុគ្គលិកស-២៤ រួមទាំងអ្នកសួរចម្លើយ បានបំពេញតួនាទី តាមឋានានុក្រមដែលត្រូវបានរៀបចំឡើងយ៉ាងច្បាស់លាស់ ក្រោមបញ្ជា ឬអំណាច របស់ជនជាប់ចោទដែលជនជាប់ចោទខ្លួនឯងផ្ទាល់ បានបំពេញតួនាទីនេះ តាមបញ្ជា របស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ដោយពិចារណាអំពីតួនាទីរបស់បុគ្គលិកទាំងអស់នោះ នៅក្នុងបរិធានរដ្ឋាភិបាល អង្គជំនុំជម្រះសន្និដ្ឋានថា អ្នកសួរចម្លើយនៅមន្ទីរស-២១ និង បុគ្គលិកស-២៤ ដែលបានប្រព្រឹត្តអំពើទារុណកម្មទាំងឡាយ បានអនុវត្តសមត្ថកិច្ចផ្លូវការ របស់ខ្លួន ក្នុងស្ថានភាពភ័យខ្លាចជាប្រចាំ។

លើសពីនេះទៀត អ្នកជាប់ឃុំបានទទួលរងនូវការខ្វះម្ហូបអាហារ អនាម័យ និងការ ព្យាបាលផ្នែកវេជ្ជសាស្ត្រ។ គោលបំណងតែមួយគត់ក្នុងការផ្តល់នូវការព្យាបាលផ្នែក វេជ្ជសាស្ត្រ គឺដើម្បីទុកអ្នកជាប់ឃុំឱ្យនៅរស់សម្រាប់ការសួរចម្លើយពួកគេតែប៉ុណ្ណោះ។ ភស្តុតាងទាក់ទងនឹងការធ្វើបាបអ្នកជាប់ឃុំនៅជើងឯក និង ស-២៤ ត្រូវបានដាក់ នៅចំពោះមុខអង្គជំនុំជម្រះផងដែរ។

**ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖** ការធ្វើទុក្ខបុកម្នេញ ពិពណ៌នាអំពី ការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន ដែលប្រព្រឹត្តឡើងដោយផ្អែកលើមូលដ្ឋាននៃការ រើសអើង។ ក្នុងការអនុវត្តជាក់ស្តែង ការធ្វើទុក្ខបុកម្នេញគឺជាបទល្មើសដែលគ្របដណ្តប់ លើបទល្មើសជាក់លាក់មួយចំនួនផ្សេងទៀត ដែលតម្រូវឱ្យបង្ហាញនូវជាតុចេតនានៃ ការរើសអើង។ ការបដិសេធនូវសិទ្ធិជាមូលដ្ឋានដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះដែល ត្រូវបានធ្វើការកែប្រែបង្ហាញអំពីបទល្មើសការធ្វើទុក្ខបុកម្នេញ ដែលនៅក្នុងនោះ មាន បទល្មើស ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀត ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួម ទាំងការរំលោភលើផ្លូវភេទ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ អង្គជំនុំជម្រះបានបង្ហាញ អំពីប្រភេទនៃបទល្មើសនានាដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ហើយអង្គជំនុំជម្រះនឹង បង្ហាញលម្អិតនូវសំអាងហេតុនៃបទល្មើសនោះថា តើបទល្មើសទាំងនោះបង្កើតបានជា បទល្មើសនៃការធ្វើទុក្ខបុកម្នេញដែរឬទេ នៅក្នុងសេចក្តីសង្ខេបខាងក្រោមនេះ។

## ង) ច្បាប់ជាធរមាននិងសំអាងហេតុទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ ជាបុគ្គលរបស់ជនជាប់ចោទ

ដូចដែលបានរៀបរាប់យ៉ាងពិស្តារនៅក្នុងសាលក្រម អង្គជំនុំជម្រះបានយល់ឃើញថា បទល្មើសទាំងឡាយដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ អនុលោមតាម មាត្រា៥ និងមាត្រា៦ នៃច្បាប់ អ.វ.ត.ក ព្រមទាំងទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវ

បានចោទប្រកាន់ អនុលោមតាមមាត្រា២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. ត្រូវបានទទួលស្គាល់ថា ជាបទល្មើសនៅក្នុងច្បាប់អន្តរជាតិ នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត។

អង្គជំនុំជម្រះ យល់ឃើញទៀតថា បុរេលក្ខខណ្ឌចាំបាច់ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ពោលគឺអត្ថិភាពនៃការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ សំដៅប្រឆាំងនឹងជនស៊ីវិល ដោយសារតែមូលហេតុសញ្ជាតិ នយោបាយ ជាតិពន្ធ ពូជសាសន៍ ឬសាសនា) បានកើតមាន តាមពេលដែលពាក់ព័ន្ធ។ តាមការយល់ឃើញអំពីសំអាងហេតុនៃបទល្មើសទាក់ទងនឹងមន្ទីរស-២១ អង្គជំនុំជម្រះយល់ឃើញថា បទល្មើសដែលត្រូវបានចោទប្រកាន់តាមមាត្រា៥ នៃច្បាប់អ.វ.ត.កដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែពិតជាមានប្រាកដមែន។ អង្គជំនុំជម្រះ ដោយមតិភាគច្រើន យល់ឃើញ ផងដែរថា បទល្មើសទាំងនេះ ត្រូវបានចោទប្រកាន់ត្រួតគ្នានៅក្នុងបទល្មើសការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលដ្ឋានថា ជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ដោយមានចេតនារើសអើងជាក់លាក់ ខាងមូលហេតុនយោបាយ។

អង្គជំនុំជម្រះ ក៏បានយល់ឃើញផងដែរថា ជម្លោះប្រដាប់អាវុធអន្តរជាតិដែលបានកើតឡើងរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម នៅគ្រប់ពេលទាំងអស់នោះ ពិតជាពាក់ព័ន្ធទៅនឹងការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។ អង្គជំនុំជម្រះ បានជឿថា បុរេលក្ខខណ្ឌចាំបាច់សម្រាប់ការកំណត់ពិរុទ្ធភាព អនុលោមតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក ដែលទាក់ទងទៅនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ត្រូវបានបំពេញ។ អង្គជំនុំជម្រះបានយល់ឃើញថា ឈ្លើយសឹកនិងជនស៊ីវិលវៀតណាម ព្រមទាំងអ្នកគាំទ្រវៀតណាម ដែលត្រូវបានឃុំខ្លួននៅមន្ទីរស-២១ បានស្ថិតនៅក្រោមស្ថានភាពនៃការឃុំខ្លួន ដូចគ្នាទៅនឹងអ្នកជាប់ឃុំដទៃទៀតដែរ និងត្រូវបានកំណត់សម្លាប់ចោលដោយចៀសមិនផុត ដោយមិនមានលក្ខខណ្ឌអនុគ្រោះចំពោះឈ្លើយសឹក និងជនស៊ីវិលទាំងនោះ ដោយសារសញ្ជាតិពួកគាត់ឬឋានៈដែលត្រូវទទួលបានការការពារនោះឡើយ។ តាមការយល់ឃើញលើសំអាងហេតុមុនៗ របស់អង្គជំនុំជម្រះ ទាក់ទងនឹងមន្ទីរស-២១ អង្គជំនុំជម្រះយល់ឃើញថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលមានបទល្មើស ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ដែលអាចផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក ពិតជាមានប្រាកដមែន។

នៅមានបញ្ហាមួយចំនួនទៀត អំពីថាតើមានភស្តុតាងដើម្បីបញ្ជាក់ថា ជនជាប់ចោទទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបទល្មើសដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ដែរឬទេ។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ចោទប្រកាន់ថា ជនជាប់ចោទបានធ្វើទារុណកម្ម ឬធ្វើបាបទៅលើអ្នកជាប់ឃុំនៅមន្ទីរស-២១ ដោយផ្ទាល់ខ្លួនជាច្រើនដង។ អង្គជំនុំជម្រះបានយល់ឃើញថា មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទទទួលខុសត្រូវចំពោះអំពើទារុណកម្ម ឬអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈអំពើសកម្ម ឬអកម្ម ដែលគាត់បានប្រព្រឹត្តដោយផ្ទាល់ឡើយ។

ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានសម្រេចថា ការប្រព្រឹត្តិតាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម គឺជាទម្រង់ដែលអាចយកមកអនុវត្តចំពោះការទទួលខុសត្រូវ ទាំងនៅ អ.វ.ត.ក និងនៅក្នុងរឿងក្តីនេះ យ៉ាងហោចណាស់ក៏នៅក្នុងទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធរបស់សហឧក្រិដ្ឋកម្មរួមដែរ។ ជាពិសេសអង្គជំនុំជម្រះមានសំអាងហេតុជាច្រើនទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានលក្ខណៈ ជាប្រព័ន្ធនៅមន្ទីរស-២១ ដែលគ្រប់គ្រងដោយជនជាប់ចោទ។ នេះបង្ហាញឱ្យឃើញច្បាស់នូវទម្រង់ជាប្រព័ន្ធទីពីរនៃសហឧក្រិដ្ឋកម្មរួមដែលត្រូវបានយកមកអនុវត្ត នៅចំពោះមុខតុលាការអន្តរជាតិដទៃទៀត ទាក់ទងនឹងមន្ទីរឃុំឃាំង ឬរចនាសម្ព័ន្ធគ្រប់គ្រងដទៃទៀត ដែលអនុវត្តនូវការរំលោភបំពានជាប្រព័ន្ធប្រឆាំងនឹងអ្នកជាប់ឃុំ។

អង្គជំនុំជម្រះបានយល់ឃើញថា ក្រោយពេលជួបប្រជុំជាមួយ សុន សេន នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ ជនជាប់ចោទបានជួយបង្កើតមន្ទីរស-២១ ជាមួយនឹង អ៊ិន លន ហៅ ណាត ដែលជាប្រធានមន្ទីរស-២១ មុនគេ។ ក្នុងឋានៈជាប្រធាននិងជាលេខាមន្ទីរស-២១ ជនជាប់ចោទបានបន្តកែលម្អ និងដឹកនាំប្រតិបត្តិការមន្ទីរស-២១ ដោយមានការជួយជ្រោមជ្រែងពីសមាជិកគណៈកម្មាធិការមន្ទីរស-២១ ដែលមានឈ្មោះ ឃឹម វ៉ាក ហៅ ហ៊ និង នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ រហូតដល់បោះបង់ចោលមន្ទីរស-២១ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។ ជនជាប់ចោទបានបំពេញការងារជាមួយបុគ្គលទាំងនេះ និងតាមរយៈថ្នាក់លើរបស់គាត់ ដើម្បីដំណើរការមន្ទីរស-២១(ទួលស្លែង) ដែលជាកន្លែងមួយសម្រាប់ ប្រព្រឹត្តអំពើដោយខុសច្បាប់ក្នុងការឃុំខ្លួន សួរចម្លើយ និងសម្លាប់អ្នកទាំងឡាយណាដែលគេយល់ថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ទាំងជនជាតិខ្មែរនិងជនបរទេស។ ប្រព័ន្ធនៃការធ្វើបាប និងធ្វើទារុណកម្មដែលបានរៀបចំជាមុន ត្រូវបានអនុវត្តដោយមានចេតនា ធ្វើឡើង ដើម្បីបង្ក្រាបអ្នកជាប់ឃុំ និងដើម្បីទាញយកចម្លើយសារភាពពីពួកគេ ក្នុងអំឡុងពេលសួរចម្លើយ។ ស-២៤ ក៏ត្រូវបានប្រើប្រាស់ផងដែរជាមន្ទីរចំណុះសម្រាប់លត់ដំការងារពលកម្មដល់អ្នកជាប់ឃុំ ដែលបក្សកម្មុយនីស្តកម្ពុជាយល់ថា ជាជនសង្ស័យ។ ក្នុងឋានៈជាអនុប្រធាន និងក្រោយមកជាប្រធាន និងជាលេខាមន្ទីរស-២១ ជនជាប់ចោទបានជាប់ពាក់ព័ន្ធយ៉ាងជ្រៅ នៅក្នុងប្រព័ន្ធឧក្រិដ្ឋនេះ និងបានរួមចំណែកយ៉ាងច្រើនដល់ការបង្កើត និងការអនុវត្តប្រព័ន្ធនេះ តាមរយៈការចូលរួមក្នុងប្រតិបត្តិការចាប់ខ្លួនបុគ្គល សំខាន់ៗមួយចំនួន តាមរយៈការធានាឱ្យមានការឃុំខ្លួននិងសម្លាប់

បុគ្គលិកមន្ទីរស-២១ មួយចំនួន និងតាមរយៈការមានវត្តមានផ្ទាល់របស់ជនជាប់ចោទក្នុងពេលប្រព្រឹត្តអំពើទាំងនោះ។ លើសពីនេះទៀត ជនជាប់ចោទបានដឹងអំពីលក្ខណៈជាប្រព័ន្ធនៃឧក្រិដ្ឋកម្មនៅមន្ទីរស-២១ និងបានបំពេញភារកិច្ច ដោយមានចេតនាដើម្បីជួយជ្រោមជ្រែងគោលបំណងឧក្រិដ្ឋទាំងនោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះបានយល់ឃើញថាជាលទ្ធផលនៃការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួមជាប្រព័ន្ធនៅមន្ទីរស-២១ ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះបទល្មើសទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១។

អង្គជំនុំជម្រះបានយល់ឃើញបន្ថែមទៀតថា ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះការធ្វើផែនការ ការញុះញង់ ការបញ្ជា និងការជួយនិងជំរុញ ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយនៅមន្ទីរស-២១។ អង្គជំនុំជម្រះក៏បានយល់ឃើញផងដែរថា ជនជាប់ចោទមានការទទួលខុសត្រូវ ដោយផ្អែកទៅលើការទទួលខុសត្រូវក្នុងនាមគាត់ជាថ្នាក់លើ។ អង្គជំនុំជម្រះបានប្រើសំអាងហេតុបន្ថែមទាំងនេះ នៅពេលផ្តន្ទាទោសនៅក្នុងការសម្រេចអំពីវិសាលភាពពេញលេញនៃការចូលរួមរបស់ជនជាប់ចោទនៅក្នុងបទឧក្រិដ្ឋដែលគាត់ត្រូវទទួលខុសត្រូវ។

អង្គជំនុំជម្រះបានបដិសេធការទាមទាររបស់មេធាវីការពារក្តីដែលថា ជនជាប់ចោទមិនត្រូវទទួល ខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះ ដោយហេតុថា ជនជាប់ចោទបានប្រព្រឹត្តអំពើទាំងនោះតាមបញ្ជារបស់ថ្នាក់លើ និងក្រោមការបង្ខិតបង្ខំតែប៉ុណ្ណោះ។ តាមច្បាប់ ការប្រព្រឹត្តិតាមបញ្ជារបស់ថ្នាក់លើ មិនបង្កើតបានជាការការពារស្របច្បាប់ចំពោះការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។ នៅក្នុងរឿងក្តីនេះ ជនជាប់ចោទក៏បានដឹងថា បទបញ្ជាឱ្យសម្លាប់ ធ្វើទារុណកម្ម និងឃុំឃាំងតាមទំនើងចិត្ត នូវបុគ្គលដែលត្រូវទទួលបានការការពារតាមអនុសញ្ញាទីក្រុងហ្សឺណែវ គឺជាអំពើខុសច្បាប់។ លើសពីនេះទៀត ជនជាប់ចោទមិនអាចត្រូវបានចាត់ទុកថាបានប្រព្រឹត្តក្រោមការបង្ខិតបង្ខំក្នុងឋានៈជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស-២១ នោះទេ។ ទោះបីជាអង្គជំនុំជម្រះទទួលស្គាល់ថា រហូតដល់ចុងបញ្ចប់នៃអត្ថិភាពរបស់មន្ទីរស-២១ ជនជាប់ចោទអាចមានការភ័យខ្លាចថា គាត់ ឬសាច់ញាតិជិតស្និទ្ធរបស់គាត់នឹងត្រូវគេសម្លាប់ ប្រសិនបើថ្នាក់លើរបស់គាត់មិនពេញចិត្តនឹងអំពើរបស់គាត់ក៏ដោយ ក៏មិនអាចយកការបង្ខិតបង្ខំមកធ្វើជាសំអាងបានឡើយ ដោយសារជនជាប់ចោទខ្លួនឯងបានចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្ត ក្នុងការអនុវត្តគោលនយោបាយប្រកបដោយភាពភ័យរន្ធត់នោះ។ តាមពិតអំពើរបស់ជនជាប់ចោទក្នុងការអនុវត្តតួនាទីទាំងនេះ បានបង្ហាញឱ្យឃើញនូវកម្រិតដ៏ខ្ពស់នៃប្រសិទ្ធភាពការងារ និងការពេញចិត្តចំពោះភារកិច្ចរបស់គាត់។

ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល

ស្របតាមមាត្រា២៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក ចំពោះបទល្មើសខាងក្រោមនេះ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណី) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ព្រមទាំងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដក ហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

នៅពេលដែលមានការផ្តន្ទាទោសច្រើនបទល្មើស យុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធបានបង្កើតគោលការណ៍សម្រាប់កំណត់ថា តើបទល្មើសមួយណាដែលត្រូវផ្តន្ទាទោស និងបទល្មើសមួយណាដែលត្រូវយកទៅពិចារណាដាក់បញ្ចូលជាមួយបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរជាង។ អនុលោមទៅតាមគោលការណ៍នេះ អង្គជំនុំជម្រះបានៈ (ក) ប្រើប្រាស់ការផ្តន្ទាទោសសម្រាប់បទឧក្រិដ្ឋស្រដៀងគ្នា ជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយពិចារណាទៅលើលក្ខណៈខុសគ្នានៃប្រភេទបទឧក្រិដ្ឋទាំងពីរ (ខ) ដាក់បញ្ចូលបទល្មើសការធ្វើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទៅក្នុងបទល្មើសការសម្លាប់រង្គាល ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង (គ) ដាក់បញ្ចូលការផ្តន្ទាទោសចំពោះបទល្មើសទាំងអស់ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទៅក្នុងបទល្មើសការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

អង្គជំនុំជម្រះ បានពិចារណាលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលត្រូវផ្តន្ទាទោសទៅលើជនជាប់ចោទ ព្រមទាំងស្ថានទម្ងន់និងស្ថានសម្រាលទាំងអស់នៅពេលផ្តន្ទាទោស។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរ លើការវាយតម្លៃអំពីជំងឺវិកលចរិត និងជំងឺផ្លូវចិត្តរបស់ជនជាប់ចោទ ព្រមទាំងលើសាក្សីដែលបានផ្តល់សក្ខីកម្មអំពីអត្តចរិត នៅចំពោះមុខអង្គជំនុំជម្រះ ដែលជាការបន្ថែមទៅលើតួនាទីរបស់គាត់នៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងការកំណត់ទោស អង្គជំនុំជម្រះក៏បានពិចារណាផងដែរ ទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងៗទៀត ដែលសេចក្តីសម្រេចរបស់តុលាការអន្តរជាតិទាំងនោះ បានពិចារណាអំពីការកំណត់ទោសទាក់ទងនឹងបទឧក្រិដ្ឋដែលមានលក្ខណៈទ្រង់ទ្រាយធំ។ ជាចុងក្រោយ អង្គជំនុំជម្រះបានរំឭកឡើងវិញអំពី «សេចក្តីសម្រេចលើសំណើសុំដោះលែងឱ្យនៅក្រៅឃុំ» របស់ខ្លួនចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ដែលសម្រេចថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការកាត់បន្ថយទោសដែលនឹងត្រូវសម្រេចនៅដំណាក់កាលផ្តន្ទាទោសដោយសារតែការឃុំខ្លួនខុសច្បាប់នីតិវិធី

ដោយតុលាការយោធាកម្ពុជា ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ ជាការពិត ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ តម្រូវឱ្យមានការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលយូរមែន ក៏ប៉ុន្តែនៅពេលដែលពិចារណាអំពីការផ្តន្ទាទោសសរុបរួម មានកត្តាជាច្រើនបានធ្វើឱ្យអង្គជំនុំជម្រះមិនអាចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត តាមច្បាប់ អ.វ.ត.ក បានឡើយ។

ឥឡូវនេះ អង្គជំនុំជម្រះនឹងពិចារណាអំពីសំណាងរដ្ឋប្បវេណី មុននឹងការប្រកាសសេចក្តីសម្រេចទាំងមូលនៅក្នុងសាលក្រម។

## ច) សំណងរដ្ឋប្បវេណី

អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចអំពីភាពអាចទទួលយកបាន និងខ្លឹមសារនៃការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ស្របតាមវិធាន ១០០ អនុវិធាន១ នៃវិធានផ្ទៃក្នុង។ បទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង ដែលទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី តាំងពីចាប់ផ្តើមសវនាការមក មានការកែសម្រួលជាច្រើនដង។ ក្នុងចំណោមការធ្វើវិសោធនកម្ម ការធ្វើវិសោធនកម្មទាំងនេះ មានគោលបំណងជានាឱ្យដំណើរការនីតិវិធីរបស់ អ.វ.ត.ក អនុញ្ញាតឱ្យមានការចូលរួមរបស់ជនរងគ្រោះប្រកបដោយប្រសិទ្ធភាពទាក់ទងនឹងបទឧក្រិដ្ឋទ្រង់ទ្រាយធំ និងបរិបទកម្ពុជាជាក់លាក់។ ដោយសារតែមានភាពជឿនលឿននៃដំណើរការនីតិវិធីសំណុំរឿង០០១ ក្នុងពេលដែលវិសោធនកម្មទាំងនេះបានចាប់ផ្តើម បទប្បញ្ញត្តិដែលបានកែលម្អទាំងនោះមិនយកមកអនុវត្តចំពោះរឿងក្តីនេះទេ។

ការសម្រេចបឋម ទៅលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺផ្អែកលើមូលដ្ឋានបណ្តោះអាសន្នដែលថា ពាក្យសុំអាចទទួលយកបាននៅពេលលក្ខណៈវិនិច្ឆ័យសម្រាប់ ការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបំពេញ។ ដំណើរការនេះគឺខុសពីការសម្រេចរបស់អង្គជំនុំជម្រះលើអង្គសេចក្តី នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសាលក្រម ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានដាក់ជូននៅក្នុងអំឡុងពេលដំណើរការនីតិវិធី។ នៅពេលប្រកាសទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលដំបូងនៃដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញដល់អង្គជំនុំជម្រះអំពីខ្លឹមសារនៃការទាមទារ ដូចជា អត្ថិភាពនៃកំហុសរបស់ជនជាប់ចោទ និងទំនាក់ទំនងរវាងព្យសនកម្មផ្ទាល់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងនឹងកំហុសរបស់ជនជាប់ចោទ។

វិធាន២៣ អនុវិធាន២ នៃវិធានផ្ទៃក្នុងចែងថា ដើម្បីឱ្យពាក្យបណ្តឹងសុំតាំងខ្លួនជាដើម

បណ្ដឹងរដ្ឋប្បវេណីអាចទទួលយកបាន ព្យសនកម្មត្រូវតែជា «ការខូចខាតខាងរាងកាយ សម្ភារៈ ឬ ផ្លូវចិត្ត» និង «ជាផលវិបាកដោយផ្ទាល់ពីបទល្មើស ជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន»។ ព្យសនកម្ម ដែលបានទទួលរង ត្រូវតែកើតចេញដោយផ្ទាល់មកពីអំពើឧក្រិដ្ឋរបស់ជនជាប់ចោទ។ ទោះបីជាសមាជិកគ្រួសារជិតស្និទ្ធរបស់ជនរងគ្រោះ ស្ថិតនៅក្នុងវិសាលភាពនៃវិធាន២៣ អនុវិធាន២ ចំណុច(ខ) ក៏ដោយ ក៏ការខូចខាតផ្ទាល់មានការលំបាកក្នុងការបង្ហាញភស្តុតាងទាក់ទងទៅនឹងទំនាក់ទំនងសមាជិកគ្រួសារសាច់ឆ្ងាយ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះពិចារណាថា ព្យសនកម្មដែលសមាជិកគ្រួសារសាច់ឆ្ងាយរបស់ជនរងគ្រោះនៅក្នុងកាលៈទេសៈពិសេស អាចជាផលវិបាកដោយផ្ទាល់ និងអាចបញ្ជាក់បានពីបទឧក្រិដ្ឋ ដែលអ្នកដាក់ពាក្យសុំអាចបង្ហាញភស្តុតាងអំពីភាពជាសាច់ញាតិ និងអត្ថិភាពនៃកាលៈទេសៈដែលបង្កើតឱ្យមានចំណងនៃសេចក្ដីស្រលាញ់ពិសេស ឬភាពនៅក្នុងបន្ទុករបស់អ្នកដែលបានស្លាប់ទៅ។

អង្គជំនុំជម្រះ បានពិចារណាថា តើ កាំង ហ្កេកអ៊ាវ អាចត្រូវគេរកឃើញថាមានការទទួលខុសត្រូវដែរឬទេ ចំពោះព្យសនកម្មជាក់លាក់ដែលត្រូវបានទាមទារដោយដើមបណ្ដឹងរដ្ឋប្បវេណីពីរប្រភេទគឺ បុគ្គលដែលអះអាងថាជាអ្នកនៅរស់រានមានជីវិតពីមន្ទីរស-២១ ឬស-២៤ និងបុគ្គលដែលអះអាងថាជាសាច់ញាតិ ឬមានចំណងនៃសេចក្ដីស្រលាញ់ពិសេស ឬភាពនៅក្នុងបន្ទុកជនរងគ្រោះផ្ទាល់។ ចំពោះហេតុផលដែលបានរៀបរាប់លម្អិតនៅក្នុងសាលក្រម អង្គជំនុំជម្រះបានយល់ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីបួននាក់ខាងក្រោមនេះ ដែលបានអះអាងថាជាអ្នកនៅរស់រានមានជីវិតពីមន្ទីរស-២១ ឬស-២៤ បានបង្ហាញភស្តុតាងបញ្ជាក់អំពីអំណះអំណាងរបស់ពួកគាត់ និងបានបង្ហាញថាជនជាប់ចោទមានការទទួលខុសត្រូវដោយផ្ទាល់ចំពោះព្យសនកម្ម ដែលពួកគាត់បានទទួលរង។

ប៊ូ ម៉េង, ជុំ មី៉, ជុំ នៅ និង ជិន ម៉េត។

អង្គជំនុំជម្រះបានយល់ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៦៦នាក់ ខាងក្រោមនេះបានបង្ហាញអំពីអំណះអំណាងថាជាជនរងគ្រោះផ្ទាល់នៃមន្ទីរស-២១ ឬស-២៤ ឬបានបង្ហាញអំពីអត្ថិភាពនៃភាពជាសាច់ញាតិជិតស្និទ្ធ ឬចំណងនៃសេចក្ដីស្រលាញ់ពិសេសជាមួយនឹងជនរងគ្រោះផ្ទាល់នៃមន្ទីរស-២១ ឬស-២៤ ឬភាពនៅក្នុងបន្ទុករបស់ជនរងគ្រោះទាំងនោះ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញបន្ថែមថា មរណភាពរបស់ជនរងគ្រោះទាំងនោះ ធ្វើឱ្យមានព្យសនកម្មដែលមានចែងនៅក្នុងវិធាន២៣ អនុវិធាន២ នៃវិធានផ្ទៃក្នុង ហើយការខូចខាតនេះ គឺជាផលវិបាកដោយផ្ទាល់នៃកំហុសរបស់ជនជាប់ចោទ។

- ប៊ូ ម៉េង គឺជាអ្នករស់រានមានជីវិតពីមន្ទីរស-២១ ហើយគាត់បាត់បង់ប្រពន្ធរបស់គាត់ឈ្មោះ ម៉ា យឿន ហៅ ធី។

- ជុំ ម៉ី គឺជាអ្នករស់រានមានជីវិតពីមន្ទីរស-២១។

- ជុំ នៅ គឺជាអ្នករស់រានមានជីវិតពី ស-២៤ ហើយគាត់បានបាត់បង់ប្ដីរបស់គាត់ឈ្មោះ នូ សាមឿន និងកូនរបស់គាត់ម្នាក់។

- ជិន ម៉េត គឺជាអ្នករស់រានមានជីវិតពីស-២៤។

- ឈិន ណារី បានបាត់បង់ប្ដីរបស់គាត់ឈ្មោះ ទា ហាវតិក។

- ហាវ សោភា បានបាត់បង់ឪពុករបស់គាត់ឈ្មោះ ចិន សៀ ហៅ ហាវ ហាន។

- ភឹងហ្គុត ស៊ុនថារី និង អ៊ឹម ស៊ុន្នី បានបាត់បង់ឪពុក និងប្ដីរបស់គាត់ឈ្មោះ ភឹង តុន។

- ជុំ ស៊ីរ៉ាត បានបាត់បង់ប្អូនប្រុសពីរនាក់របស់គាត់ឈ្មោះ ជុំ ណារិត និង ជុំ ស៊ីណារ៉េត។

- មាសកេត សំភាត់, ជូឡុង អង់តូនីញ៉ា (TIOULONG Antonya), ជូឡុង ណេវ៉ា (TIOULONG-ROHMER Neva), គីម៉ារី ណេវីនកា (KIMARI Nevinka) និង គីម៉ារី វីសាកា (KIMARI Visaka) បានបាត់បង់កូនស្រី ប្អូនស្រី និងម្ដាយឈ្មោះ ជូឡុង រង្ស៊ី និងកូនប្រសាប្រុស ប្អូនថ្លៃប្រុស និងឪពុកឈ្មោះ លឹម គីម៉ារី។

- រស់ ម៉េន បានបាត់បង់ប្អូនប្រុសរបស់គាត់ឈ្មោះ រស់ ធឹម។

- ឆែ ហ៊ាប បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ឆែ ហេង។

- ជ្រាំង សំអ៊ាន បានបាត់បង់ប្អូនប្រុសរបស់គាត់ឈ្មោះ ជ្រាំង សំអុន ហៅ សោម សំអុន។

- ស៊ាង វ៉ាន់ឌី បានបាត់បង់ប្អូនប្រុសរបស់គាត់ឈ្មោះ ស៊ាង ផុន។

- តូច មុនិន្ទ បានបាត់បង់បងប្រុសជីដូនមួយរបស់គាត់ឈ្មោះ ជា ខន ដែលបានចិញ្ចឹមបីបាច់រូបគាត់ ហើយដែលគាត់ជាសាច់ញាតិដែលនៅរស់រានមានជីវិតតែម្នាក់គត់។

- កាន់ ស៊ុន្ទរ៉ា បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ជឹម ឡាង និងបងថ្លៃស្រីឈ្មោះ អោម យិនដូនី។
- ម៉ាន សូត បានបាត់បង់កូនប្រុសរបស់គាត់ឈ្មោះ ម៉ាន ស៊ីម ហៅ រៀម។
- គង់ ទេស បានបាត់បង់ប្តីរបស់គាត់ឈ្មោះ សេក ឆៀក។
- ង៉ែត សុខ បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ណុប សរ ហៅ ណុប ង៉ាន ហៅ ចារឹន ហៅ ង៉ែត ង៉ែម។
- តាត់ ឡូន បានបាត់បង់ឪពុករបស់គាត់ឈ្មោះ សុក ស៊ិត ហៅ សុក ប៉ុន។
- ធីម៉ូធី ស្កុត ឌីដ បានបាត់បង់បងប្រុស របស់គាត់ឈ្មោះ ម៉ៃយល ឌីដ។
- យឹម ឡេង បានបាត់បង់ឪពុករបស់គាត់ឈ្មោះ ផ្លក លួន ហៅ  យ៉ន។
- អ៊ុម ពិសិដ្ឋ គឺជាសិទ្ធិវន្តរបស់ប្រពន្ធគាត់ឈ្មោះ សួស សារិន ដែលបានបាត់បង់បងស្រីប្រពន្ធរបស់គាត់ឈ្មោះ សួស សារណ្ណ។
- កែ ខុន និង កែ សាម៉ូត បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ កែ កេងស៊ី។
- អៀម សួយ ដែលបានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ជុក ចយ ហៅ  ជៀវ។
- អ៊ុល សាយ ហៅ  រៀម បានបាត់បង់ប្តីរបស់គាត់ឈ្មោះ អេង ម៉ាក ហៅ វ៉ែន។
- ស៊ីន លឹមសៀ បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ ស៊ីន ឈុនលីម។
- អ៊ូ សារិទ្ធ, ញឹក អ៊ូដាវី (NHEK Oudavy) និង អ៊ូ កាមេឡា (OU Kamela) បានបាត់បង់ ប្អូនប្រុស ប្តី និងឪពុកឈ្មោះ អ៊ូ វិនឌី។
- រស់ ជួ ស៊ីអ៊ី (ROS Chuorsiy) បានបាត់បង់ប្តីរបស់គាត់ឈ្មោះ រស់ សារិន។
- ញឹម គឹមហឿន បានបាត់បង់បងប្រុសទាំងពីររបស់គាត់ឈ្មោះ ញឹម គួយ និង ញឹម ចាន់។

- សួន សុខុម៉ាលី (SUON Sokhomaly) បានបាត់បង់ប្ដីរបស់គាត់ឈ្មោះ សួន កាសេត។

- ស៊ិន ស៊ីណែត ហៅ ស្រ៊ុន បានបាត់បង់ជីតារបស់គាត់ឈ្មោះ ភាច គឹម ហៅ ស៊ិន ដែលរូបគាត់បានរស់នៅផ្ទះជាមួយតាំងពីគាត់អាយុ៧ឆ្នាំ។

- រូន ស្រីណុប បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ រូន ម៉ាត់ ហៅ សារី។

- អែល លីម៉ះ បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ អ៊ីស្មាអ៊ែល អាម៉ាត់ ហៅ សុខ។

- ស្មាន ស និង ស្មាន ណុប បានបាត់បង់ប្អូនប្រុសរបស់គាត់ឈ្មោះ ស្មាន ស្លេះ ហៅ ឡេង សុខា និងក្មួយឈ្មោះ សា ម៉ាត់ ហៅ សារឿន។

- ម៉ែន ឡាយ បានបាត់បង់កូនប្រុសរបស់គាត់ឈ្មោះ មិន កាន។

- ញ៉ែម សុផាន បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ ញ៉ែម ថុល ហៅ រ៉ា។

- នេត ផល្លី បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ នេត ប៊ុនធី។

- ម៉ាន ម៉ះ ហៅ ម៉ាន ម៉ាលីម៉ះ បានបាត់បង់កូនប្រុសរបស់គាត់ឈ្មោះ តា ឡសម៉ាត់ ហៅ ម៉ាន ម៉ាត់។

- កុំ មេន ហៅ គុម មេន បានបាត់បង់ប្ដីរបស់គាត់ឈ្មោះ ស្រី យ៉េង។

- ទ្រី ង៉ិចលាង បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ខឿង មួយស័រ។

- ហេង ង៉ិចហុង បានបាត់បង់ឪពុករបស់គាត់ឈ្មោះ សុក ហេង។

- បេង ចាន់ថន បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ បេង ពុំ។

- យុន ឈីន បានបាត់បង់ក្មួយប្រុសរបស់គាត់ឈ្មោះ យុន សឿន ដែលបានរស់នៅជាមួយគាត់រហូតដល់អាយុ១៥ឆ្នាំ នៅពេលដែលក្មួយរបស់គាត់បានចូលបដិវត្តន៍

- លី យៀក បានបាត់បង់ប្អូនស្រីរបស់គាត់ឈ្មោះ អួយ វ៉ែន ហៅ ម៉ៅ ។

- ពូល ពន្លឹក ហៅ ង៉ែត បានបាត់បង់ឪពុករបស់គាត់ឈ្មោះ ពូល ទឿន ហៅ

ចាំង។

- ចាន់ គ្រួច បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ចាន់ នួន ហៅ ស៊ីនួន។
- នង គឹមលៀង បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ នង គឹមហ្គេច ហៅ នង គឹមវ៉េត។
- ពេញ សុខេន បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ ពេញ សុភាព។
- កាន សាន បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ កាន កន។
- អ៊ុង វឿន ហៅ ហ៊ុល វឿន បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ អ៊ុង គាំ ហៅ ភ័ណ។
- មាស សារឿន បានបាត់បង់ឪពុករបស់គាត់ឈ្មោះ អ៊ុក តុប។
- សេក សៀក បានបាត់បង់បងជីដូនមួយ និងគូដណ្ដឹងរបស់គាត់ឈ្មោះ ម៉ក់ ឈឿន ដែលបានរស់នៅក្នុងគ្រួសាររបស់គាត់។
- ឆាត គឹម ឈុន បានបាត់បង់ឪពុករបស់គាត់ឈ្មោះ អំា ជាត់ និងសាច់ញាតិរបស់គាត់ឈ្មោះ ពត ម៉យ ហៅ សាផល។
- អ៊ុក វ៉ាសោធិន បានបាត់បង់ឪពុករបស់គាត់ឈ្មោះ អ៊ុក ជី។
- ម៉ាទីន លីហ៊ួយ និង អ៊ុក នារី បានបាត់បង់ប្ដីនិងឪពុកឈ្មោះ អ៊ុក កេត។
- រ៉ូប៊ីត ហាមីល បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ  ឃែរី ហាមីល។

ការទាមទារសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលនៅសេសសល់ទាំងប៉ុន្មានទៀតត្រូវបានបដិសេធ ដោយហេតុថាដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះ មិនបានបង្ហាញឱ្យអង្គជំនុំជម្រះជឿថា ពួកគាត់គឺជាសាច់ញាតិជិតស្និទ្ធជាមួយនឹងជនរងគ្រោះមន្ទីរស-២១ ឬ ស-២៤ នោះទេ ឬថាពួកគាត់មិនបានបង្ហាញអំពីអត្ថិភាពនៃភាពជាសាច់ញាតិជិតស្និទ្ធ ឬ ចំណងនៃសេចក្ដីស្រលាញ់ពិសេស ឬភាពនៅក្នុងបន្ទុករបស់ជនរងគ្រោះនៃមន្ទីរស-២១ ឬស-២៤ នោះទេ។ អាស្រ័យហេតុនេះ ការទាមទារសំណងរបស់ពួកគាត់ ក៏ត្រូវបានបដិសេធដែរ។

អង្គជំនុំជម្រះក៏បានចេញសេចក្ដីសម្រេចផងដែរ ទៅលើបណ្ដឹងទាមទារសំណងរបស់ដើមបណ្ដឹង រដ្ឋប្បវេណី។ ដើម្បីទទួលបានជោគជ័យ បណ្ដឹងទាមទារទាំងនេះត្រូវតែមានលក្ខណៈជាសំណងផ្លូវចិត្ត និងជាសមូហភាព ស្ថិតក្នុងអត្ថន័យនៃវិធាន២៣ អនុវិធាន១ ចំណុច(ខ) នៃវិធានផ្ទៃក្នុង និងមានលក្ខណៈច្បាស់លាស់ ឬជាក់លាក់គ្រប់គ្រាន់ ដែលអាចឱ្យអង្គជំនុំជម្រះចេញដីកាបង្គាប់ប្រឆាំងនឹងពិរុទ្ធជនបាន។

លក្ខណៈសំខាន់នៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីគឺថា ការផ្ដល់សំណងគឺជាបន្ទុកផ្ទាល់មុខរបស់ពិរុទ្ធជន បន្ទាប់ពីមានការសម្រេចអំពីការទទួលខុសត្រូវចំពោះព្យសនកម្ម ដែលបានលើកឡើង ដោយដើមបណ្ដឹងរដ្ឋប្បវេណីថាជាព្យសនកម្ម ដែលបានបណ្ដាលមកពីការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ។ អ.វ.ត.ក ដែលជាតុលាការកូនកាត់អន្តរជាតិក្នុងតុលាការកម្ពុជា មិនមានសមត្ថកិច្ចអនុវត្តដោយបង្ខំចំពោះសេចក្ដីសម្រេចអំពីសំណងឡើយ។ អង្គជំនុំជម្រះពុំមានយុត្តាធិការទៅលើអាជ្ញាធរកម្ពុជា ឬអាជ្ញាធរជាតិដទៃទៀត ឬស្ថាប័នអន្តរជាតិឡើយ។ អង្គជំនុំជម្រះក៏មិនអាចដាក់កាតព្វកិច្ច ឬផ្ដល់សិទ្ធិដល់បុគ្គល ឬអង្គភាពនានា ដែលមិនមែនជាភាគីនៃដំណើរការនីតិវិធីបានឡើយ។ នៅក្នុងបរិបទបច្ចុប្បន្ននេះ ឧបសគ្គជាក់ស្ដែងគឺថា ដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងនូវការបាត់បង់យ៉ាងធំធេង ហើយការបាត់បង់ទាំងនេះមិនអាចនឹងសងរួចវិញដោយពិរុទ្ធជនដែលទំនងជា អ្នកទីទ័លក្រគ្មានលទ្ធភាពនោះទេ។

អង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានស្នើសុំឱ្យបញ្ចូលឈ្មោះ របស់ពួកគាត់នៅក្នុងសាលក្រមចុងក្រោយ រួមទាំងសេចក្ដីបញ្ជាក់អំពីទំនាក់ទំនងរបស់ពួកគាត់ជាមួយនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១។ អង្គជំនុំជម្រះក៏បានយល់ព្រមផងដែរ ទៅនឹងសំណើសុំឱ្យមានការចងក្រង និងបោះពុម្ពផ្សាយនូវពាក្យសម្ដីសុំអភ័យទោសដែលបានធ្វើឡើងដោយជនជាប់ចោទក្នុងអំឡុងពេលសវនាការ។

អង្គជំនុំជម្រះបានបដិសេធសំណើសុំផ្សេងៗទៀតទាំងអស់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយហេតុថា សំណើសុំទាំងនោះមិនមានភាពជាក់លាក់ ឬហួសពីវិសាលភាពដែល អ.វ.ត.ក អាចសម្រេចបាន។

## ឆ) សេចក្ដីសម្រេច

ឥឡូវនេះ អង្គជំនុំជម្រះប្រកាសនូវសេចក្ដីសម្រេចរបស់ខ្លួន។
ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ក្រោកឈរ!

ក្រោយពីបានពិចារណាលើរាល់ភស្តុតាង និងសេចក្តីសន្និដ្ឋានទាំងអស់របស់ភាគី អង្គជំនុំជម្រះ សម្រេច ដូចខាងក្រោមនេះ ៖

អង្គជំនុំជម្រះរកឃើញថា កាំង ហ្កេកអ៊ាវ មានពិរុទ្ធភាព តាមមាត្រា៥ មាត្រា៦ និងមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ពីបទ ៖

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ) ដោយរួមបញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះ៖

- ការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត)
- ការធ្វើឱ្យទៅជាទាសករ
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណី)
- អំពើអមនុស្សធម៌ផ្សេងៗទៀត និង

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖**

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និង
- ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

តាមសំអាងហេតុដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនអំពីអញ្ញត្រកម្ម អង្គជំនុំជម្រះមិនពិចារណាអំពីពិរុទ្ធភាពរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងបទចោទប្រកាន់ពីបទឧក្រិដ្ឋជាតិនៃការធ្វើមនុស្សឃាតគិតទុកជាមុន និងការធ្វើទារុណកម្ម ដែលជាការរំលោភបំពានលើមាត្រា៥០១ មាត្រា៥០៦ និងមាត្រា៥០០ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលអាចផ្តន្ទាទោសនៅចំពោះមុខ អ.វ.ត.ក ស្របតាមមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ទេ។

ដើម្បីកំណត់ទោសឱ្យបានសមរម្យ អង្គជំនុំជម្រះបានពិចារណាគ្រប់កាលៈទេសៈទាំងអស់នៃរឿងក្តី។ អង្គជំនុំជម្រះបានកត់សម្គាល់នូវស្ថានទម្ងន់ទោសនានា ដែលរួមទាំង

ភាពឃោរឃៅ និងសាហាវយង់ឃ្នងនៃបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តមកលើជនរងគ្រោះយ៉ាងហោចណាស់ចំនួន ១២.២៧៣ នាក់ ក្នុងអំឡុងពេលនោះ។ នៅពេលពិចារណាអំពីពិរុទ្ធភាពនៃបទល្មើសច្រើន កត្តានៃស្ថានទម្ងន់ទោសទាំងអស់នេះ ត្រូវជានាឱ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារក្នុងរយៈពេលមួយយ៉ាងយូរ។

អង្គជំនុំជម្រះបានសម្រេចថា មានស្ថានសម្រាលទោសមួយចំនួនដែលតម្រូវឱ្យមានការផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារដែលមានរយៈពេលកំណត់ជាក់លាក់មួយ ជាជាងការដាក់ពន្ធនាគារអស់មួយជីវិត។ ស្ថានសម្រាលទោសទាំងនេះ រួមមាន៖ កិច្ចសហការរបស់ជនជាប់ចោទជាមួយអង្គជំនុំជម្រះ ការទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្លួន ការសម្តែងវិប្បដិសារី ទោះបីជាមិនបានទូលំទូលាយក៏ដោយ បរិយាកាសបង្ខិតបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងលទ្ធភាពដែលថាជនជាប់ចោទអាចនឹងស្តានីតិសម្បទាឡើងវិញបាន។

ដោយផ្អែកលើស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស ដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះដោយមតិភាគច្រើន សម្រេចផ្តន្ទាទោស កាំង ហ្គេកអ៊ាវ ដាក់ពន្ធនាគារសរុបរួមកំណត់ ៣៥ ឆ្នាំ។

អង្គជំនុំជម្រះយល់ឃើញថា ការកាត់បន្ថយទោសពីរយៈពេលផ្តន្ទាទោសខាងលើចំនួន ៥ឆ្នាំ គឺជាការផ្តល់ជូនដ៏សមរម្យចំពោះការរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងអំឡុងពេលឃុំខ្លួនខុសច្បាប់នីតិវិធីដោយតុលាការយោធាកម្ពុជា ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។

ជនជាប់ចោទត្រូវទទួលបានការទូទាត់នូវរយៈពេលឃុំខ្លួននៅក្រោមសមត្ថកិច្ចរបស់តុលាការ យោធាកម្ពុជាចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ និងរយៈពេលឃុំខ្លួនបណ្តោះអាសន្ននៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក ចាប់ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ រហូតដល់សាលក្រមនេះចូលជាស្ថាពរ។

កាលពីមុន អង្គជំនុំជម្រះបានរាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលបានទទួលរងនូវព្យសនកម្ម ដែលជាផលវិបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ត្រូវបានរកឃើញថាមានពិរុទ្ធភាព។ អង្គជំនុំជម្រះ នឹងធ្វើការចងក្រងនូវពាក្យសម្តីសុំអភ័យទោសទាំងអស់ និងការទទួលស្គាល់នូវការទទួលខុសត្រូវរបស់ កាំង ហ្គេកអ៊ាវ នៅក្នុងអំឡុងពេលសវនាការ។ កម្រងនេះត្រូវដាក់នៅលើ គេហទំព័រផ្លូវការរបស់ អ.វ.ត.ក នៅក្នុងរយៈពេល១៤ថ្ងៃ ក្រោយពីពេលសាលក្រមនេះចូលជាស្ថាពរ។ អង្គជំនុំជម្រះបដិសេធការទាមទារផ្សេងៗទៀតទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី។

បើកផ្លូវប្តឹងសាទុក្ខដល់ភាគីតាមកំណត់នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

ដោយសារស្ថានភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលគាត់មានពិរុទ្ធ អង្គជំនុំជម្រះត្រូវរក្សាទុក ពិរុទ្ធជន កាំង ហ្កេកអ៊ាវ នៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតដល់សាលក្រមនេះចូលជាស្ថាពរ ។

នេះគឺជាសេចក្តីសង្ខេបនៃសាលក្រម។ ដំណើរការនីតិវិធីជំនុំជម្រះនៅក្នុងរឿងក្តីនេះ ឃើញថាមកដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសបិទសវនាការ៕

អនុរក្សមន្ទីរឃុំឃាំងនាំពិរុទ្ធជនត្រឡប់ទៅមន្ទីរឃុំឃាំង អ.វ.ត.ក វិញចុះ!



# ៥. សេចក្តីសង្ខេបនៃសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល

# ៥. សេចក្ដីសង្ខេបនៃសាលដីការបស់ អង្គជំនុំជម្រះតុលាការកំពូល



## សេចក្ដីសង្ខេបនៃសាលដីកា

សំណុំរឿងលេខ០០១/១៨-០៧-២០០៧/អ.វ.ត.ក./អ.ជ.ត.ក.
(កាំង ហ្កេកអ៊ាវ ហៅ «ឌុច» )

ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២

### ក. សេចក្ដីផ្ដើម

១. ខាងក្រោមនេះ គឺជាសេចក្ដីសង្ខេបសំអាងហេតុដែលដកស្រង់ចេញពីសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០១។ ផ្នែកសំអាងហេតុដែលមានអានុភាពតាមផ្លូវច្បាប់មាននៅក្នុងសាលដីកាពេញលេញរបស់អង្គជំនុំជម្រះតុលាការកំពូល។ អត្ថបទសាលដីកាពេញលេញ ជាភាសាខ្មែរនិងជាភាសាអង់គ្លេស នឹងមានក្នុងពេលឆាប់ៗខាងមុខ ហើយនឹងត្រូវបកប្រែជាភាសាបារាំងតាមក្រោយ។

២. អង្គជំនុំជម្រះសាលាដំបូង បានចេញសាលក្រមរបស់ខ្លួននៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។ ការដាក់សារណាបណ្ដឹងសាទុក្ខជាលាយលក្ខណ៍អក្សរ ត្រូវបានបញ្ចប់ត្រឹមថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ហើយសវនាការលើបណ្ដឹងសាទុក្ខបានធ្វើឡើងចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១។ រយៈពេលនៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខនិងទំហំនៃសាលដីកាបានឆ្លុះបញ្ចាំងអំពីចរិតលក្ខណៈជាប្រវត្តិសាស្ត្រនៃរឿងក្ដីនេះដែលជារឿងក្ដីទីមួយនៅចំពោះមុខ អ.វ.ត.ក. និងបង្ហាញអំពីភាពថ្មីស្រឡាងនិងស្មុគស្មាញនៃបញ្ហាគតិយុត្តនៅក្នុងទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខ។

៣. នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងនាមជាអនុលេខា ហើយបន្ទាប់មកជាលេខាមន្ទីរស-២១ ជនជាប់ចោទបានចាត់ចែងនិងពង្រឹងប្រព័ន្ធគ្រប់គ្រងអស់រយៈពេលជាងបីឆ្នាំដែលបណ្ដាលឱ្យមានការសម្លាប់ជនរងគ្រោះ

មិនតិចជាង ១២.២៧២ នាក់ ដែលជនរងគ្រោះភាគច្រើនត្រូវបានទទួលរងនូវការធ្វើទារុណកម្មជាប្រព័ន្ធ។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ៣៥ ឆ្នាំ ដោយផ្អែកលើការរកឃើញថា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ(ដោយស្រូបបញ្ចូលនូវបទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានដូចជា ការសម្លាប់រង្គាល(រួមបញ្ចូលអំពើមនុស្សឃាត) ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមបញ្ចូលការរំលោភផ្លូវភេទមួយករណី) និងអំពើអមនុស្សធម៌ផ្សេងៗទៀត) និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ រួមមាន ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្មនិងការធ្វើបាបដោយអមនុស្សធម៌ ការបង្កឱ្យមានការឈឺចាប់ដោយចេតនា ឬឱ្យមានរបួសធ្ងន់ធ្ងរដល់រូបរាងកាយឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបាននូវការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាត់បន្ថយទោសចំនួន០៥ ឆ្នាំពីរយៈពេលផ្តន្ទាទោស ដោយសារការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ក្នុងអំឡុងពេលឃុំខ្លួនខុសច្បាប់នីតិវិធីដោយតុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផងដែរថា ជនជាប់ចោទត្រូវទទួលបានការទូទាត់នូវថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទាំងស្រុងចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ (ក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា) និងពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ រហូតដល់សាលក្រមចូលជាស្ថាពរ។

៤. អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំណងពីរប្រភេទដល់ដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងសាលក្រមរបស់ខ្លួនថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ពិតជាបានទទួលរងគ្រោះដែលជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋទាំងឡាយ ដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព ហើយអង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមធ្វើការចងក្រងពាក្យសម្តីសុំអភ័យទោសទាំងអស់និងពាក្យសម្តីទទួលស្គាល់ការទទួលខុសត្រូវដែលជនជាប់ចោទបានធ្វើនៅក្នុងអំឡុងពេលសវនាការ ហើយកម្រងពាក្យសម្តីទាំងនេះនឹងត្រូវដាក់នៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក. ក្នុងរយៈពេល១៤ ថ្ងៃបន្ទាប់ពីសាលក្រមរបស់ខ្លួនចូលជាស្ថាពរ។

៥. អង្គជំនុំជម្រះតុលាការកំពូលធ្វើសេចក្តីសង្ខេបសំអាងហេតុរបស់ខ្លួនទៅលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដូចខាងក្រោម។

## ខ. យុត្តាធិការលើរូបបុគ្គល

៦. ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរូបបុគ្គលចំពោះខ្លួននោះទេ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលគប្បីបដិសេធការសម្រេចដាក់ពិរុទ្ធភាពនិងការផ្តន្ទាទោសលើខ្លួន។ យោងតាមការលើកឡើងរបស់ជនជាប់ចោទថា ទាំងការទទួលខុសត្រូវផ្នែកប្រតិបត្តិ និងតួនាទីដែលខ្លួនបានបំពេញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពុំបានធ្វើឱ្យខ្លួនគាត់ស្ថិតក្នុងអត្ថន័យជា«មេដឹកនាំជាន់ខ្ពស់»មួយរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ ឬជាជនម្នាក់ក្នុងចំណោម«ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត»ចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ សហព្រះរាជអាជ្ញាបានលើកឡើងថា ទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ជនជាប់ចោទទាក់ទងនឹងយុត្តាធិការលើរូបបុគ្គលមិនអាចទទួលយកបានឡើយ ដោយសារតែសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនិងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទពុំបានបំពេញនូវបទដ្ឋានអប្បបរមានៃសារណាការពារបណ្តឹងសាទុក្ខ។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិបដិសេធសារណារបស់មេធាវីការពារក្តីស្តីពីយុត្តាធិការលើរូបបុគ្គលដោយសារតែសារណានេះមិនត្រូវបានធ្វើឡើងឱ្យបានទាន់ពេលវេលា ហើយអង្គជំនុំជម្រះសាលាដំបូងយល់ឃើញត្រឹមត្រូវក្នុងការសន្និដ្ឋានថា ពាក្យពេចន៍«មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត»សំដៅលើជនសង្ស័យពីរប្រភេទដាច់ដោយឡែកពីគ្នា និងអង្គជំនុំជម្រះសាលាដំបូងយល់ឃើញត្រឹមត្រូវក្នុងការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការលើរូបបុគ្គលជនជាប់ចោទដោយផ្អែកទៅលើឋានៈរបស់ជនជាប់ចោទជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល«ទទួលខុសត្រូវខ្ពស់បំផុត»ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣បានឆ្លើយតបដោយគាំទ្រការលើកឡើងរបស់សហព្រះរាជអាជ្ញា។

៧. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការជំនុំជម្រះប្រកបដោយយុត្តិធម៌តម្រូវថាជនជាប់ចោទត្រូវមានសិទ្ធិលើកឡើងនូវការជំទាស់អំពីកង្វះយុត្តាធិការដែលស្តែងឱ្យឃើញច្បាស់ឬមិនស្តែងឱ្យឃើញច្បាស់ដែលអាចប៉ះពាល់ដល់ការជំនុំជម្រះក្តីនៅពេលណាដែលជនជាប់ចោទសម្រេចថា ខ្លួនត្រូវការពារផលប្រយោជន៍របស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែសម្រេចលើការជំទាស់ណាមួយឬទាំងអស់ទៅនឹងយុត្តាធិការដែលជនជាប់ចោទបានលើកឡើង យ៉ាងយូរបំផុត«នៅពេលដំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី»។ នៅក្នុងករណីដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋណាមួយនោះ ជនជាប់ចោទមាន«សិទ្ធិស្នើសុំឱ្យសាលាជម្រះក្តីជាន់ខ្ពស់ពិនិត្យឡើងវិញទៅលើការសម្រេចដាក់ពិរុទ្ធភាពនិងការផ្តន្ទាទោសដោយ

អនុលោមតាមច្បាប់»។ ដោយផ្អែកទៅលើសិទ្ធិនេះ ជនជាប់ចោទមានសិទ្ធិប្តឹងសាទុក្ខទៅលើកំហុសអង្គច្បាប់ ឬអង្គហេតុនានាដែលអាចធ្វើឱ្យមោឃៈសាលក្រម ឬបណ្តាលឱ្យសាលក្រមមានភាពមិនយុត្តិធម៌ដែលរួមបញ្ចូលទាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីយុត្តាធិការលើរូបបុគ្គលផងដែរ។

៨. ទាក់ទងនឹងបទដ្ឋាននៃសារណាបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បញ្ហាសំខាន់ដែលត្រូវសម្រេចនោះគឺ ថាតើម្ចាស់បណ្តឹងសាទុក្ខបានលើកហេតុផលរបស់ខ្លួន ក្នុងលក្ខណៈដែលអាចឱ្យភាគីផ្សេងទៀតមានលទ្ធភាពដឹងអំពីបញ្ហាដែលខ្លួនត្រូវប្រឈម និងដែលអាចឱ្យអង្គជំនុំជម្រះតុលាការកំពូលមានលទ្ធភាពកំណត់និងសម្រេចបានលើបញ្ហាវិវាទ ដែរឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បញ្ហាសំខាន់ៗនៅក្នុងបណ្តឹងសាទុក្ខរបស់ជនជាប់ចោទដែលត្រូវបានលើកឡើងសម្រាប់ការសម្រេចសេចក្តីពុំមានលក្ខណៈពិបាកក្នុងការកំណត់នោះទេ ហើយផ្អែកពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក៏មានលក្ខណៈអាចកត់សម្គាល់បានយ៉ាងងាយដែរនិងអាចកំណត់បានយ៉ាងច្បាស់ចំពោះសំអាងហេតុដែលនាំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសន្និដ្ឋានថា ជនជាប់ចោទគឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល«ទទួលខុសត្រូវខ្ពស់បំផុត»។

៩. ចំពោះបញ្ហាសំខាន់នៃយុត្តាធិការលើរូបបុគ្គល យោងតាមអត្ថន័យធម្មតានៃពាក្យពេចន៍ដែលមាននៅក្នុងបរិបទនិងដោយពិចារណាអំពីកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពាក្យពេចន៍«មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត»សំដៅទៅលើកម្មាភិបាលខ្មែរក្រហមពីរប្រភេទខុសគ្នា ប៉ុន្តែប្រភេទទាំងពីរនេះមានទំនាក់ទំនងគ្នា។ ប្រភេទទីមួយ គឺជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះមេដឹកនាំជាន់ខ្ពស់ម្នាក់មិនមែនជាជនសង្ស័យដោយផ្អែកតែទៅលើតួនាទីជាមេដឹកនាំរបស់ខ្លួនប៉ុណ្ណោះទេ។ ប្រភេទមួយផ្សេងទៀត គឺអ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែជាអ្នកដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតផងដែរ។ ជនទាំងពីរប្រភេទនេះ គឺជា«ជនសង្ស័យ»ដែលជាកម្មវត្ថុនៃការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក.។

១០. អង្គជំនុំជម្រះតុលាការកំពូលក៏ត្រូវពិចារណាផងដែរ ថាតើការបកស្រាយពាក្យពេចន៍«មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត»ថា ជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការនោះមានលក្ខណៈស្របគ្នាជាមួយកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ដែរ

ឬយ៉ាងណា ហើយថា តើការបកស្រាយបែបនេះនឹងនាំឱ្យមានលទ្ធផលមួយ«ដែលពុំសមហេតុផលនិងមិនមានភាពស៊ីសង្វាក់គ្នាយ៉ាងច្បាស់ក្រឡែត» ដែរឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា យុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. គ្របដណ្តប់លើកម្មាភិបាលខ្មែរក្រហម ហើយបញ្ហាចោទដែលថា តើជនជាប់ចោទ គឺជាកម្មាភិបាលខ្មែរក្រហមដែរឬយ៉ាងណានោះគឺជាបញ្ហាដែលអាចវិនិច្ឆ័យបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ទោះបីជាយ៉ាងណាក៏ដោយ ពាក្យពេចន៍«ទទួលខុសត្រូវខ្ពស់បំផុត»មិនអាចជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការនោះទេដោយសារមូលហេតុជាច្រើនរួមមាន៖ សញ្ញាណនៃការទទួលខុសត្រូវដែលយកមកប្រៀបធៀបពុំមានលក្ខណៈស្របទៅនឹងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដែលហាមឃាត់មិនឱ្យប្រើប្រាស់មធ្យោបាយការពារខ្លួនដោយយកមូលហេតុបញ្ជាថ្នាក់លើ។ ការកំណត់ថា តើជនជាប់ចោទជា«ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត» ដែរឬយ៉ាងណានោះ តម្រូវឱ្យមានការប្រើឆន្ទានុសិទ្ធិយ៉ាងច្រើន។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពាក្យពេចន៍«ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត»គប្បីបកស្រាយថា មិនមែនជាបញ្ហាដែលអាចធ្វើការវិនិច្ឆ័យបាននោះទេ ប៉ុន្តែជាគោលការណ៍ណែនាំដល់សហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេត ក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួនទាក់ទងនឹងវិសាលភាពនៃការចោទប្រកាន់និងការស៊ើបអង្កេត។ ចំពោះពាក្យពេចន៍«មេដឹកនាំជាន់ខ្ពស់» អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញផងដែរថា ពាក្យពេចន៍នេះមិនមែនជាកម្មវត្ថុដែលអាចធ្វើការវិនិច្ឆ័យបានទេ ប៉ុន្តែជាគោលការណ៍ណែនាំ ជាជាងលក្ខខណ្ឌតម្រូវយុត្តាធិការដោយសារមានហេតុផលផ្សេងៗ ចំពោះភាពបទបែនក្នុងការកំណត់និយមន័យនៃពាក្យនេះ។ ប្រសិនបើមិនមានភស្តុតាងបញ្ជាក់ថា ការប្រើឆន្ទានុសិទ្ធិនេះត្រូវបានធ្វើឡើងដោយអសុទ្ធចិត្តឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈនោះទេ អង្គជំនុំជម្រះសាលាដំបូងពុំមានអំណាចពិនិត្យឡើងវិញអំពីបញ្ហារំលោភឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតឡើយ ដោយអនុលោមតាមមាត្រា ៥(៣) និងមាត្រា ៦(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងគោលបំណងនៃការចោទប្រកាន់និងការស៊ើបអង្កេត។ ចំពោះបញ្ហាថា តើជនជាប់ចោទគឺជាមេដឹកនាំជាន់ខ្ពស់មួយរូបឬជាជនមួយរូបក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដែរឬយ៉ាងណានោះ គឺជាសេចក្តីសម្រេចផ្នែកគោលការណ៍ណែនាំសម្រាប់សហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតដែលជាអ្នកទទួលខុសត្រូវ ហើយពុំមែនជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះឡើយ។ អាស្រ័យហេតុនេះ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទទាក់ទងនឹងយុត្តាធិការលើរូបបុគ្គល ត្រូវបដិសេធចោលទាំងស្រុង។

## គ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### ក. គោលការណ៍នីត្យានុកូលភាព

១១. សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ជាច្រើនចំណុចចំពោះការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានចោទប្រកាន់លើជនជាប់ចោទ ដោយអនុលោមតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

១២. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ដើម្បីដោះស្រាយទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងនេះ អង្គជំនុំជម្រះត្រូវតែពិចារណាអំពីយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក. ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងលើបទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ និងការធ្វើទុក្ខបុកម្នេញ។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងថា ដើម្បីឱ្យបទល្មើសដែលត្រូវបានចោទប្រកាន់ និងទម្រង់នៃការចូលរួមស្ថិតនៅក្នុងយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក. បទល្មើស និងទម្រង់នៃការចូលរួមទាំងនោះត្រូវតែមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដោយច្បាស់លាស់ឬដោយប្រយោល។ បន្ថែមពីលើនេះ ដោយសារតែច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវបានអនុម័តក្រោយការប្រព្រឹត្តអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ដូចនេះអំពើឧក្រិដ្ឋទាំងនោះត្រូវតែពិចារណាដោយផ្អែកលើគោលការណ៍ គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege/គោលការណ៍នីត្យានុកូលភាព)។ អនុលោមតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ រាល់បទល្មើសឬរាល់ទម្រង់នៃការទទួលខុសត្រូវដែលចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក. ត្រូវតែមានអត្ថិភាពក្រោមច្បាប់ជាតិឬច្បាប់អន្តរជាតិ នៅពេលដែលអំពើល្មើសដែលបានចោទប្រកាន់នោះបានកើតឡើងនៅក្នុងអំឡុងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ បន្ថែមពីលើនេះ ជនជាប់ចោទត្រូវតែអាចយល់ដឹងជាមុនថាជាបទល្មើស និងដឹងជាមុនថាមានច្បាប់ចែង។

### ខ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចន្លោះពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩

១៣. ទាក់ទងនឹងយុត្តាធិការរបស់ អ.វ.ត.ក. ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យមើលឡើងវិញអំពីដំណើរការវិវឌ្ឍនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់អន្តរជាតិ ដោយចាប់ផ្តើមពីសញ្ញាណដំបូងទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងទសវត្សរ៍ ១៦០០ និងតាមលំនាំនៃការអនុវត្តតៗគ្នារបស់រដ្ឋ និងការប្រកាសពីឆន្ទៈទទួលយកជាច្បាប់ (opinion juris) ក្រោយសង្គ្រាមលោកលើកទី I និងក្រោយសង្គ្រាមលោកលើកទី II។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាឧក្រិដ្ឋកម្មអន្តរជាតិក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក.។ បន្ថែមពីលើនេះអង្គជំនុំជម្រះសាលាដំបូងសម្រេចថា និយមន័យទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងគោលការណ៍ Nuremberg ឆ្នាំ១៩៥០ ឆ្លុះបញ្ចាំងឱ្យឃើញពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលនោះ។ នៅពេលពិចារណាអំពីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវសម្រេច ថាតើនិយមន័យនោះមានចែងនៅក្នុងច្បាប់អន្តរជាតិចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ដែរឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលនឹងបន្តសម្រេចទៅលើបទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## គ. ការធ្វើឱ្យទៅជាទាសករ

១៤. ចំពោះការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយមិនបានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទធ្វើឱ្យទៅជាទាសករចំពោះអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១។ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសបែបនេះ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យមានធាតុផ្សំនៃពលកម្មដោយបង្ខំ នៅក្នុងនិយមន័យនៃការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

១៥. អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង ពុំបានកំណត់អំពីការធ្វើពលកម្មដោយបង្ខំថា ជាធាតុផ្សំចាំបាច់មួយនៅក្នុងនិយមន័យនៃការធ្វើឱ្យទៅជាទាសករនោះឡើយ។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ការធ្វើពលកម្មដោយបង្ខំគ្រាន់តែជាកត្តាមួយ ដែលត្រូវយកមកពិចារណាតែប៉ុណ្ណោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងរបស់សហព្រះរាជអាជ្ញាលើបញ្ហានេះពុំមានមូលដ្ឋានត្រឹមត្រូវនោះទេ។

១៦. ទោះបីជាយ៉ាងណាក៏ដោយ ផ្អែកតាមការពិចារណាលើនិយមន័យនៃទាសភាពតាមអនុសញ្ញាស្ដីពីទាសភាពឆ្នាំ ១៩២៦ និងការពិចារណាលើការវិនិច្ឆ័យពីអំពើធ្វើឱ្យទៅជាទាសករដែលជាបទឧក្រិដ្ឋនៅ ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនបានបញ្ជាក់ឱ្យបានច្បាស់អំពីនិយមន័យជាធរមាននៃអំពើធ្វើឱ្យទៅជាទាសករនោះទេ។ និយមន័យនៃអំពើធ្វើឱ្យទៅជាទាសករនៅ ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ គឺជា ១) ការប្រើប្រាស់អំណាចក្នុងនាមជាម្ចាស់ (ធាតុផ្សំសត្យានុម័ត) (actus reus) និង ២) ចេតនាក្នុងការបង្កើនផលចំណេញ តាមរយៈការប្រើប្រាស់អំណាចក្នុងនាមជាម្ចាស់ (ធាតុផ្សំអត្តនោម័ត) (mens rea)។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជនជាប់ចោទអាចយល់ដឹងជាមុន និងអាចដឹងថា មានច្បាប់ចែងអំពីនិយមន័យនេះ។

១៧. នៅពេលយកនិយមន័យនៃការធ្វើឱ្យទៅជាទាសករ ដែលមានលក្ខណៈច្បាស់លាស់មកអនុវត្តចំពោះ សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការប្រព្រឹត្តលើអ្នកជាប់ឃុំឃាំងនៅ មន្ទីរស-២១ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានភស្តុតាងបង្ហាញអំពីចេតនារបស់ជនជាប់ចោទនៅក្នុងការទទួលផលចំណេញសម្រាប់ខ្លួន ពីអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១ នោះទេ ឬភស្តុតាងបង្ហាញពីការចាត់ទុកអ្នកជាប់ឃុំឃាំងទាំងអស់នោះជាទំនិញនោះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង មិនមានកំហុសក្នុងការកម្រិតសំអាងហេតុរបស់ខ្លួននៃការធ្វើឱ្យទៅជាទាសករ ចំពោះតែអ្នកជាប់ឃុំឃាំងដែលបានទទួលរងនូវពលកម្មដោយបង្ខំនោះឡើយ។ ដោយផ្អែកតាមមូលដ្ឋាននេះ ត្រូវបដិសេធចោលនូវទឡ្ហីករណ៍ទី៣ នៃបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

## ឃ. ការធ្វើទារុណកម្ម និងការរំលោភលើផ្លូវភេទ

១៨. សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល សម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទរំលោភលើផ្លូវភេទ និងបទធ្វើទារុណកម្ម នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាបទល្មើសត្រួតគ្នា។

១៩. ដោយសារពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់ចំពោះអត្ថិភាពនៃការរំលោភលើផ្លូវភេទដែលជាបទឧក្រិដ្ឋមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្ថិតក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក. អង្គជំនុំជម្រះតុលាការ

កំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសន្និដ្ឋានថា ហេតុការណ៍ដែលបានកើតឡើងនៅមន្ទីរស-២១ គឺជាការរំលោភលើផ្លូវភេទដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អាស្រ័យហេតុនេះ ការលើកឡើងផ្នែកនេះនៅក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ត្រូវបដិសេធចោលជាស្វ័យប្រវត្តិ។

២០. ជាបន្ត អង្គជំនុំជម្រះតុលាការកំពូលនឹងសម្រេច ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដែរឬយ៉ាងណាក្នុងការយល់ឃើញថា អំពើរំលោភលើផ្លូវភេទអាចចាត់ជាអំពើធ្វើទារុណកម្មនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក. នោះ។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ទាក់ទងនឹងធាតុផ្សំសត្យានុម័តនៃអំពើធ្វើទារុណកម្ម«អំពើមួយចំនួនត្រូវបានចាត់ទុកថា ជាអំពើដែលនឹងនាំឱ្យមានការឈឺចាប់និងរងទុក្ខធ្ងន់ធ្ងរ ដោយផ្អែកលើចរិតនៃអំពើទាំងនោះ។ អំពើទាំងនោះរួមមាន ការរំលោភលើផ្លូវភេទ [...]»។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របនិងយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសនោះទេ ក្នុងការស្រូបបញ្ចូលអំពើរំលោភលើផ្លូវភេទទៅក្នុងនិយមន័យនៃអំពើធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

២១. ទាក់ទងនឹងគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មានការបង្ហាញយ៉ាងច្បាស់ថា អំពើធ្វើទារុណកម្មគឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិជាសារវន្តរបស់បុគ្គលនៅពេលដែលជនជាប់ចោទប្រព្រឹត្តអំពើឧក្រិដ្ឋនេះ។ ការទទួលស្គាល់យ៉ាងទូលំទូលាយដោយបណ្តាសហគមន៍ប្រជាជាតិនានាអំពីស្ថានទម្ងន់នៃអំពើធ្វើទារុណកម្ម បានបង្ហាញពីភាពអាចយល់ដឹងជាមុនអំពីបទល្មើសព្រហ្មទណ្ឌដែលបានចោទប្រកាន់ចំពោះអំពើបែបនេះថា ជាបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## ង. ការធ្វើទុក្ខបុកម្នេញ

២២. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការធ្វើទុក្ខបុកម្នេញគឺជាបទល្មើសដែលត្រូវបានទទួលស្គាល់ថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥។ អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងថា លក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័ត គឺជាការប្រព្រឹត្តអំពើសកម្ម ឬអកម្ម«ដោយមានចេតនា» ក្នុងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា។ បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា មតិភាគច្រើនរបស់អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសនោះទេ នៅក្នុង

ការអនុវត្តជាតុផ្សំអត្តនោម័ត ចាំបាច់ចំពោះការធ្វើទុក្ខបុកម្នេញ ដើម្បីសម្រេចថាជនជាប់ចោទបានបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃជាតុផ្សំអត្តនោម័តនៅក្នុងរឿងក្តីនេះ។

២៣. អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយ អង្គជំនុំជម្រះសាលាដំបូងថា ចំណុចទីមួយនៃជាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញគឺថា ជាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញបង្កើតបានជាអំពើសកម្មឬអកម្ម ដែលដកហូតឬរំលោភទៅលើសិទ្ធិជាសារវន្តដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឬច្បាប់សន្ធិសញ្ញា។ ចំណុចសំខាន់បំផុតនៃការវិភាគនោះ ឋិតនៅលើការកំណត់ថា តើអំពើសកម្ម ឬអកម្មនេះ នៅពេលដែលពិចារណាជារួម និងតាមបរិបទ មានភាពធ្ងន់ធ្ងរ ឬស្ថានទម្ងន់ស្មើគ្នាទៅនឹងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬយ៉ាងណា ដែលនាំឱ្យមានការរំលោភលើសិទ្ធិជាសារវន្ត ដោយកំរោលឬឥតលាក់លៀម។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របផងដែរ ទៅនឹងចំណុចទីពីរនៃការកំណត់និយមន័យជាតុផ្សំសត្យានុម័ត ដោយអង្គជំនុំជម្រះសាលាដំបូងដែលថា អំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញត្រូវតែ«មានការរើសអើងជាក់ស្តែង» ទើបនាំឱ្យមានផលវិបាកដែលមានលក្ខណៈរើសអើសជាក់ស្តែង។

២៤. ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដែរឬយ៉ាងណា ចំពោះការសន្និដ្ឋានផ្នែកអង្គហេតុដែលថា អ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១ បានក្លាយជាជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញ ដោយសារអ្នកជាប់ឃុំឃាំងទាំងនេះត្រូវបានកំណត់ជាគោលដៅដោយមូលហេតុនយោបាយ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ក្នុងអំឡុងពេលនៃរបបគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាមានក្រុមមនុស្សខុសៗគ្នា ត្រូវបានកំណត់ជាគោលដៅថាជាខ្មាំងនយោបាយពិតប្រាកដឬដោយសន្មត ហើយត្រូវបានឃុំឃាំងនៅមន្ទីរ ស-២១ ក្រោមលក្ខណៈវិនិច្ឆ័យផ្សេងៗដែលបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជា។ ខណៈពេលដែលបដិវត្តកំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួនត្រូវបានធ្វើបាប និងត្រូវបានបោសសម្អាតដោយមិនរើសមុខ និងដោយគ្មានការធ្វើយុត្តិកម្មដ៏សមហេតុផល ដោយមូលហេតុនយោបាយនោះទេ។ សកម្មភាពបែបនេះមិនមែនជាការធ្វើទុក្ខបុកម្នេញតទៅទៀតនោះទេ ប៉ុន្តែបង្កើតឱ្យមានការភ័យខ្លាចដែលពុំមានលក្ខណៈវិនិច្ឆ័យដែលស្តែងឱ្យឃើញក្នុងការកំណត់គោលដៅលើជនរងគ្រោះឡើយ។ ជនជាប់ចោទទទួលខុសត្រូវលើការឃុំខ្លួន ការសួរចម្លើយ ការធ្វើទារុណកម្ម ការធ្វើឱ្យទៅជាទាសករ និងការសម្លាប់បុគ្គលជាច្រើន ដែលមិនមែនជាខ្មាំងនយោបាយនោះទេ។

ទាក់ទងនឹងជនទាំងនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជនរងគ្រោះទាំងនោះមិនស្ថិតនៅក្នុងសញ្ញាណនៃការធ្វើទុក្ខបុកម្នេញនោះទេ។

## ច. ការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា

២៥. សហព្រះរាជអាជ្ញាអះអាងថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយធ្វើការស្រូបបញ្ចូលនូវរាល់បទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញ ជំនួសឱ្យការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីរាល់បទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។

២៦. អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា នៅក្នុងការពិចារណាលើបញ្ហាដាក់ពិរុទ្ធភាពពីបទល្មើស ច្រើន អង្គជំនុំជម្រះសាលាដំបូងយល់ឃើញត្រឹមត្រូវក្នុងការជ្រើសរើសនូវលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី Čelebići ដែលមានបញ្ជាក់យ៉ាងលម្អិតនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ក្នុងការយកលក្ខណៈវិនិច្ឆ័យនេះមកអនុវត្តចំពោះការធ្វើទុក្ខបុកម្នេញ ព្រមទាំងចំពោះបទឧក្រិដ្ឋដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គជំនុំជម្រះនេះយល់ឃើញថា នៅពេលវិភាគអំពីការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសច្រើន គឺត្រូវធ្វើការប្រៀបធៀបជាមួយជាតុផ្សំនីត្យានុកូលអរូបិយនៃបទល្មើសជាជាងប្រៀបធៀបកាលៈទេសៈនៃអង្គហេតុដែលកើតឡើងជុំវិញអំពើជាមូលដ្ឋាន។ អង្គជំនុំជម្រះសាលាដំបូង ពុំបានផ្តោតការវិភាគរបស់ខ្លួនឱ្យបានត្រឹមត្រូវទៅលើការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសច្រើនចំពោះអំពើដែលជាមូលដ្ឋាននៃបទចោទ ជាជាងផ្តោតទៅលើជាតុផ្សំនៃការកំណត់និយមន័យតាមផ្លូវច្បាប់នៃបទល្មើសដែលខ្លួនយល់ឃើញថាអាចអនុវត្តបាន។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងពុំបានសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសច្រើនចំពោះអំពើធ្វើទុក្ខបុកម្នេញ និងចំពោះបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនជាប់ចោទមានការទទួលខុសត្រូវ នោះទេ។

២៧. ហេតុដូច្នេះ ទទួលយកផ្នែកខ្លះនៃទឡ្ហីករណ៍ទីពីរនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។ បន្ថែមពីលើការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះមានការសម្រេចដាក់ពិរុទ្ធភាពដាច់ដោយឡែកផ្សេងទៀតដែលត្រូវបានធ្វើឡើង ចំពោះការសម្លាប់រង្គាល(ដោយរួមបញ្ចូលការធ្វើមនុស្សឃាត) ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត។

## ឃ. ការប្រកាសទោស

២៨. មេធាវីការពារក្ដីអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសម្រេចផ្ដន្ទាទោសពុំបានសមស្រប ដោយសារការខកខានក្នុងការពិចារណាទៅលើមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ដែលចែងថា កាលណាបទល្មើសត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្ដល់«ស្ថានសម្រាលទោសអាចប្រកាសទោសដាក់ពន្ធនាគារក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ»។ មេធាវីការពារក្ដីអះអាងថា នៅ អ.វ.ត.ក. អាចអនុញ្ញាតឱ្យមានការកំណត់ទោសរយៈពេល ៣០ (សាមសិប) ឆ្នាំ គឺជាការផ្ដន្ទាទោសដែលមានរយៈពេលកំណត់អតិបរមា។

២៩. សហព្រះរាជអាជ្ញាអះអាងតបថា មាត្រា៣៩ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ចែងអំពីរយៈពេល នៃទោសជាប់ពន្ធនាគារ «ពី ០៥ (ប្រាំ) ឆ្នាំ រហូតដល់មួយជីវិត» និងថា យោងតាមមាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ត្រូវមានអាទិភាពជាងច្បាប់ព្រហ្មទណ្ឌជាតិក្នុងករណីដែលមានទំនាស់គ្នា។

៣០. ដោយពិចារណាទៅលើពាក្យពេចន៍ និងខ្លឹមសារនៃមាត្រា ៨ និងមាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩ អង្គជំនុំជម្រះតុលាការកំពូលយល់ស្រប ជាមួយនឹងសហព្រះរាជអាជ្ញាដែលថា ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. គឺជា «ច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស»យោងតាមអត្ថន័យនៃមាត្រា៦៦៨(៣) នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។ ហេតុដូច្នេះបទប្បញ្ញត្តិនៃគន្ថីទី១ (បទប្បញ្ញត្តិទូទៅ) នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មិនមានអាទិភាពជាងបទប្បញ្ញត្តិណាមួយនៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក. ក្នុងករណីដែលមានទំនាស់រវាងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ និងច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក. នោះទេ។ ហេតុដូច្នេះកម្រិតនៃទណ្ឌកម្មនៅ អ.វ.ត.ក. អាចស្ថិតនៅចន្លោះណាមួយរវាងទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ រហូតដល់ទោសអស់មួយជីវិត ដូចមានចែងនៅក្នុងមាត្រា៣៩ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។

៣១. យោងតាមសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលទឡ្ហីករណ៍ទី២ នៃបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ត្រង់ចំណុចប្រឆាំងនឹងការផ្ដន្ទាទោស។

៣២. សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការផ្ដន្ទាទោសដែលមានកម្រិតស្រាលពេក។ យោងតាមការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងក្នុងចំណោមកត្តាស្ថានសម្រាលទោសទាំងបួន មានកត្តាស្ថានសម្រាលទោសចំនួនពីរដែលមានអានុភាព«តិចតួច» ប៉ុណ្ណោះ រីឯអានុភាពនៃកត្តាស្ថានសម្រាលទោសទីបី «ត្រូវបានកាត់បន្ថយ» និង«ស្ទើរតែមិនមាន»។ ប៉ុន្តែ នៅក្នុងផ្នែកក្រោយទៀតនៃសាលក្រម

របស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបែរជាបានរៀបរាប់អំពីកត្តាស្ថានសម្រាលទោសទាំងបួនថា ជាកត្តាដែល«មានសារៈសំខាន់»ទៅវិញ ដោយមិនមានការពន្យល់អ្វីនោះទេ។

៣៣. ទោះបីជាអង្គជំនុំជម្រះសាលាដំបូង មានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយក្នុងការកំណត់អំពីទម្ងន់នៃកត្តាស្ថានសម្រាលទោសក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ឥទ្ធិពលដែលកើតចេញពីការប្រើប្រាស់កត្តាស្ថានសម្រាលទោសក្នុងការប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ស្ថានសម្រាលទោសទាំងនោះមានឥទ្ធិពលបន្តិចបន្តួចប៉ុណ្ណោះ។ លើសពីនេះទៀត ស្ថានទម្ងន់ទោសនិងស្ថានទម្ងន់ដ៏ពិសេសនៃឧក្រិដ្ឋកម្មបានធ្វើឱ្យបាត់បង់ឥទ្ធិពលនៃស្ថានសម្រាលទោសទាំងនេះ។

៣៤. ទម្ងន់តិចតួចនៃកត្តាស្ថានសម្រាលទោសនៅក្នុងរឿងក្ដីបច្ចុប្បន្ននេះ មានលក្ខណៈគ្រប់គ្រាន់ដើម្បីធ្វើការបដិសេធនូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាកត្តាស្ថានសម្រាលទោសទាំងនេះមាន«សារៈសំខាន់» «តម្រូវឱ្យមាន» ការប្រកាសទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ ដោយមិនបានយោងលើសំអាងផ្លូវច្បាប់ណាមួយនោះ។ អង្គជំនុំជម្រះសាលាដំបូងថែមទាំងមិនបានពិចារណាលើច្បាប់ជាតិ និងអន្តរជាតិដែលបានអនុញ្ញាតឱ្យមានការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត ទោះបីជាមានកត្តាស្ថានសម្រាលទោសក៏ដោយ ហេតុដូច្នេះ អាចសន្មតបានថា អង្គជំនុំជម្រះសាលាដំបូងមិនបានផ្ដល់នូវទម្ងន់ណាមួយទៅលើច្បាប់ជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធទាំងនោះទេ។

៣៥. អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា អង្គជំនុំជម្រះសាលាដំបូង បានផ្ដល់ទម្ងន់មិនសមហេតុផលចំពោះស្ថានសម្រាលទោស និងមិនបានផ្ដល់ទម្ងន់ឱ្យបានគ្រប់គ្រាន់ចំពោះស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងស្ថានទម្ងន់ទោស ។ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងនេះ គឺជាកំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈការប្រកាសទោសនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវអន្តរាគមជាចាំបាច់ ដើម្បីធ្វើការប្រកាសទោសមួយដ៏សមស្រប។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលទទួលយកទឡ្ហីករណ៍ទីមួយនៃបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

៣៦. ដោយសារតែមិនមានយុត្តិសាស្ត្រប្រហាក់ប្រហែលគ្នានៅតុលាការកម្ពុជានោះ ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការពិនិត្យទៅលើការប្រកាសទោសរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗ ទៀតដែលដោះស្រាយបញ្ហាអង្គហេតុ និងអង្គច្បាប់ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះ។

៣៧. នៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិជាច្រើនបានបង្ហាញយ៉ាងច្បាស់ថា ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មរបស់ពិរុទ្ធជនគឺជាកត្តាចំបងនៅក្នុងការប្រកាសទោស។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមថា តុលាការមិនអចិន្ត្រៃយ៍ ភាគច្រើនបានសម្រេចប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះរឿងក្តី ដែលជនជាប់ចោទបានរំលោភបំពានលើមុខដំណែងដឹកនាំ តាមរយៈការរៀបចំផែនការ ឬការបញ្ជាឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ព្រមទាំងរឿងក្តីនានាដែលមានភស្តុតាងបង្ហាញថា ពិរុទ្ធជនរូបនេះធ្វើអំពើឃោរឃៅឬបានបំពេញភារកិច្ចរបស់ខ្លួនដោយពេញចិត្ត។ ហេតុដូច្នេះ ដើម្បីធ្វើការប្រកាសទោសឱ្យបានសមស្រប អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ព្រមទាំងកត្តាស្ថានទម្ងន់ទោសនានាដូចជា តួនាទីដឹកនាំរបស់ កាំង ហ្គេកអ៊ាវ និងការប្រព្រឹត្តឧក្រិដ្ឋកម្មដោយភាពឃោរឃៅ និងពេញចិត្ត។

៣៨. នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ឧក្រិដ្ឋកម្មដែល កាំង ហ្គេក អ៊ាវ បានប្រព្រឹត្ត គឺមាន«លក្ខណៈសាហាវយង់ឃ្នង និងគួរឱ្យព្រឺខ្លាច» ដោយផ្អែកតាមចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់មិនតិចជាង ១២.២៧២ នាក់ ព្រមទាំងការធ្វើទារុណកម្មជាប្រព័ន្ធ និងស្ថានភាពអាក្រក់ទូទៅដែលជនរងគ្រោះទទួលរងថែមទៀតផង។ ចំនួនអ្នកស្លាប់យ៉ាងច្រើនដែល កាំង ហ្គេក អ៊ាវ ជាអ្នកទទួលខុសត្រូវរួមជាមួយនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈពេលដ៏វែង (លើសពី ៣ឆ្នាំ) គឺពិតជាធ្វើឱ្យសំណុំរឿងនេះជាសំណុំរឿងមួយដែលមានលក្ខណៈធ្ងន់ធ្ងរជាងគេបំផុតនៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា។

៣៩. ពាក់ព័ន្ធនឹងកត្តាស្ថានទម្ងន់ទោស កាំង ហ្គេកអ៊ាវ មានតួនាទីជាមេដឹកនាំធំជាងគេនៅមន្ទីរ ស-២១ ហើយជនជាប់ចោទបានបំពានតួនាទីរបស់ខ្លួន ដោយបានបង្ហាត់បង្រៀន បញ្ជា និងគ្រប់គ្រងទៅលើបុគ្គលិកក្នុងការធ្វើទារុណកម្មជាប្រព័ន្ធ និងការសម្លាប់អ្នកជាប់ឃុំឃាំងដែលត្រូវបានចាត់ទុកថា ជាសត្រូវរបស់របបកម្ពុជាប្រជាធិបតេយ្យ ដោយបង្ហាញពី«ការខិតខំប្រឹងប្រែងបំពេញភារកិច្ចដើម្បីធ្វើឱ្យមន្ទីរស-២១ ដំណើរការទៅបានយ៉ាងរលូន»។ ជាការពិតដែលថា កាំង ហ្គេកអ៊ាវ មិនមែនជាជនកំពូលនៅក្នុងខ្សែសង្វាក់បញ្ជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចធ្វើជាយុត្តិកម្មសម្រាប់ការផ្តន្ទាទោសស្រាលជាងនោះទេ។ ជាការពិត ពុំមានវិធានណាមួយដែលតម្រូវឱ្យផ្តន្ទាទោសខ្ពស់បំផុតចំពោះតារីដែលជាជនកំពូលនៃខ្សែសង្វាក់បញ្ជានោះទេ។ ការផ្តន្ទាទោស កាំង ហ្គេកអ៊ាវ ត្រូវតែមានលក្ខណៈសមស្របទៅនឹងឧក្រិដ្ឋកម្មដែលខ្លួនគាត់បានប្រព្រឹត្តដោយមិនគិតថាតើមានមេដឹកនាំខ្ពស់ជាងជនជាប់ចោទបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរជាង ដែរឬយ៉ាងណានោះទេ។

៤០. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា តួនាទីដឹកនាំរបស់ កាំង ហ្កេកអ៊ាវ និងការពេញចិត្តយ៉ាងខ្លាំងក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយ គឺស្ថានទម្ងន់ទោសដែលផ្តល់ទម្ងន់គ្រប់គ្រាន់ក្នុងការប្រកាសទោសលើជនជាប់ចោទ។

៤១. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដោយសារស្ថានទម្ងន់នៃឧក្រិដ្ឋកម្មរបស់ កាំង ហ្កេកអ៊ាវ ការដាក់ទោសដែលសមនឹងទទួល និងការធ្វើឱ្យរាងចាល គឺជាគោលបំណងសំខាន់នៅក្នុងរឿងក្តីនេះ។ ការដាក់ទណ្ឌកម្មត្រូវតែមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង និងរារាំងមិនឱ្យឧក្រិដ្ឋកម្មដូចគ្នានេះកើតឡើងម្តងទៀត។ ឧក្រិដ្ឋកម្មដែល កាំង ហ្កេកអ៊ាវ បានប្រព្រឹត្តក្នុងរឿងក្តីនេះ គឺពិតជាឧក្រិដ្ឋកម្មមួយនៅក្នុងចំណោមឧក្រិដ្ឋកម្មដ៏អាក្រក់បំផុតនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។ ឧក្រិដ្ឋកម្មទាំងនេះសមនឹងទទួលនូវទណ្ឌកម្មធ្ងន់ធ្ងរបំផុត ដើម្បីជាការឆ្លើយតបប្រកបដោយយុត្តិធម៌ និងគ្រប់គ្រាន់ចំពោះអំពើសាហាវឃោរឃៅដែលឧក្រិដ្ឋកម្មទាំងនោះបង្កឡើងទៅលើជនរងគ្រោះ ក្រុមគ្រួសារ និងសាច់ញាតិ ក៏ដូចជាប្រជាជនកម្ពុជានិងមនុស្សជាតិទាំងមូល។

៤២. សហព្រះរាជអាជ្ញាមិនបានបំផ្លើសឡើយ នៅពេលដែលសហព្រះរាជអាជ្ញាបានសំដៅទៅលើមន្ទីរស-២១ ថា ជា«ទីកន្លែងសម្លាប់មនុស្សដ៏ធំដោយមានការរៀបចំ»។ កាំង ហ្កេកអ៊ាវ បានបញ្ជានិងបានប្រតិបត្តិការទីកន្លែងសម្លាប់មនុស្សនេះអស់រយៈពេលជាងបីឆ្នាំ។ កាំង ហ្កេកអ៊ាវ ជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់មនុស្សមិនតិចជាង ១២.២៧២ នាក់ដោយគ្មានធម៌មេត្តា ដែលក្នុងនោះរួមមានស្ត្រីនិងកុមារផងដែរ។

៤៣. ទោះបីជាឧក្រិដ្ឋកម្មទាំងឡាយបានកើតឡើងជាង ៣០ ឆ្នាំហើយក៏ដោយ ក៏ការកន្លងផុតដ៏យូរនេះមិនអាចសម្រាលភាពចាំបាច់ក្នុងការដាក់ទណ្ឌកម្មធ្ងន់ធ្ងរបាននោះទេ។ ការឈឺចាប់របស់ជនរងគ្រោះ ព្រមទាំងក្រុមគ្រួសារ និងសាច់ញាតិ គឺមិនត្រឹមតែជារឿងអតីតកាលប៉ុណ្ណោះទេ ក៏ប៉ុន្តែការឈឺចាប់អស់ទាំងនេះបានបន្តនិងនៅតែបន្តរហូតអស់មួយជីវិត។ ឧក្រិដ្ឋកម្មរបស់ កាំង ហ្កេកអ៊ាវ គឺជាបញ្ហាប្រឈមសម្រាប់មនុស្សជាតិទាំងមូល និងជាពិសេសសម្រាប់ប្រជាជនកម្ពុជា ដែលបង្កឱ្យមានការឈឺចាប់ដែលមិនអាចព្យាបាលជាសះស្បើយបាន។ ប្រជាជនកម្ពុជានៅតែប្រឈមមុខជាមួយបញ្ហាដែលមិនធ្លាប់ជួបប្រទះ ក្នុងការធ្វើឱ្យធូរស្បើយពីសោកនាដកម្មដែលបណ្តាលមកពីឧក្រិដ្ឋកម្មដែល កាំង ហ្កេកអ៊ាវ បានប្រព្រឹត្ត។

៤៤. យោងតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ការប្រកាសទោសដាក់ពន្ធនាគាររយៈពេល ៣៥ (សាមសិបប្រាំ)ឆ្នាំ ដោយអង្គជំនុំជម្រះសាលាដំបូងមិនបានឆ្លុះបញ្ចាំងឱ្យបានសមរម្យទៅនឹងស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងស្ថានភាពបុគ្គល

របស់ កាំង ហ្កេកអ៊ាវ ឡើយ។ អង្គជំនុំជម្រះសាលាដំបូង ពិតជាមានកំហុសក្នុងការប្រកាសទោសដែលមានលក្ខណៈមិនគ្រប់គ្រាន់យ៉ាងច្បាស់ក្រឡែត។ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលសម្រេចប្រកាសទោសដាក់ពន្ធនាគារ កាំង ហ្កេកអ៊ាវ អស់មួយជីវិត។

៤៥. ការដោះលែងដោយមានលក្ខខណ្ឌ គឺជានីតិវិធីដាច់ដោយឡែកមួយ នៅក្នុងដំណាក់កាលនៃការអនុវត្តទោសពន្ធនាគារ។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ភាពកង្វះបទប្បញ្ញត្តិពិសេសស្តីពីការដោះលែងដោយមានលក្ខខណ្ឌនៅក្នុងឯកសារផ្លូវច្បាប់នានារបស់ អ.វ.ត.ក. បង្ហាញឱ្យឃើញថា បញ្ហានេះគួរត្រូវបានដោះស្រាយទៅតាមនីតិវិធីក្នុងស្រុកជាធរមាន នាពេលដែលការដោះលែងដោយមានលក្ខខណ្ឌនេះ ត្រូវបានលើកមកពិចារណា។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ខ្លួនមិនមានសមត្ថកិច្ចសម្រេចអំពីសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ក្នុងការទទួលបានការដោះលែងដោយមានលក្ខខណ្ឌនោះទេ។

៤៦. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការកាត់បន្ថយទោសចំនួន ៥ (ប្រាំ)ឆ្នាំ និងការគិតបញ្ចូលរយៈពេលដែលបានជាប់ឃុំក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា គឺជាការផ្តល់សំណងសមរម្យចំពោះការរំលោភលើសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ដោយសារការឃុំខ្លួនខុសច្បាប់នីតិវិធីដោយតុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។

៤៧. អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ច្បាប់ដែលអាចយកមកអនុវត្តបាននៅ អ.វ.ត.ក. រួមទាំងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិមិនបានបង្ហាញថា ការរំលោភសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ គួរត្រូវបានទូទាត់សងដោយ អ.វ.ត.ក. ឡើយ នៅពេលដែលពុំមានភស្តុតាងបង្ហាញថា អ.វ.ត.ក. ជាអ្នករំលោភកិច្ចដំណើរការនីតិវិធី ឬជាអ្នកទទួលខុសត្រូវចំពោះការរំលោភសិទ្ធទាំងនោះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិដែលពាក់ព័ន្ធត្រង់ចំណុចដែលមានខ្លឹមសារថា ការរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទដែលបានកើតឡើងមុនការបង្កើតឱ្យមាន អ.វ.ត.ក. គប្បីត្រូវទទួលបានការទូទាត់ពី អ.វ.ត.ក. ទោះបីជាមិនមែនជាការរំលោភបំពានរបស់ អ.វ.ត.ក. និងទោះបីជាមិនមានការរំលោភលើកិច្ចដំណើរការនីតិវិធីក៏ដោយ។ ដោយពុំមានស្ថានភាពទាំងពីរនេះ អង្គជំនុំជម្រះសាលាដំបូងគួរតែបានបដិសេធសំណើសុំសំណងរបស់ជនជាប់ចោទ។

៤៨. យោងតាមហេតុផលដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា នេះមិនមែនជាករណីដែល អ.វ.ត.ក. គប្បីសម្រេចផ្តល់សំណងចំពោះការរំលោភសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ឡើយ។ ប៉ុន្តែចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe មានមតិជំទាស់ចំពោះការយល់ឃើញនេះ។ អង្គជំនុំជម្រះតុលាការ

កំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈការប្រកាសទោសក្នុងការសម្រេចកាត់បន្ថយរយៈពេលផ្តន្ទាទោសចំនួន ៥(ប្រាំ) ឆ្នាំ និងការគិតបញ្ចូលនូវរយៈពេលនៃការឃុំខ្លួន ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ដែលជាការផ្តល់សំណងសមស្របចំពោះការរំលោភសិទ្ធិកាំង ហ្កេកអ៊ាវ នោះ។ ចំពោះការយល់ឃើញនេះ ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe ក៏មានមតិជំទាស់ដែរ។

៤៩. ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe បានជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ចៅក្រមមតិភាគច្រើនដែលសម្រេចមិនផ្តល់សំណង កាំង ហ្កេកអ៊ាវ ដោយសារហេតុផលដូចខាងក្រោម។ ដោយឈរលើមូលដ្ឋានយុត្តិធម៌និងសមធម៌នៅគ្រប់កាលៈទេសៈទាំងអស់ អ.វ.ត.ក. ដែលជាតុលាការចម្រុះពិសេស គប្បីទទួលខុសត្រូវចំពោះការឃុំខ្លួនមុនអង្គសេចក្តីហួសរយៈពេលកំណត់ដោយតុលាការជាតិ។ នៅក្នុងរឿងក្តីនេះ កាលៈទេសៈទាំងនេះមានដូចតទៅៈ ទីមួយ ដោយហេតុថា អង្គជំនុំជម្រះត្រូវបានបង្កើតឡើងនៅក្នុង«រចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់» ដូច្នេះ អ.វ.ត.ក. ត្រូវបានបញ្ចូលយ៉ាងពេញលេញទៅក្នុងប្រព័ន្ធតុលាការកម្ពុជា។ ទីពីរ មានទំនាក់ទំនងយ៉ាងខ្លាំងរវាងរឿងក្តីប្រឆាំងនឹង កាំង ហ្កេកអ៊ាវ នៅ អ.វ.ត.ក. និងបទចោទនៅចំពោះមុខតុលាការយោធាកម្ពុជា។ ទាក់ទងនឹងបញ្ហានេះចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe កត់សម្គាល់ថា តុលាការយោធាបានឃុំខ្លួន កាំង ហ្កេកអ៊ាវ អស់រយៈពេល ៨ ឆ្នាំ ដែលនៅក្នុងអំឡុងពេលនោះ ពុំបានធ្វើការស៊ើបអង្កេតឱ្យបានស៊ីជម្រៅ មុននឹងផ្ទេរជនជាប់ចោទមក អ.វ.ត.ក. ភ្លាមៗ បន្ទាប់ពី អ.វ.ត.ក. ត្រូវបានបង្កើតឡើងតាមអំណាចរដ្ឋរបស់កម្ពុជា។ ទីបី ភាពធ្ងន់ធ្ងរនៃការដកហូតសិទ្ធិសេរីភាពជនជាប់ចោទ មានលក្ខណៈធ្ងន់ធ្ងរយោងតាមបទដ្ឋានអន្តរជាតិ។ អ.វ.ត.ក. ផ្តល់នូវសំណងដែលមានលក្ខណៈជាការស្តារស្ថានភាពដើមប៉ុណ្ណោះ។ ទីបួន ហេតុដូច្នេះ ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe នឹងផ្តល់សំណងដល់ កាំង ហ្កេកអ៊ាវ ដោយកាត់បន្ថយការប្រកាសទោសពីដាក់ពន្ធនាគារអស់មួយជីវិតមកត្រឹមការដាក់ពន្ធនាគារមានរយៈពេលកំណត់ ៣០ ឆ្នាំវិញ។

៥០. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា កាំង ហ្កេកអ៊ាវ មានសិទ្ធិទទួលបានការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទាំងស្រុង ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០០៧ និងនៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក. ចាប់ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ រហូតដល់ពេលសាលក្រមនេះចូលជាស្ថាពរ។ យោងតាមអង្គជំនុំជម្រះសាលាដំបូង ចំពោះរយៈពេលនៃការឃុំខ្លួនដំបូងនៅក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា ត្រូវបានផ្តល់ឱ្យជនជាប់ចោទជាផ្នែកមួយនៃការទូទាត់សំណង

សម្រាប់ការឃុំខ្លួនខុសច្បាប់ រីឯរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នបន្ទាប់ដែលស្ថិតក្រោមសមត្ថកិច្ច អ.វ.ត.ក. ត្រូវបានគិតបញ្ចូលទៅក្នុងចិរវេលានៃទោស ដោយផ្អែកតាមសិទ្ធិដែលមានចែងនៅក្នុងមាត្រា ៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។ ដោយហេតុថា ការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន សម្រាប់រយៈពេលបន្ទាប់មិនមានបញ្ហាចោទនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គប្បីឱ្យមានការពិចារណាអំពីការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន សម្រាប់រយៈពេលដំបូង។

៥១. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងថា ការចោទប្រកាន់ទាំងឡាយដែលតុលាការយោធាកម្ពុជាបានយកមកធ្វើជាសំអាងដើម្បីឃុំខ្លួនកាំង ហ្គេកអ៊ាវ គឺ«មានលក្ខណៈប្រហាក់ប្រហែលគ្នាយ៉ាងខ្លាំង»ទៅនឹងការចោទប្រកាន់ទាំងឡាយនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក.។ ដោយពិចារណាលើច្បាប់ និងការអនុវត្តកម្រិតជាតិ និងអន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលសម្រេចជាឯកច្ឆន្ទថា កាំង ហ្គេកអ៊ាវ មានសិទ្ធិទទួលបានការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នទាំងស្រុង ពោលគឺ ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ មក។ អង្គជំនុំជម្រះតុលាការកំពូល សម្រេចអនុវត្តការគិតបញ្ចូលទៅក្នុងចិរវេលានៃការផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះ កាំង ហ្គេកអ៊ាវ ដោយយល់ឃើញថា កាំងហ្គេកអ៊ាវបានទទួលរងទោសរបស់ខ្លួនអស់រយៈពេល ១២ ឆ្នាំ និង ២៦៩ ថ្ងៃរួចហើយ ដែលជារយៈពេលជននេះស្ថិតក្នុង ការឃុំខ្លួនជាបណ្ដោះអាសន្នចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ដល់ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២។

## ង. ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

៥២. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ ក្រុម ២ និងក្រុម ៣ សរុបចំនួន ២២ នាក់ បានប្ដឹងសាទុក្ខប្រឆាំងនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។

៥៣. ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានអនុម័តតាមទំនើងចិត្តនូវលក្ខណៈវិនិច្ឆ័យនៃចំណងពិសេសនៃក្ដីស្រលាញ់ ឬការរស់នៅក្នុងបន្ទុកជាមួយជនរងគ្រោះផ្ទាល់ នៅក្នុងការសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះមិនផ្ទាល់។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា លក្ខណៈវិនិច្ឆ័យនៃចំណងពិសេសនៃក្ដីស្រឡាញ់ ឬការរស់នៅក្នុងបន្ទុកដែលជាប់ទាក់ទងរវាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាមួយនឹងជនរងគ្រោះផ្ទាល់ គឺគ្រប់ដណ្ដប់ទៅលើសារៈសំខាន់នៃទំនាក់ទំនង

ផ្ទាល់ខ្លួនទៅវិញទៅមក ហើយការបំផ្លាញទំនាក់ទំនងនេះនាំឱ្យមានព្យសនកម្ម ដែលប៉ះពាល់ដល់ជនរងគ្រោះមិនផ្ទាល់។ លក្ខណៈវិនិច្ឆ័យនេះអនុវត្តចំពោះបុគ្គលគ្រប់រូបដែលបានអះអាងថា ខ្លួនជាជនរងគ្រោះមិនផ្ទាល់ ទោះបីជាសមាជិកគ្រួសារក្តី ឬមិនមែនជាសមាជិកគ្រួសារក្តី ដោយហេតុថា ប្រសិនបើមិនមានចំណងទាក់ទងពីមុន ដែលចងភ្ជាប់ម្ចាស់បណ្តឹងទាមទារសំណងតាមផ្លូវមនោសញ្ចេតនា ញាតិលោហិត ឬសេដ្ឋកិច្ច ជាមួយនឹងជនរងគ្រោះផ្ទាល់ទេនោះ ព្យសនកម្មដែលបណ្តាលមកពីការប្រព្រឹត្តបទល្មើសនេះ មិនអាចកើតមានចំពោះម្ចាស់បណ្តឹងទាំងនេះបានទេ។ ទោះបីជាពាក្យពេចន៍បែបនេះអាចត្រូវបានបង្ហាញជាលើកដំបូងនៅក្នុងសាលក្រមនេះក៏ដោយ ក៏លក្ខណៈវិនិច្ឆ័យដែលបានបញ្ជាក់ក្នុងសាលក្រមនេះ គឺជាប់ទាក់ទងទៅនឹងសញ្ញាណនៃព្យសនកម្មនៅក្នុងអត្ថន័យនៃមាត្រា១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ដែលអាចអនុវត្តចំពោះជនរងគ្រោះមិនផ្ទាល់បាន។ ហេតុដូច្នេះ ការប្រើប្រាស់លក្ខខណ្ឌតម្រូវនេះគឺត្រឹមត្រូវតាមផ្លូវច្បាប់ និងអាចយល់ដឹងជាមុនបាន ដូចគ្នាទៅនឹងលក្ខខណ្ឌតម្រូវឱ្យបង្ហាញព្យសនកម្ម ដែលត្រូវតែអាចយល់ដឹងជាមុនបានចំពោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។ អាស្រ័យហេតុនេះ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងពីកំហុសអង្គច្បាប់ និងកង្វះភាពអាចយល់ដឹងជាមុន ត្រូវបដិសេធចោលទាក់ទងទៅនឹងលក្ខណៈវិនិច្ឆ័យ។

៥៤. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ចំណងពិសេសនៃក្តីស្រឡាញ់និងការរស់នៅក្នុងបន្ទុកគឺជាឥទ្ធិពលដែលមានជាធម្មតានៅក្នុងចំណោមសមាជិកគ្រួសារជិតស្និទ្ធបំផុត។ អាស្រ័យហេតុនេះ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ជាយថាហេតុនូវសមាជិកគ្រួសារណាម្នាក់ អាចនាំឱ្យមានការឈឺចាប់ ប៉ះទង្គិចផ្លូវចិត្ត និងប្រភេទនៃព្យសនកម្មដទៃទៀតដែលកើតឡើងចំពោះសមាជិកគ្រួសារជិតស្និទ្ធបំផុត ដូចជាការបាត់បង់ផ្នែកហិរញ្ញវត្ថុជាដើម។ សេចក្តីសន្និដ្ឋាននេះមានការគាំទ្រដោយភស្តុតាងដែលមាននៅក្នុងរឿងក្តីនេះ ដោយសុភវិនិច្ឆ័យ និងដោយការយល់ឃើញដែលមានភស្តុតាងជាសំអាង អនុលោមតាមអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស និងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ហេតុដូច្នេះ គឺជាការត្រឹមត្រូវឬសមហេតុផលក្នុងការមិនដាក់បន្ទុកទៅលើគ្រួសារសាច់ញាតិផ្ទាល់ឱ្យបង្ហាញភស្តុតាងអំពីព្យសនកម្ម នៅពេលដែលនិយមន័យនៃគ្រួសារសាច់ញាតិផ្ទាល់ត្រូវបានកំណត់ច្បាស់លាស់ ហើយភាគីនានាត្រូវបានជ្រួតជ្រាបពីនិយមន័យនេះរួចហើយ។

៥៥. ទាក់ទងទៅនឹងវិសាលភាពនៃការសន្មតទុកជាមុនអំពីព្យសនកម្ម ជាការសមហេតុសមផលក្នុងការកំណត់និយមន័យនៃគ្រួសារសាច់ញាតិផ្ទាល់ ដោយគិតអំពីប្រភេទព្យសនកម្មដែលទាមទារនៅក្នុងបរិបទនៃចំណងគ្រួសារក្នុងសង្គមកម្ពុជា។ ក្នុងករណីនេះ អ្នកជំនាញមួយរូបដែលបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង បានផ្តល់

សក្ខីកម្មថា ជាទូទៅ គ្រួសារក្នុងសង្គមកម្ពុជារស់នៅជិតស្និទ្ធនឹងគ្នា និងពឹងអាស្រ័យគ្នាទៅវិញទៅមក ដែលជាទូទៅបង្កើតបានជាចំណងទាក់ទងដ៏រឹងមាំបែបនេះ។ គ្រួសារមិនមែនរាប់បញ្ចូលត្រឹមតែប្តីប្រពន្ធនិងកូនប៉ុណ្ណោះទេ ប៉ុន្តែរាប់បញ្ចូលទាំង«សមាជិកផ្សេងទៀតដែរ ដូចជា ឪពុកម្តាយចាស់ជរា» ឬ«បងប្អូនបង្កើត និងក្រុមគ្រួសាររបស់ពួកគេ» ឬ«ជីដូនជីតា បងប្អូនជីដូនមួយ និងមីងមា»។ ក្នុងកាលៈទេសៈភាគច្រើនមនុស្សដែលមានវ័យចាស់ជាងត្រូវធ្វើជាគំរូនៅក្នុងជីវិតរស់នៅសម្រាប់មនុស្សជំនាន់ក្រោយ។ ហេតុដូច្នេះ កត្តាទាំងនេះបង្កើតបានជាចំណងពិសេស និងភាពជិតស្និទ្ធបំផុត។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសញ្ញាណដ៏ទូលំទូលាយស្តីពីសមាជិកគ្រួសារសាច់ញាតិផ្ទាល់ទៅតាមព្រឹត្តិហេតុ ប៉ុន្តែក្រោយមកយល់ឃើញថា «នៅក្នុងករណីលើកលែងតែប៉ុណ្ណោះ» សមាជិកគ្រួសារដែលមិនមែនជាសាច់ញាតិផ្ទាល់ត្រូវបានចាត់ទុកថា មាន«ចំណងពិសេសនៃក្តីស្រលាញ់ ឬជាអ្នករស់នៅក្នុងបន្ទុក»ជាមួយជនរងគ្រោះផ្ទាល់។ ដោយហេតុថា សេចក្តីសន្និដ្ឋាននេះបានកំណត់និយមន័យនៃវិសាលភាពការសន្មតទុកជាមុន ក្នុងន័យចង្អៀតជាងវិសាលភាពដែលបានបញ្ជាក់អះអាងក្នុងសក្ខីកម្មរបស់អ្នកជំនាញដែលបានចាត់តាំងនោះ ដូច្នេះ សេចក្តីសន្និដ្ឋាននេះមិនបានរំលោភសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដោយហេតុថា ការបង្កើតការសន្មតទុកជាមុននេះ គឺផ្អែកលើឆន្ទានុសិទ្ធិរបស់តុលាការ មិនមែនផ្អែកលើសិទ្ធិរបស់ភាគីដើម្បីទទួលបានអត្ថប្រយោជន៍ពីការសន្មតទុកជាមុននេះទេ។

៥៦. ប្រហាក់ប្រហែលគ្នានេះដែរ ការដែលមិនបានជូនដំណឹងជាមុននោះ មិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដោយហេតុថា ដើមបណ្តឹងរដ្ឋប្បវេណីមានបន្ទុកក្នុងការបង្ហាញភស្តុតាងអំពីព្យសនកម្ម។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្អែកអង្គហេតុដែរឬយ៉ាងណា ក្នុងការសម្រេចអំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងសាទុក្ខ។

៥៧. ពាក់ព័ន្ធនឹងសេចក្តីអះអាងជាវិជ្ជមានដែលថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការទទួលយកប្រព័ន្ធនៃការពិនិត្យឡើងវិញពីរដំណាក់កាល ទៅលើភាពទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ អង្គជំនុំជម្រះតុលាការកំពូលរំឭកឡើងវិញថា វិធាន ១០០(១) នៃវិធានផ្ទៃក្នុងដែលមានអត្ថន័យដូចគ្នាទៅនឹងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ បានចែងយ៉ាងច្បាស់ថា៖ «នៅក្នុងសាលក្រមតែមួយជាមួយរឿងព្រហ្មទណ្ឌ តុលាការ [សាលាដំបូង] សម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។ តុលាការវិនិច្ឆ័យអំពីភាពអាចទទួលយកបាននៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសម្រេចអំពីពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ទៅលើជនជាប់ចោទ និងលើអ្នកទទួលខុសត្រូវរដ្ឋប្បវេណី»។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានមូលដ្ឋានផ្លូវច្បាប់ តាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក្នុងការសម្រេចអំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ នៅក្នុងសាលក្រមរបស់ខ្លួនបាន។

៥៨. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខ្លឹមសារច្បាស់លាស់នៃមាត្រា៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ និងវិធាន ១០០(១) នៃវិធានផ្ទៃក្នុង មានភាពគ្រប់គ្រាន់សម្រាប់ជាពត៌មានដល់ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីថា ពាក្យសុំរបស់ខ្លួននឹងត្រូវបានវាយតម្លៃសាជាថ្មីនៅក្នុងសាលក្រមរបស់ អង្គជំនុំជម្រះសាលាដំបូង។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងពិតជាបានផ្ដល់នូវសញ្ញាយ៉ាងទូលំទូលាយចំពោះដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសវនាការបឋម និងក្នុងអំឡុងពេលសវនាការលើអង្គសេចក្ដីថា ការវាយតម្លៃជាបឋមដោយផ្អែកលើសេចក្ដីបញ្ជាក់ដំបូងរបស់អង្គជំនុំជម្រះសាលាដំបូង លើភាពអាចទទួលយកបានជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ មិនទាន់ចាត់ទុកជាស្ថាពរនៅឡើយទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង មិនបានប្រព្រឹត្តកំហុសអង្គច្បាប់ឡើយក្នុងការវាយតម្លៃនៅក្នុងសាលក្រមរបស់ខ្លួនអំពី ថា តើភាពរងគ្រោះពិតប្រាកដ ត្រូវបានលើកបង្ហាញយ៉ាងគ្រប់គ្រាន់ នៅក្នុងដំណាក់កាលសម្រេចអំពីសំណងដែរឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានបន្ថែមទៀតថា ទោះបីមានភាពមិនច្បាស់លាស់កើតឡើងចំពោះតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលចាប់ផ្ដើមសវនាការក៏ដោយ ក៏ចំណុចនេះមិនចាត់ទុកជាបុរេវិនិច្ឆ័យចំពោះម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការនោះដែរ។

៥៩. បើទោះជាអង្គជំនុំជម្រះសាលាដំបូង ពុំមានកំហុសអង្គច្បាប់ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ហាក់បីដូចជាមានការយល់ច្រឡំជាសារវន្តរវាងអង្គជំនុំជម្រះសាលាដំបូង និងម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងទៅនឹងលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃពាក្យសុំ និងអានុភាពតាមផ្លូវច្បាប់នៃការពិនិត្យជាបឋមលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះតុលាការកំពូល ក៏ទទួលស្គាល់ផងដែរថា ដំណើរការទទួលស្គាល់ និងការបដិសេធឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ពិតជាអាចបណ្ដាលឱ្យមានការប៉ះពាល់ដល់ផ្លូវចិត្ត និងការខកចិត្តដោយសារការចូលរួមដោយឥតប្រយោជន៍នៅក្នុងកិច្ចដំណើរការនីតិវិធីកន្លងមក។ ក្រោយពីបានពិចារណាអំពីចរិតលក្ខណៈថ្មីនៃក្របខ័ណ្ឌដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក. និងភាពមិនច្បាស់លាស់ដែលអាចមើលឃើញទាក់ទិនទៅនឹងការរៀបចំជាក់លាក់អំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះតុលាការកំពូល ទទួលស្គាល់នូវ

លទ្ធភាពដែលអាចកើតមានឡើងថា អាចមានម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន មានការយល់ច្រឡំចំពោះបញ្ហា ថាតើនៅតែមានការទាមទារឱ្យពួកគាត់ដាក់ភស្តុតាងបន្ថែមទៀតដែរឬយ៉ាងណា។ ហេតុដូច្នេះដើម្បីទូទាត់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីនូវឱកាសដែលខ្លួនបានបាត់បង់កន្លងមក អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកសំណើរបស់ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសុំដាក់ភស្តុតាងបន្ថែម ដោយមិនចាំបាច់ពិចារណា ថាតើភស្តុតាងទាំងនេះបានដាក់រួចហើយនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងដែរឬយ៉ាងណា នោះឡើយ។

៦០. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីខាងក្រោមនេះ ពិតជាបានបង្ហាញភស្តុតាងគ្រប់គ្រាន់ នៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួន ហេតុនេះត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ បន្ថែមលើដើមបណ្ដឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចទទួលស្គាល់នៅក្នុងសាលក្រមរបស់ខ្លួន គឺ៖

- លី ហ៊ា ហៅ អ៊ា ហ៊ារ (E2/61)
- ហ៊ឹម មុំ (E2/62)
- JAMES Jeffrey, ROTHSCHILD Joshua (E2/86 និង E2/88)
- ឆាយ កន ហៅ លៀង កន (E2/35)
- ហុង សាវ៉ាត (E2/83)
- ភោគ ខន (E2/33)
- ម៉ន សុជា (E2/82)
- ឈឹម ស៊ីថា (E2/22)
- ណាំ ម៉ុន (E2/32)។

៦១. អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត ដោយហេតុថា មិនអាចទទួលយកបាន។

៦២. ទាក់ទងនឹងបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ជុំ ស៊ីរ៉ាត (D25/6) អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ពិតជាមានការភ្លេចបញ្ចូលឈ្មោះអ្នកស្រី គីម សុវណ្ណារី និងកូនរបស់គាត់នៅក្នុងបញ្ជីឈ្មោះជនរងគ្រោះ ក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលនេះ គឺជាកំហុសសម្ភារៈ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលធ្វើការកែតម្រូវកំហុសនេះដោយខ្លួនឯង ក្នុងការដាក់បញ្ចូលឈ្មោះអ្នកស្រី គីម សុវណ្ណារី និងកូនរបស់គាត់ទៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ។

## ច. សំណាងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី

៦៣. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចទៅលើសំណើសុំសំណងដែលមានដូចជាៈ (ក) យល់ព្រមបញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងសាលក្រម និង (ខ) ចងក្រង និងផ្សព្វផ្សាយពាក្យសម្តីសុំអភ័យទោស និងពាក្យសម្តីទទួលស្គាល់ការទទួលខុសត្រូវទាំងអស់ដែល កាំង ហ្កេកអ៊ាវ បានធ្វើឡើងក្នុងអំឡុងពេលសវនាការ។ សំណើសុំសំណងដទៃទៀតរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធដោយសំអាងថា សំណើសុំទាំងនោះខ្វះភាពជាក់លាក់ឬហួសពីវិសាលភាពនៃសំណងដែលមាននៅ ចំពោះមុខ អ.វ.ត.ក.។

៦៤. ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ មិនបានប្តឹងសាទុក្ខប្រឆាំងនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើបញ្ហាសំណងក៏ដោយ ក៏ក្រុមនេះបានស្នើថា នៅក្នុងស្ថានភាពដែលទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខអំពីសំណងដែលបានដាក់ដោយម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ និងក្រុម ៣ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកនោះ នោះផលប្រយោជន៍ដែលបានពីសំណងទាំងនេះ ក៏នឹងមានវិសាលភាពផងដែរ ដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុម ១។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានលើកឡើងពីទឡ្ហីករណ៍យ៉ាងទូលំទូលាយអំពីសំណង ហើយបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលប្រានចោលនូវការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសំណើសុំសំណងរបស់ខ្លួនចំនួន ៩ ចំណុច និងបានស្នើសុំឱ្យសម្រេចផ្តល់សំណងទាំងអស់នេះវិញ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ក៏ស្នើសុំផងដែរដល់អង្គជំនុំជម្រះតុលាការកំពូលឱ្យសម្រេចផ្តល់សំណងទៅតាមសំណើដើមដែលខ្លួនបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ហើយត្រូវបានបដិសេធនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

៦៥. ជាបឋម អង្គជំនុំជម្រះតុលាការកំពូល នឹងលើកបង្ហាញនូវក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងសំណងនៅចំពោះមុខ អ.វ.ត.ក.។ ទោះបីជាម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានពឹងផ្អែកលើសំអាងផ្លូវច្បាប់អន្តរជាតិខុសៗគ្នាជាច្រើនសម្រាប់ជាប្រភពក្នុងការរៀបចំវិធីសាស្ត្រ ដែលមានលក្ខណៈបត់-បែនស្តីពីសំណងក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ថា អ.វ.ត.ក. ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃប្រព័ន្ធច្បាប់ពិសេស ហើយមានតែសទិសភាព និងការណែនាំដែលមានកំរិតប៉ុណ្ណោះ ដែលអាចទាញយកពីក្របខណ្ឌដាច់ដោយឡែកទាំងនោះបាន។ ទោះបីជាមានការលើកឡើងដ៏ត្រឹមត្រូវថាប្រទេសកម្ពុជាជារដ្ឋភាគីមួយនៃលិខិតុបករណ៍អន្តរជាតិជាច្រើន ដែលបានចែងអំពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាននូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពក៏ដោយ ក៏ អ.វ.ត.ក. មិនមានអំណាចក្នុងការវាយតម្លៃពីការអនុវត្តកាតព្វកិច្ចជាអន្តរជាតិ

របស់ប្រទេសកម្ពុជានេះដែរ។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានយល់ឃើញផងដែរថា ខ្លួនពុំមានយុត្តាធិការក្នុងការសម្រេចផ្តល់សំណងទៅតាមសំណើសុំទាំងឡាយណាដែលតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មរបស់អាជ្ញាធរកម្ពុជា សម្រាប់អនុវត្តវិធានការនានាក្នុងការផ្តល់សំណងឡើយ ដែលទោះជាកាតព្វកិច្ចដែលមានកំណត់ច្បាស់លាស់ក្តីឬគ្រាន់តែជាភាពចាំបាច់ក្តី។ អ.វ.ត.ក. ក៏ពុំមានសមត្ថកិច្ចក្នុងការអនុវត្តសេចក្តីសម្រេចផ្តល់សំណងនេះផងដែរ។

៦៦. អាស្រ័យហេតុនេះ ទោះបីជា អ.វ.ត.ក. ពិតជាមានសមត្ថកិច្ចក្នុងការផ្តល់សំណងក៏ដោយ ក៏សមត្ថកិច្ចនេះត្រូវតែបកស្រាយទៅតាមអាណត្តិការងារ និងគោលបំណងក្នុងន័យចង្អៀត។ វិធាន២៣ នៃវិធានផ្ទៃក្នុងចែងថា «សំណងកំហិតត្រឹមតែសំណងជា«សមូហភាព និងផ្លូវចិត្ត»»។ ពាក្យថា «ផ្លូវចិត្ត» បង្ហាញពីគោលដៅនៃព្យសនកម្មផ្លូវចិត្តដែលអាចជួសជុលបានហើយពុំមែនជាសម្ភារៈទេ ចំណែកឯពាក្យថា «សមូហភាព» គឺមិនរាប់បញ្ចូលនូវសំណងជាបុគ្គលទេ បើទោះបីពាក់ព័ន្ធ ឬមិនពាក់ព័ន្ធនឹងស្ថានភាពហិរញ្ញវត្ថុក៏ដោយ និងពាក្យ«សមូហភាព»នេះក៏សំដៅទៅលើវិធានការទាំងឡាយណាដែលជាប្រយោជន៍ដល់ជនរងគ្រោះដែលមានចំនួនកាន់តែច្រើន តាមដែលអាចធ្វើទៅបាន។

៦៧. កត្តាគន្លឹះមួយទៀតទាក់ទងនឹងប្រព័ន្ធនៃការផ្តល់សំណងនៅ អ.វ.ត.ក. គឺថាការផ្តល់សំណងដែលជាកាតព្វកិច្ចផ្ទាល់មុខរបស់ពិរុទ្ធជន។ រឿងក្តីបច្ចុប្បន្ននេះពាក់ព័ន្ធនឹងពិរុទ្ធជនដែលត្រូវបានរកឃើញថាជាជនក្រីក្រ។ គឺជាចំណុចសំខាន់ដំបូងបំផុតក្នុងការកម្រិតអំពីសំណងបែបនេះ ដើម្បីឱ្យការអនុវត្តសំណងអាចធ្វើបានយ៉ាងពិតប្រាកដ ដើម្បីបញ្ចៀសនូវការចេញសេចក្តីបង្គាប់ទាំងឡាយណាដែលមិនអាចយកទៅអនុវត្តបាន និងដែលនាំឱ្យជនរងគ្រោះមានការភ័ន្តច្រឡំ និងខកចិត្ត។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងមិនទទួលយកនូវសំណើណា ដែលពឹងផ្អែកលើហិរញ្ញវត្ថុរបស់ កាំង ហ្គេកអ៊ាវ ក្នុងការអនុវត្តសំណងនោះឡើយ។

៦៨. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សំណើមួយចំនួនត្រូវបានបដិសេធចោលដោយហេតុថា ការសម្រេចទទួលយកសំណើទាំងនេះ មានអត្ថន័យជាសេចក្តីបង្គាប់ចំពោះរដ្ឋរបស់កម្ពុជា។ នេះជាករណីមួយដែលអាចកើតឡើងឧទាហរណ៍ ដូចជាករណីដែលស្នើសុំឱ្យមានការសុំអភ័យទោសពីរដ្ឋ ការរៀបចំឱ្យមានការថែទាំសុខភាព ការបង្កើតឱ្យមានថ្ងៃរំលឹកវិញ្ញាណក្ខន្ធថ្នាក់ជាតិ និងយកឈ្មោះជនរងគ្រោះដាក់ជាឈ្មោះអគារសាធារណៈ ជាដើម។ រីឯសំណើដទៃទៀតត្រូវបានបដិសេធចោល ដោយហេតុថា ពុំមានមធ្យោបាយហិរញ្ញវត្ថុសម្រាប់ធានាការអនុវត្តតាមសំណើទាំងនោះ។ ករណីនេះនឹងអាចកើតឡើង ឧទាហរណ៍ ដូចជា សំណើសុំឱ្យសាងសង់បូជនីយដ្ឋាន និងដំណើរទស្សនកិច្ច

ដោយឥតគិតថ្លៃរបស់ជនរងគ្រោះទៅកាន់ទីបូជនីយដ្ឋានទាំងនោះ។ សំណើដែលសុំឱ្យតុលាការបង្គាប់ឱ្យ កាំង ហ្គេកអ៊ាវ សរសេរលិខិតទៅរដ្ឋាភិបាល ក៏ជាសំណើដែលត្រូវបានបដិសេធចោលដែរ ដោយហេតុថា ជាសំណើដែលមិនអាចអនុវត្តបាន។ ចំពោះសំណើដែលទាក់ទិននឹងការផ្សព្វផ្សាយសម្ភារៈ និងឯកសារនានា ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា កិច្ចការទាំងនោះស្ថិតក្នុងអាណត្តិរបស់ផ្នែកកិច្ចការសាធារណៈ និងអង្គភាពគាំពារជនរងគ្រោះនៃ អ.វ.ត.ក. រួចហើយ។

## ឆ. ផ្នែកសម្រេចសេចក្តី

៦៩. អង្គជំនុំជម្រះតុលាការកំពូល អានបន្តនូវផ្នែកសម្រេចសេចក្តីរបស់ អង្គជំនុំជម្រះតុលាការកំពូល។ ផ្នែកសម្រេចសេចក្តីដែលភ្ជាប់នៅក្នុងសាលដីកាសង្ខេបនេះ មានលក្ខណៈពេញលេញ និងចូលជាស្ថាពរ ហើយត្រូវបានចុះហត្ថលេខាដោយចៅក្រមអង្គជំនុំជម្រះតុលាការកំពូល។

## ផ្នែកសម្រេចសេចក្តី

យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូល៖

ដោយអនុលោមតាមមាត្រា១៤ថ្មី (១)(ខ) និង មាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មាត្រា ៤(១)(ខ) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ឆ្នាំ ២០០៣ និងវិធាន ១១១ នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨)

បានឃើញសារណាបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សររបស់ភាគីនីមួយៗ និងអំណះអំណាងដែលភាគីបានលើកឡើងនៅក្នុងសវនាការបណ្តឹងសាទុក្ខចាប់ពីថ្ងៃទី២៨ ដល់ ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១១។

ចំពោះបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ «ឌុច» សម្រេចបដិសេធបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។

ចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

សម្រេចទទួលយកផ្នែកខ្លះនៃទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងសម្រេចបដិសេធផ្នែកខ្លះនៃទឡ្ហីករណ៍នេះ។

សម្រេចបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រង់ចំណុចស្រូបបញ្ចូលបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅក្នុងបទធ្វើទុក្ខបុកម្នេញ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា កាំង ហ្កេកអ៊ាវ ជាអ្នកទទួលខុសត្រូវ។

សម្រេចតម្កល់ការដាក់ពិរុទ្ធភាព លើ កាំង ហ្កេកអ៊ាវ ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

សម្រេចដាក់ពិរុទ្ធភាពបន្ថែមលើ កាំង ហ្កេកអ៊ាវ ពីបទសម្លាប់រង្គាល (រួមបញ្ចូលអំពើមនុស្សឃាត) បទធ្វើឱ្យទៅជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំង បទធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

សម្រេចទទួលយកទឡ្ហីករណ៍ទី ១ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

សម្រេចបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចសម្រេចផ្តន្ទាទោសលើ កាំង ហ្កេកអ៊ាវ ដាក់ពន្ធនាគាររយៈពេល ៣៥ ឆ្នាំ ។

សម្រេចបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចសម្រេចផ្តល់សំណងចំពោះការរំលោភសិទ្ធិរបស់ជនជាប់ចោទដែលបណ្តាលមកពីការឃុំខ្លួនខុសច្បាប់នីតិវិធី របស់តុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ និង

សម្រេចផ្តន្ទាទោសលើ កាំង ហ្កេកអ៊ាវ ដាក់ពន្ធនាគារអស់មួយជីវិត ដោយចាប់គិតពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ តទៅ ដែលគិតមកទល់ពេលនេះ កាំង ហ្កេកអ៊ាវ បានទទួលរង ទោសអស់រយៈពេល ១២ ឆ្នាំ និង ២៦៩ ថ្ងៃរួចហើយ។

សម្រេចបដិសេធទឡ្ហីករណ៍ទី ៣ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

ចំពោះបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ក្រុម ២ និង ក្រុម ៣

សម្រេចទទួលយកផ្នែកខ្លះនៃទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបដិសេធ ផ្នែកខ្លះនៃទឡ្ហីករណ៍ទាំងនេះ។

សម្រេចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានភស្តុតាងបង្ហាញនៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខថា ពិតជាបានទទួលរងព្យសនកម្មដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ត្រូវបានសម្រេចដាក់ពិរុទ្ធភាព បន្ថែមលើដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងកថាខណ្ឌ ៦៨២ នៃសាលក្រម ដូចមានរាយនាមខាងក្រោម៖

- លី ហ៊ា ហៅ អ៊ា ហ៊ារ (E2/61)
- ហ៊ឹម មុំ (E2/62)
- JAMES Jeffrey, ROTHSCHILD Joshua (E2/86 និង E2/88)
- ឆាយ កន ហៅ លៀង កន (E2/35)
- ហុង សាវ៉ាត (E2/83)
- ភោគ ខន (E2/33)
- ម៉ន សុជា (E2/82)
- ឈឹម ស៊ីថា (E2/22)
- ណាំ ម៉ុន (E2/32)។

សម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត។

សម្រេចបដិសេធ ទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណង។

សម្រេចតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចស្តីពីការចងក្រងនិងផ្សព្វផ្សាយនៅក្នុងគេហទំព័រជាផ្លូវការរបស់ អ.វ.ត.ក. នូវសេចក្តីថ្លែងសុំអភ័យទោស និងការទទួលស្គាល់នូវការទទួលខុសត្រូវដែលបានធ្វើឡើងដោយ កាំង ហ្គេកអ៊ាវ ក្នុងអំឡុងពេលជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូងព្រមទាំងនៅអង្គជំនុំជម្រះតុលាការកំពូល។

សម្រេចតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចបដិសេធសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

ដោយអនុលោមតាម វិធាន ១១១ (៥) និង ១១៣(១)-(៣) នៃវិធានផ្ទៃក្នុង
បង្គាប់ថា កាំង ហ្គេកអ៊ាវ ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក. រហូតដល់ពេលបញ្ចប់នៃកិច្ចរៀបចំនានាក្នុងការផ្ទេរ កាំង ហ្គេកអ៊ាវ ទៅកាន់ពន្ធនាគារដែលខ្លួនត្រូវអនុវត្តទោសដោយអនុលោមតាមច្បាប់ជាធរមាន។

ធ្វើជាភាសាខ្មែរ ភាសាអង់គ្លេស
រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២

ចៅក្រម Klonowiecka-Milart និងចៅក្រម Chandra Nihal Jayasinghe ភ្ជាប់មតិជំទាស់រួមគ្នាលើផ្នែកខ្លះ។

**ក្រឡាបញ្ជី**

**ស៊ា ម៉ៅ** **Christopher RYAN** **ផន ធឿន** Paolo LOBBA

ចៅក្រម **គង់ ស្រ៊ឹម ប្រធាន**

ចៅក្រម **Motoo NOGUCHI**

ចៅក្រម **សោម សិរីវឌ្ឍ**

ចៅក្រម **Agnieszka KLONOWIECKA-MILART**

ចៅក្រម **ស៊ិន រិទ្ធ**

ចៅក្រម **Chandra Nihal JAYASINGHE**

ចៅក្រម **យ៉ា ណារិន**

៧០. ទាំងនេះ គឺជាសេចក្តីសង្ខេបសំអាងហេតុនៃសាលដីការបស់អង្គជនុំជម្រះតុលាការកំពូលរួមជាមួយនឹងផ្នែកសម្រេចសេចក្តីដែលពេញលេញនិងស្ថាពរ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលប្រកាសបិទសវនាការលើបណ្តឹងសាទុក្ខក្នុងរឿងក្តីនេះ។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
អ.វ.ត.ក



# ៦. ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០១

# ៦. ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១



## បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ ចំនួន៦៦រូប ដែលត្រូវបានទទួលស្គាល់ថាបានទទួលរងគ្រោះដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មដែល ឌុច ត្រូវបានប្រកាសថាទទួលខុសត្រូវ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង

| ល.រ | លេខសំគាល់ | ឯកសារ | នាមត្រកូលនិងនាមខ្លួន |
|---|---|---|---|
| ១ | 00-VU-00010 | D25/1 | ប៊ូ ម៉េង |
| ២ | 00-VU-00012 | D25/3 | ជុំ ម៉ី |
| ៣ | 08-VU-00658 | D25/16 | ជុំ នៅ |
| ៤ | 09-VU-00002 | E2/80 | ជិន ម៉េត |
| ៥ | 00-VU-00011 | D25/2 | ឈិន ណារី |
| ៦ | 08-VU-00041 | D25/4 | ហាវ សោភា |
| ៧ | 08-VU-00670 | D25/7 | អ៊ឹម ស៊ុន្ធី |
| ៨ | 08-VU-00671 | D25/5 | ភឹងហួត ស៊ុនថារី |
| ៩ | 08-VU-00042 | D25/6 | ជុំ ស៊ីរ៉ាត |
| ១០ | 08-VU-00819 | D25/8 | មាសកេត សំភាត់ (MEASKETH Samphortre) |
| ១១ | 08-VU-01276 | D25/27 | ជូឡុង អង់តូនីញ៉ា (TIOULONG Antonya) |
| ១២ | 08-VU-01277 | D25/28 | ជូឡុង ណេវ៉ា (TIOULONG-ROHMER Neva) |

| ល.រ | លេខសំគាល់ | ឯកសារ | នាមត្រកូលនិងនាមខ្លួន |
|---|---|---|---|
| ១៣ | 08-VU-01278 | D25/26 | គីម៉ារី ណេវីនកា (KIMARI Nevinka) |
| ១៤ | 08-VU-01279 | E2/29 | គីម៉ារី វីសាកា (KIMARI Visaka) |
| ១៥ | 08-VU-01017 | D25/9 | រស់ ម៉េន |
| ១៦ | 08-VU-01013 | D25/10 | ផៃ ហ៊ាប |
| ១៧ | 08-VU-01015 | D25/12 | ជ្រាំង សំអ៊ាន |
| ១៨ | 08-VU-01008 | D25/13 | ស៊ាង វ៉ាន់ឌី |
| ១៩ | 08-VU-00234 | D25/14 | តួច មុនិន្ទ |
| ២០ | 08-VU-00748 | D25/17 | កាន់ ស៊ុន្ធរ៉ា |
| ២១ | 08-VU-01012 | D25/18 | ម៉ាន សូត |
| ២២ | 08-VU-01016 | D25/19 | គង់ ទេស |
| ២៣ | 08-VU-00415 | D25/20 | ផ៉េត សុខ |
| ២៤ | 08-VU-01007 | D25/21 | តាត់ ឡូន |
| ២៥ | 08-VU-01115 | D25/22 | ធីម៉ូធី ស្កុត ឌីដ (Timothy Scott DEEDS) |
| ២៦ | 08-VU-00338 | D25/23 | យឹម ឡេង |
| ២៧ | 08-VU-00416 | D25/24 | អ៊ុម ពិសិដ្ឋ (សិទ្ធិវ័ន្ត នៃ សួស សារិន) |
| ២៨ | 08-VU-01011 | D25/25 | កែ ខុន |
| ២៩ | 08-VU-01519 | E2/46 | កែ សាម៉ូត |
| ៣០ | 08-VU-01219 | E2/21 | អៀម សួយ |

| ល.រ | លេខសំគាល់ | ឯកសារ | នាមត្រកូលនិងនាមខ្លួន |
|---|---|---|---|
| ៣១ | 08-VU-01366 | E2/24 | អ៊ុល សាយ ហៅ រៀម |
| ៣២ | 08-VU-01365 | E2/25 | ស៊ិន លឹមសៀ |
| ៣៣ | 08-VU-01770 | E2/26 | អ៊ូ សាររិទ្ធ |
| ៣៤ | 08-VU-01768 | E2/31 | ញឹក អ៊ូដាវី (NHEK Oudavy) |
| ៣៥ | 08-VU-01769 | E2/27 | អ៊ូ កាមេឡា (OU Kamela) |
| ៣៦ | 08-VU-01369 | E2/28 | រស់ ជួ ស៊ីអ៊ី (ROS Chuorsiy) |
| ៣៧ | 08-VU-00152 | E2/30 | ញឹម គឹមហៀន |
| ៣៨ | 08-VU-01311 | E2/39 | សួន សុខុម៉ាលី (SUON Sokhomaly) |
| ៣៩ | 08-VU-00288 | E2/41 | ស៊ិន ស៊ីណែត ហៅ ស្រ៊ុន |
| ៤០ | 08-VU-01427 | E2/42 | រ្វន ស្រីណុប |
| ៤១ | 08-VU-01428 | E2/43 | អែល លីម៉ះ |
| ៤២ | 08-VU-01431 | E2/45 | ស្មាន ស |
| ៤៣ | 08-VU-01430 | E2/44 | ស្មាន ណុប |
| ៤៤ | 08-VU-01523 | E2/47 | ម៉ែន ឡាយ |
| ៤៥ | 08-VU-01524 | E2/48 | ញ៉ៀម សុផាន |
| ៤៦ | 08-VU-01526 | E2/50 | នេត ផល្លី |
| ៤៧ | 08-VU-01583 | E2/51 | ម៉ាន ម៉ះ ហៅ ម៉ាន ម៉ាលីម៉ះ |
| ៤៨ | 08-VU-01584 | E2/52 | កុំ មេន ហៅ គុម មេន |

| ល.រ | លេខសំគាល់ | ឯកសារ | នាមត្រកូលនិងនាមខ្លួន |
|---|---|---|---|
| ៤៩ | 08-VU-01764 | E2/53 | ទ្រី ង៉ិចលាង |
| ៥០ | 08-VU-01765 | E2/54 | ហេង ង៉ិចហុង |
| ៥១ | 08-VU-01766 | E2/55 | បេង ចាន់ថន |
| ៥២ | 08-VU-01767 | E2/56 | យុន ឈីន |
| ៥៣ | 08-VU-01771 | E2/57 | លី យៀក |
| ៥៤ | 08-VU-02261 | E2/58 | ពូល ពន្លឺក ហៅ ង៉ែត |
| ៥៥ | 09-VU-00001 | E2/59 | ចាន់ គ្រួច |
| ៥៦ | 08-VU-01429 | E2/60 | នង គឹមលៀង |
| ៥៧ | 07-VU-00004 | E2/66 | ពេញ សុខេន |
| ៥៨ | 09-VU-00176 | E2/72 | កាន សាន |
| ៥៩ | 08-VU-01256 | E2/76 | អ៊ុង រឿន ហៅ ហ៊ុល រឿន |
| ៦០ | 08-VU-02298 | E2/78 | មាស សារឿន |
| ៦១ | 08-VU-02299 | E2/79 | សេក សៀក |
| ៦២ | 09-VU-00020 | E2/81 | ឆាត គឹម ឈុន |
| ៦៣ | 09-VU-00177 | E2/84 | អ៊ុក វ៉ាសោផិន |
| ៦៤ | 09-VU-00169 | E2/85 | ម៉ាទីន លីហ្វឺយ (Martine LEFEUVRE) |
| ៦៥ | 09-VU-00170 | E2/89 | អ៊ុក នារី |
| ៦៦ | 09-VU-00167 | E2/87 | រ៉ូប៊ឺត ហាមីល (Robert HAMILL) |

## បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ មាន១០រូប ដែលត្រូវបានទទួលស្គាល់ថាបានទទួលរងគ្រោះដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មដែល ឌុច ត្រូវបានប្រកាសថាទទួលខុសត្រូវ នៅក្នុងសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល

| ល.រ | លេខសំគាល់ | ឯកសារ | នាមត្រកូលនិងនាមខ្លួន |
|---|---|---|---|
| ៦៧ | 08-VU-01516 | E2/61 | លី ហ៊ ហៅ អ៊ា ហ៊ារ |
| ៦៨ | 08-VU-01515 | E2/62 | ហ៊ឹម មុំ |
| ៦៩ | 09-VU-00168 | E2/86 | JAMES Jeffrey |
| ៧០ | 09-VU-00160 | E2/88 | ROTHSCHILD Joshua |
| ៧១ | 08-VU-01014 | E2/35 | ឆាយ កន ហៅ លៀង កន |
| ៧២ | 09-VU-00166 | E2/83 | ហុង សាវ៉ាត |
| ៧៣ | 08-VU-00579 | E2/33 | ភោគ ខន |
| ៧៤ | 09-VU-00095 | E2/82 | ម៉ន សុជា |
| ៧៥ | 08-VU-01220 | E2/22 | ឈឹម ស៊ីថា |
| ៧៦ | 08-VU-00162 | E2/32 | ណាំ ម៉ុន |



# ៧. ការចងក្រងនិង បោះពុម្ពផ្សាយសេចក្តីថ្លែង សុំអភ័យទោសនិងការ ទទួលស្គាល់ការទទួល ខុសត្រូវរបស់ ឌុច

# ៧. ការចងក្រងនិងបោះពុម្ពផ្សាយសេចក្តីថ្លែងសុំអភ័យទោស និងការទទួលស្គាល់ការទទួលខុសត្រូវរបស់ ឌុច



## ប្រតិចារិកថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៩

### ទំព័រ៥២ [បន្ទាត់១៤-២៥] ដល់ទំព័រ៥៦ [បន្ទាត់១-២១]

ដំបូងខ្ញុំសូមបញ្ជាក់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្រ្តនៅកម្ពុជាខ្លះ ។

តាមតម្រាយដែលសហព្រះរាជអាជ្ញាលោកមានប្រសាសន៍រួចមកហើយ ។ ខ្ញុំសូមបញ្ជាក់ថា ប្រជាជនកម្ពុជា រងទុក្ខវេទនា ដោយការកាប់សម្លាប់នេះយូរឆ្នាំហើយ គឺចាប់តាំងពីឆ្នាំ១៩៦៦ ដែលឧត្តមសេនីយ៍ លន់ នល់ គាត់កាប់សម្លាប់កសិករនៅសំឡូត ។ បន្ទាប់មកទៀតរដ្ឋប្រហារ ១៨មីនា ភាគនយោបាយទាំងអស់ ប្រណាំងប្រជែងគ្នាកាប់សម្លាប់ ប្រជាជនកម្ពុជារហូតដល់ ថ្ងៃ១៧ មេសា ១៩៧៥ ទើប ឧក្រិដ្ឋកម្មនេះ វាធ្លាក់ផ្ចាប់មុខទៅលើបក្សកុម្មុយនីស្តកម្ពុជា នេះ តម្រាយប្រវត្តិសាស្រ្ត ដែលខ្ញុំសូមលើកជូនអង្គប្រជុំ ស្របតាមតម្រាយដែលសហព្រះរាជអាជ្ញា ព្រឹកមិញ លោក មានប្រសាសន៍ ។

តទៅនេះ ខ្ញុំសូមបញ្ជាក់អំពីគោលជំហរខ្ញុំ ដូចតទៅ៖

ពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ បក្សកុម្មុយនីស្តកម្ពុជា ជាអ្នកទទួលខុសត្រូវផ្ចាប់មុខលើឧក្រិដ្ឋកម្ម នៅកម្ពុជា ភស្តុតាងសំខាន់គឺ លក្ខន្តិកៈបក្សឆ្នាំ១៩៧៦ ។ ទំព័រទី១ នៃលក្ខន្តិកនេះ សរសេរជាអាទិ៍ថា «ក្រោយពីដឹកនាំ សម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ បានទាំងស្រុងនឹងជាស្ថាពរនៅថ្ងៃ១៧ មេសា ១៩៧៥ មក ។ បក្សកុម្មុយ នីស្តកម្ពុជា ដឹកនាំបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមតទៅទៀត ដោយផ្ចាប់មុខ ដាច់ខាតនឹងគ្រប់ផ្នែក» នេះជាភស្តុតាង ដែលខ្ញុំសូមលើក ជូនជាតិប្រជាជនតាមរយៈអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ។

ទី១) ខ្ញុំសូមវិភាគអំពីឧក្រិដ្ឋកម្មទូទាំងប្រទេសពីថ្ងៃ១៧មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩។ ក្រោយ ១៧ មេសា ១៩៧៥ ប៉ុល ពត កើតចិត្តភ្លើតភ្លើនខ្លាំងណាស់ បានលើកមាគ៌ាដែលប៉ះពាល់អាយុមនុស្ស នេះគឺមកពី ប៉ុល ពត គាត់មានសព្វមានគ្រប់ សំខាន់គឺមានបក្ខជន រាប់ម៉ឺននាក់ នៅក្នុងកណ្តាប់ដៃគាត់។ ឧក្រិដ្ឋកម្មជំនាន់នោះធំធេងណាស់។ ដោយឡែកការបាត់បង់ អាយុជីវិត មានទៅដល់ជាងមួយលាននាក់ ដោយខ្ញុំជា បក្ខជនមួយរូបរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំទទួលស្គាល់ថា «ខ្ញុំពិតជាមានតួនាទីទទួលខុសត្រូវខាងផ្លូវចិត្ត លើឧក្រិដ្ឋកម្ម

ដែលបក្សកុម្មុយនីស្តកម្ពុជាប្រព្រឹត្តនៅជំនាន់នោះ» ខ្ញុំសូមសម្ដែងនូវវិប្បដិសារី សោកស្ដាយយ៉ាងឈឺចាប់បំផុត ចំពោះឧក្រិដ្ឋកម្មគ្រប់យ៉ាង ដែលបក្សកុម្មុយនីស្តកម្ពុជាប្រព្រឹត្តពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩ ។

ទី២) ខ្ញុំសូមបញ្ជាក់ដោយឡែក អំពីឧក្រិដ្ឋកម្មនៅ ស-២១ខ្ញុំសូមទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្ញុំតាមផ្លូវច្បាប់ ។ ខ្ញុំសូមបញ្ជាក់ថា តាមផ្លូវច្បាប់ចំពោះឧក្រិដ្ឋកម្ម ទាំងអស់ ដែលកើតមាននៅ ស-២១ សំខាន់គឺសកម្មភាពធ្វើទារុណកម្ម និងសម្លាប់ផ្ដាច់ផ្ដោចអាយុជីវិតមនុស្ស ។

តាមតម្រាយដែលខ្ញុំបានធ្វើរួចមកហើយ នៅវេលាដែលលោកសហចៅក្រមស៊ើបអង្កេតនាំខ្ញុំទៅសម្ដែងសកម្មភាព រំឭកព្រឹត្តិការណ៍ចាស់ឡើងវិញ នៅជើងឯកនិងនៅសារមន្ទីរប្រល័យពូជសាសន៍ ទួលស្លែងគឺ ខ្ញុំសូមអនុញ្ញាត ចូលសុំ ទោសជនរងគ្រោះ ដែលនៅរស់រានមានជីវិត និងសុំទោស ក្រុមគ្រួសារជនរងគ្រោះទាំងអស់ដែល បានស្លាប់បាត់បង់ជីវិត យ៉ាងអាណោចអាធ័មនៅស-២១ ។

ពេលនេះ ខ្ញុំសូមអស់លោកទាំងនោះ លោកមេត្តាទទួលដឹងឮថាខ្ញុំចង់សុំទោស សូមលោកមេត្តាយកបំណងនេះទៅ ពិចារណា។ ខ្ញុំមិនជាមិនទាន់ទាមទារសូមឱ្យលោកអត់ទោសឱ្យខ្ញុំនៅពេលឥឡូវនេះទេ ។ ខ្ញុំដឹងហើយថា ឧក្រិដ្ឋកម្ម របស់ខ្ញុំទៅលើជីវិតមនុស្សជាពិសេសទៅលើជីវិតស្ត្រី និងកុមារ ជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរមិនអាចអត់ឱនឱ្យបានទេ ។ សំណូមពរបច្ចុប្បន្ននេះ របស់ខ្ញុំគឺសូមអស់លោក លោកមេត្តាទុកទ្វារចូលសុំទោសនេះ ឱ្យនៅចំហ ។

ទី៣) វិប្បដិសារីដ៏សែនចុកចាប់របស់ខ្ញុំរំឭកអតីតកាលពេលណា ខ្ញុំសែនខ្លោចផ្សាពេលនោះ ។ ខ្ញុំតក់ស្លុតណាស់ កាលណាខ្ញុំនឹកដល់សកម្មភាពកន្លងមក ដែលខ្ញុំបានទទួលអនុវត្ត និង បានបញ្ជាឱ្យអនុវត្ត ដែលសុទ្ធតែជាសកម្មភាពប៉ះពាល់ដល់អាយុជីវិតជនស្លូតត្រង់យ៉ាងច្រើន ក្នុងនោះ រួមមានទាំងស្ត្រី និងកុមារផង ។

ទោះបីខ្ញុំធ្វើ ដោយគោរពតាមបញ្ជារបស់អង្គការក៏ដោយ ក៏ខ្ញុំពិតជាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ ។ ខ្ញុំបានជម្រាប សហចៅក្រមស៊ើបអង្កេតហើយថា ខ្ញុំជាចំណាប់ថ្នូរនិងជាតួសម្ដែងនៃរបបឧក្រិដ្ឋកម្មនេះ ។ ខ្ញុំជឿថា មនុស្សម្នាជា ទូទៅនៅពេលនេះ ចាត់ទុកខ្ញុំថាកំសាកថាអមនុស្សធម៌ ខ្ញុំទទួលពាក្យនេះដោយស្មោះនិងដោយគោរព ។ នៅសម័យស-២១នោះ ខ្ញុំចាត់ទុកជីវិតខ្ញុំនិងជីវិតគ្រួសារ ខ្ញុំសំខាន់លើសជីវិតអ្នកជាប់ឃុំឃាំងនៅស-២១ នោះ ។

ប្រកែកប្រណាំងនឹងបទបញ្ជាពីខាងលើ ទោះបីដឹងថា បទបញ្ជានោះឧក្រិដ្ឋក៏ដោយ ក៏ខ្ញុំមិនដែលហ៊ាននឹកនាដល់ដែរ នៅជំនាន់នោះ ។ នេះជាបញ្ហាស្លាប់រស់របស់ខ្ញុំនិងគ្រួសារខ្ញុំ ។ ក្នុងឋានៈខ្ញុំជាប្រធាន ស-២១ ខ្ញុំអត់ហ៊ានគិត គូររកលទ្ធភាពអ្វី ក្រៅពីអនុវត្តតាមបទបញ្ជារបស់ថ្នាក់លើទេ ។

ទោះបី ខ្ញុំដឹងថា ការអនុវត្តនោះនាំទៅរកការបាត់ បង់អាយុជីវិតមនុស្សរាប់ពាន់ៗនាក់ក៏ដោយ ។ បច្ចុប្បន្ននេះ ខ្ញុំមានវិប្បដិសារីសោកស្ដាយយ៉ាងជ្រាលជ្រៅ ព្រមទាំង ខ្មាសអៀន ព្រមទាំង មានសភាពរអៀស ក្នុងឋានៈជាអ្នកមានខ្លួនមានទោស ដឹងថាខ្លួនជាអ្នកមានទោសចំពោះ ជាតិប្រជាជនកម្ពុជាទាំងមូល ។ ចំពោះគ្រួសារជនរងគ្រោះទាំងអស់ ដែលបានបាត់បង់ជីវិត នៅស-២១ ព្រមទាំង ចំពោះក្រុមគ្រួសារខ្ញុំ ផ្ទាល់ ដែលមានសមាជិកមួយចំនួនបាត់បង់ជីវិតទៅ ក៏ដោយ ។

វិធានការដោះស្រាយខាង-- ពេលបច្ចុប្បន្ននេះរបស់ខ្ញុំ

ខ្ញុំបានសម្រេចចិត្តសហការជាមួយអង្គ អ.វ.ត.ក ដោយហេតុថាទុក្ខទោសទាំង ប៉ុន្មានដែល ខ្ញុំបានប្រព្រឹត្តទៅលើប្រជាជនខ្ញុំមានតែផ្លូវនេះតែមួយប៉ុណ្ណោះគត់ ដែលអាចរំលែកទុក្ខសោក ទាំងអស់ដែលបង្ក ឡើងដោយ ឧក្រិដ្ឋកម្មរបស់ស-២១ និយាយដោយឡែក និងឧក្រិដ្ឋកម្មរបស់ បក្ស កុម្មុយនីស្តកម្ពុជានិយាយជារួម ។

ខ្ញុំសូមបញ្ជាក់ថា ស-២១ និងវិនាសកម្មគួរឱ្យរន្ធត់ទាំងប៉ុន្មានដែល ស-២១បង្កើតឡើងជា បាតុភាពជាក់ស្ដែងដែលខ្ញុំសូមប្រគល់ខ្លួនជូនអង្គ អ.វ.ត.កជំនុំជម្រះខ្ញុំដោយផ្លូវច្បាប់ ដ៏ស្មោះ និង យ៉ាងឱនលំទោនជានិច្ច ។

នៅចុងបញ្ចប់នេះ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំពិតជាសហការតទៅទៀតជាមួយអ.វ.ត.ក នៅពេល សវនាការដោយខ្ញុំពិតជាឆ្លើយសំណួររបស់លោកនិងលោកស្រីចៅក្រមនៃអង្គជំនុំជម្រះ សាលា ដំបូង ។ ឆ្លើយសំណួររបស់លោកនិងលោកស្រីសហព្រះរាជអាជ្ញា ឆ្លើយសំណួររបស់ដើមបណ្ដឹង របស់រដ្ឋប្បវេណីទៅតាមការចង់ ដឹង និងដោយឈរលើឯកសារជាភស្តុតាង ។

លោកប្រធានជាទីគោរព!

តទៅនេះខ្ញុំសូមលោកមេត្តាអនុញ្ញាតឱ្យខ្ញុំថ្លែងអំពីវិប្បដិសារីដែលខ្ញុំមានប្រចាំជីវិតជូនដូចតទៅ៖ ខ្ញុំអត់ពេញចិត្តទេ ក្នុងការធ្វើការងារនេះ ។ ខ្ញុំបានសុំចេញទៅសហកម្មនៅ ខែ៥ ឆ្នាំ១៩៧៥ តែ មិនបាន សម្រេច ។ គេចាត់ឱ្យខ្ញុំធ្វើមន្ទីរស-២១ ខ្ញុំក៏បានធូរចិត្តម្យ៉ាងដែរ ដោយខ្ញុំធ្វើអនុប្រធាន គេ ។ បន្ទាប់មកខ្ញុំធ្វើប្រធាន ខ្ញុំតវ៉ាទៀត សុំយកអ្នកផ្សេងមកធ្វើប្រធាន ខ្ញុំធ្វើអនុប្រធាន ខ្ញុំត្រូវគេ កំហែង ។ ខ្ញុំក៏ព្រមធ្វើតទៅទៀត ។

រឿងដែលខ្ញុំចាប់ផ្ដើមតក់ស្លុត ចាប់ផ្ដើមនឹកឃើញគឺ ថ្ងៃ៣១ មករា ១៩៧៧ នៅពេលដែល សុន សេន គាត់បញ្ជាឱ្យចាប់កម្មាភិបាលភូមិភាគឧត្តរចាស់មកជាចំនួនច្រើនៗម្ដងខ្ញុំតក់ស្លុតណាស់។ ខ្ញុំសាកល្បង សុំយោបល់ គាត់ថាបង មនុស្សនេះដូចជាមិនមែន ។ គាត់កំហែងខ្ញុំ ពីខាងម្ខាង

ទូរស័ព្ទមកថា «យើ ឌុច! ចម្លើយអាធួនណាំ!» ។ ខ្ញុំលែងហ៊ានមាត់ ។ ខ្ញុំគិតក្នុងចិត្ត «ឱ! អ្នកដែលបានប្តូរផ្តាច់អាយុជីវិតដើម្បីរំដោះជាតិ ប្រជាជនខ្លួន ឥឡូវធ្លាក់ មក ស្លាប់ ធ្លាក់មកជាប់គុកក្នុងឋានៈជាជនក្បត់បក្ស» ។

ខ្ញុំសូមបញ្ជាក់ជូនជាតិប្រជាជន តាមរយៈអង្គជំនុំជម្រះសាលាដំបូងនេះថា ខ្ញុំនិងកម្មាភិបាលឧត្តរមានមនោសញ្ចេតនាជ្រាលជ្រៅនឹងគ្នាណាស់ ។ ខ្ញុំជាប់គុកកាលពីឆ្នាំ១៩៦៨ ភាគច្រើនជាមួយពួកអស់នេះដែរ ។ ការរន្ធត់តក់ស្លុតរបស់ខ្ញុំចេះតែបន្តទៅទៀតនៅពេល ដែលគេចាប់ មនុស្សពីភូមិភាគផ្សេងៗ ចុងបញ្ចប់ គេចាប់បង ង៉ែត ញូ ហៅ ហុង មកនៅថ្ងៃ១៣ មីនា ១៩៧៨ ។ ខ្ញុំគិតថា «អីយ៉ា! អាយុជីវិតខ្ញុំជិតដល់ពេលហើយ» ដូច្នេះ ការតក់ស្លុតចំពោះការត្រូវគេចាប់ចងវាម្យ៉ាង ការតក់ស្លុតចំពោះអាយុជីវិតខ្លួនឯងក្រែងមិនរស់ នេះក៏ម្យ៉ាងទៅទៀត ។

ដល់ចុងបញ្ចប់ មេធំរបស់ខ្ញុំ គឺបងទី២ បញ្ជាឱ្យខ្ញុំបញ្ចេញជនរងគ្រោះពីស-២១ ឱ្យអស់ទៅជើងឯក។ ខ្ញុំថា «ដល់ពេលហើយជីវិតខ្ញុំ» ពេលនោះខ្ញុំធ្វើការអត់កើតទេ ។ ខ្ញុំដេកនៅផ្ទះទាំងយប់ទាំងថ្ងៃ សួរចុះអ្នក ដែលខ្ញុំធ្លាប់ទៅអង្គុយនៅកន្លែងគួរឆ្ងាក់ គេអត់ឃើញមុខ ខ្ញុំទៅទីនោះទៀតទេ ។

ចុងបញ្ចប់ ម៉ោង១១ ថ្ងៃ៧ មករា រថក្រោះគេបរមុខកាត់មុខផ្ទះខ្ញុំ ខ្ញុំចប់លែង ដឹងធ្វើអី ។ ម៉ោង២ខ្ញុំនាំគ្នាចេញពីកន្លែងទីតាំងស-២១ ទៅនៅកន្លែងសន្សំកុសល ចាំយប់ព្រលប់ៗ បានខ្ញុំចេញទៅទៀត ។ ក្នុងមួយឆ្នាំនៃការរត់ភៀសសឹក ខ្ញុំបាត់បង់អស់អាយុជីវិតមនុស្សដែលនៅជុំវិញខ្ញុំ ដែលទៅជាមួយខ្ញុំទាំងប៉ុន្មាន ប្អូនខ្ញុំ២នាក់ស្លាប់, ក្មួយខ្ញុំ៦នាក់ស្លាប់, ប្រពន្ធមិត្តប៉ុន រួមទាំងមិត្តប៉ុនទៀត ទាំងកូនមិត្តប៉ុន ទៀតស្លាប់, ប្រពន្ធបង ម៉ម ណៃ ស្លាប់, មិត្តយើងផ្សេងទៀតស្លាប់ៗគ្មានសល់ ចុងបញ្ចប់នៅសល់តែខ្ញុំម្នាក់ឯង ។ គ្នាប្អូននាក់ មិនមែនម្នាក់ឯងទេ ។ ខ្ញុំ ហើយនិងប្រពន្ធខ្ញុំ ហើយនិង កូនពីរនាក់ ។ នៅពេលនោះខ្ញុំចង់សុំចេញពី មិនព្រមនៅជាមួយ នឹងបងសារុន ឈ្មោះដើម វៀង ឯម អនុលេខាភូមិភាគពាយព្យថ្មី ។ គាត់តាមទៅឱ្យគេទៅហៅខ្ញុំមកវិញកាំភ្លើងបើកសោ (ឮមិនច្បាស់) ខ្ញុំថា «អើស! មនុស្សជាងមួយលាននាក់ស្លាប់ទៅហើយ ខ្ញុំប្អូននាក់ទៀតអត់អីទេ ស្លាប់ទៅចុះ!» ។ ដូច្នេះចំពោះអាយុជីវិតមនុស្ស និងអាយុជីវិតប្រជាជនកាលណានឹកដល់អាយុ ជីវិតមនុស្ស ដែល ស្លាប់បាត់បង់ទៅក្នុងរបបនេះ អាយុជីវិតខ្ញុំមួយអត់ការ ។ ខ្ញុំគិតចឹង ។

នេះចំពោះអាយុជីវិតខ្ញុំ ខ្ញុំឱ្យតម្លៃប៉ុណ្ណឹង ។ ដូច្នេះ ក្នុងមួយឆ្នាំហ្នឹងខ្ញុំធ្វើអីអត់កើតទេរហូតៗ ដេកសំកុក ។ ចុងបញ្ចប់ខ្ញុំនឹកឃើញវិធីមួយគឺសែនសុំទោសជនរងគ្រោះ សែនសុំទោសឪពុកម្តាយដែលបង្កើតខ្ញុំមក ប្រាថ្នាឱ្យកូនល្អ ខ្ញុំខ្លួនឯងក៏ប្រាថ្នាសងគុណមាតាបិតា រកផ្លូវល្អ ដល់ចុងបញ្ចប់ធ្លាក់ទៅលើផ្លូវអាក្រក់ ។

ខ្ញុំបង្កើតវិធីមួយ ដើម្បីលួងអារម្មណ៍ខ្លួនឱ្យបានស្ងប់បន្តិច គឺសែនសុំទោស មុនដំបូងគ្រាន់តែសុំទោស ម្តាយឪពុកខ្ញុំ ហើយនិងគ្រូបាអាចារ្យខ្ញុំទេ ដល់យូរទៅវាជាការសែនសុំទោសជាតិប្រជាជនទាំងមូល ។ រាល់ថ្ងៃ១៧ វិច្ឆិកា ដែលជាថ្ងៃកំណើតខ្ញុំ រាល់ឆ្នាំឱ្យតែថ្ងៃ១៧ វិច្ឆិកា ខ្ញុំមិនដែលធ្វើអីកើតទេ ។ ខ្ញុំតែងធ្វើស្ទ្រីមួយបន្តិចបន្តួច សម្រាប់ជាការរំឭកនឹកដល់វិប្បដិសារីរបស់ខ្ញុំ។ ក្នុងឆ្នាំនេះ ខ្ញុំបានគូរគំនូរមួយ ប្រសិនបើលោកប្រធាន និងអង្គជំនុំជម្រះ សាលាដំបូងលោកអនុញ្ញាតខ្ញុំលើកបង្ហាញជូន ។

## ប្រតិចារឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩

### ទំព័រ១០ [បន្ទាត់១៩-២៥]

ខ្ញុំសូមជម្រាបលោកចៅក្រមដោយស្មោះថា ខ្ញុំទទួលខុសត្រូវលើឧក្រិដ្ឋកម្ម ដែលធ្វើទារុណកម្មមនុស្ស នេះ។ ចម្លើយ ដែលបានមកពីទារុណកម្មទាំងប៉ុន្មានធ្លាក់ទៅលើអាយុជីវិតអ្នកផ្សេងទៀតក៏ខ្ញុំទទួលដែរខ្ញុំអត់ប្រកែកទេ ។ គ្រាន់តែនេះ ខ្ញុំសូមបញ្ជាក់ជូនលោកចៅក្រម អំពីការពិតដែលកើតមាននៅទីនោះ ។ ទោះបីខ្ញុំ ក្នុងឋានៈខ្ញុំតាំងខ្លួន ជាស្នងការម្នាក់ ដែលបញ្ជាទៅលើអធិការក៏ដោយ ក៏ខ្ញុំនៅតែទទួលខុសត្រូវថាឧក្រិដ្ឋកម្មនេះវាកើតពីខ្លួនខ្ញុំ ។ សូមទោស ខ្ញុំងាកទៅឃើញមុខលោក ជុំ ម៉ី ខ្ញុំអត់បាន ទៅវ៉ៃ លោក ជុំ ម៉ី ទេ, មិត្ត សេងគាត់វ៉ៃ លោក ជុំ ម៉ី តែខ្ញុំបញ្ជា ឱ្យនៅលើហ្នឹង ខ្ញុំសូមទោសលោកជុំ ម៉ី ។

## ប្រតិចារឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩

### ទំព័រ១៩ [បន្ទាត់៦-១១]

ឧក្រិដ្ឋកម្មក្នុងការកម្ទេចមនុស្សទោះបីគេសម្រេចពីខាងលើមកទុកជាគោលការណ៍ហើយក៏ដោយក៏ពេលជំទាស់ណា មួយខ្ញុំធ្វើ រាល់ពេល ។ ដូច្នេះឧក្រិដ្ឋកម្មនេះ គឺវានៅលើខ្ញុំដដែល ។ ដូច្នេះហើយ បានជាពេលម្សិលមិញ ខ្ញុំនិយាយថា វិញ្ញាណក្ខន្ធជនរងគ្រោះទាំងអស់ ដែលបាត់បង់ជីវិតនៅអមលាំង ខ្ញុំនៅតែសុំខមាទោស ។ ខ្ញុំនៅតែរំឭកឈ្មោះ ឡើងវិញ ដើម្បីសរសេរសៀវភៅមួយនេះពីបញ្ហាកម្ទេច ។ ខ្ញុំអត់គេចអំពីឧក្រិដ្ឋកម្មដែលត្រូវធ្លាក់មកលើក្បាលខ្ញុំទេ ខ្ញុំទទួល ប៉ុន្តែការពិតវាបែបនេះ ។

## ប្រតិចារឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩

### ទំព័រ២៩ [បន្ទាត់១២-២៣]

ខ្មោចជនរងគ្រោះដែលសម្លាប់នៅមន្ទីរ-១៣ វាអត់ដែលទៅណាឆ្ងាយអំពីទីតាំងរបស់មន្ទីរ-១៣ ហ្នឹងទេ យ៉ាងច្រើន មួយរយម៉ែត្រ ។ ដូច្នេះមន្ទីរ-១៣ វាមានកន្លែងវាបី ។ គឺកន្លែងទីមួយនៅថ្មគុប ត្រង់ម៉្លុំ អន្លង់វែង កន្លែងទីពីរ គឺនៅ តាលាវ ដែលយើងខ្ញុំកម្ទេចឬហៅថា «សម្លាប់» តិចបំផុត ហើយកន្លែងទីបី នៅត្រពាំងត្រោប ភូមិត្រពាំងត្រោប ក៏ចន្លោះស្ទឹងនិងត្រពាំងប្រាប ។ ភស្តុតាងដែលនៅសល់ វាអាច បញ្ជាក់បានថា ខ្មោចហ្នឹងវាមានអាយុពីអង្គាលមក? ហើយវាមានចំនួនប៉ុន្មានច្បាស់លាស់? សម្រាប់ បញ្ជាក់នូវសេចក្តីដែលខ្ញុំសារភាពការស្មោះត្រង់ជូនជាតិប្រជាជនរបស់ខ្ញុំ ។ ឯចំណែកសពផ្សេងទៀត នៅកន្លែងផ្សេងទៀត វាជាសពរបស់មនុស្សខ្មែរ ជាសពខ្មែរដែលស្លាប់ទៅ ដោយសារស្នាដៃបក្ស កុម្មុយនីស្តកម្ពុជា ។ ខមាទោស ខ្ញុំសុំខមាទោសដដែល អត់ប្រកែកទេ ក៏ប៉ុន្តែទទ្ទឹម នឹងនេះខ្ញុំក៏សម្តែង ការសោកស្តាយប៉ុណ្ណោះ ហើយនិងរំលែកទុក្ខចំពោះក្រុមគ្រួសារញាតិមិត្តនៃសព ។

## ប្រតិចារឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩

### ទំព័រ៤៤ [បន្ទាត់២១-២៥] ដល់ទំព័រ៤៥ [បន្ទាត់១-៧]

លោកប្រធានជាទីគោរព! ការសោកស្តាយ ការឈឺចាប់ វាអត់ស្រាកស្រាន្តទេ វាអត់ស្ងប់ទេ ។ វាអត់ស្ងប់ទេ ។ កាលណានឹកដល់រឿងចាស់ ខ្ញុំនៅស្មោះត្រង់នឹងវិប្បដិសារីរបស់ខ្ញុំជានិច្ច ។ ខ្ញុំមិនក្បត់វិប្បដិសារីរបស់ខ្ញុំ ខ្ញុំមិនលុប បំបាត់វិប្បដិសារីខ្ញុំនេះ ចោលទទេៗទេ ខ្ញុំចងចាំជានិច្ច ខ្ញុំឈឺចុកចាប់ណាស់ ខ្ញុំតែងតែនិយាយថា សម្រេចខុស គឺ សម្រេចតែមួយដង្ហើមទេ តែរងទុក្ខ រងការឈឺចាប់ រងការសោកស្តាយមួយជីវិត ។ ដូច្នេះការដែលខ្ញុំឱន ក្បាលចូល មកទទួលជំនុំជម្រះនេះ គឺជំនុំជម្រះចំពោះ ឧក្រិដ្ឋកម្មដែលខ្ញុំធ្វើ។ ខ្ញុំមិនឆ្លើយទម្លាក់កំហុសទាំងស្រុងនៅលើមេទេ ទៅលើមេខ្ញុំទេ ហើយក៏មិន ទម្លាក់កំហុសទៅលើកូនចៅខ្ញុំដែរ មានន័យថា ខ្ញុំអត់គេចយករួចខ្លួនទេ ។ ឧក្រិដ្ឋកម្មនេះ ថ្វីត្បិតតែមាន តួនាទីរបស់មេ ក៏វាមានតួនាទីរបស់ខ្ញុំដែរ នៅស-២១ឧក្រិដ្ឋកម្មទាំងអស់ខ្ញុំទទួលតែម្នាក់ឯង គ្មានគេច គ្មានទម្លាក់កំហុសទៅលើកូនចៅទាល់តែសោះ កំហុសឧក្រិដ្ឋកម្មទូទាំងប្រទេស ដូចដែលខ្ញុំបានថ្លែង ការណ៍នៅពេល បើកសវនាការនេះអ៊ីចឹង ។ ខ្ញុំទទួលខុសត្រូវខាងផ្លូវចិត្ត ចំពោះការវិនាសហិនហោចរបស់ប្រជាជនកម្ពុជាយើងទាំងមូល ខ្ញុំរំលែកទុក្ខវេទនា សុំរំលែកទុក្ខ។

## ប្រតិចារឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩

### ទំព័រ៤៦ [បន្ទាត់២-១២]

ខ្ញុំសូមអនុញ្ញាតបន្តទៅទៀត។ការអនុវត្តនយោបាយនេះនៅទូទាំងប្រទេសក៏ដូចជានៅស-២១។ នៅស-២១ វាមាន ឧក្រិដ្ឋកម្មទៅលើមនុស្ស យ៉ាងតិចណាស់ក៏មួយម៉ឺនពីរពាន់បីរយប៉ែតសិប (១២៣៨០) នាក់ដែរ នៅទូទាំងប្រទេស ខ្ញុំមិនទាន់មានតួលេខច្បាស់លាស់ទេ តែខ្ញុំជឿថាជាងមួយលាននាក់ នេះជាការអនុវត្តមាគ៌ានយោបាយខុស ។ ខុសនេះ ខ្ញុំខុសនឹងគេដែរ មិនមែនរឿងមេតែម្នាក់ឯងទេ មានតួនាទីរបស់ខ្ញុំនៅក្នុងហ្នឹង ទូទាំងប្រទេស តួនាទីរបស់ខ្ញុំ ក្នុងថ្នាក់ ជាសមាជិកបក្សម្នាក់ ខ្ញុំអត់ចោលទេ ការទទួលស្គាល់កំហុសនេះ កំហុសនេះ គឺពិតជាកំហុសក្នុង ការអនុវត្តមាគ៌ានយោបាយហើយ ។ នៅស-២១ កំហុសនេះកំហុសនៃការអនុវត្តមាគ៌ានយោបាយរបស់បក្ស ដែលជាមាគ៌ាមហាឧក្រិដ្ឋ ដូចខ្ញុំបានបញ្ជាក់ព្រឹកមិញអ៊ីចឹង ឧក្រិដ្ឋជាងមាគ៌ារបស់ពួកអាក្រុមបួននាក់នៃមហាបដិវត្តន៍វប្បធម៌ចិនតទៅ ធ្វើឱ្យប៉ះពាល់ដល់អាយុជីវិតមនុស្សជាងមួយម៉ឺននាក់ ។ ខ្ញុំចាំអត់ភ្លេចទេរឿងអស់ទាំងនេះ ។ នេះសូមសារភាពជូនតុលាការជូនជាតិប្រជាជនកម្ពុជា ឱ្យលោកយល់បញ្ហានេះ ។ នេះខ្ញុំអត់ចោលទេវិប្បដិសារី។ វិប្បដិសារី គឺក្នុងការអនុវត្តមាគ៌ានយោបាយខុសនេះឯង នេះខ្ញុំសុំ បញ្ចប់ប៉ុណ្ណេះ។

## ប្រតិចារឹកថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩

### ទំព័រ៦៧ [បន្ទាត់២-៩]

សូមសរុបមកវិញ រូបថតដែលខ្ញុំអង្គុយបង្រៀនឯកសារហ្នឹង បើមើលអាតឡូវនេះទៅ វាហាក់ដូចជាជំនាន់នោះ ខ្ញុំវាសម្បើមណាស់ ភ្ញាក់រំឭកវណ្ណៈ ។ ក៏ប៉ុន្តែ តាមពិត ដល់មើលអាតឡូវ វិភាគឱ្យមែនទែន គឺជារូបថតមួយគួរឱ្យ ខ្មាស់អៀន គួរឱ្យតក់ស្លុតនឹងឧក្រិដ្ឋកម្មដែលខ្ញុំបានប្រព្រឹត្តិទៅលើមនុស្ស ជីវិតមនុស្សមួយម៉ឺនពីរពាន់បីរយផ្លាយនាក់ ។

ដូច្នេះ ខ្ញុំសូមទទួលទាំងអស់ ឧក្រិដ្ឋកម្មនៅស-២១ ទាំងប៉ុន្មាន ។ ទន្ទឹមនេះ ខ្ញុំជំពាក់បក្ខជនម្នាក់ខ្ញុំតក់ស្លុត នឹងការ បាត់បង់អាយុជីវិតប្រជាជនកម្ពុជាជាងមួយលាននាក់ ។ ខ្ញុំទទួលខុសត្រូវខាងផ្លូវចិត្តចំពោះការបាត់បង់អាយុជីវិត ប្រជាជនទាំងមួយលានជាងនាក់ ជារៀងរហូត ។ ហ្នឹងខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

## ប្រតិចារឹកថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩

### ទំព័រ៧០ [បន្ទាត់៩-១៦]

ជម្រាបប្រសាសន៍លោក ម៉េង ចំពោះរូបលោកម្នាក់ ខ្ញុំក្តុកក្តួលណាស់ យើងធ្លាប់រស់នៅជាមួយគ្នា សុខភាពលោក ល្អ ខ្ញុំតក់ស្លុតណាស់ នៅពេលដែលជួបលោកពីអង្គាល់ថ្ងៃ២៨ កុម្ភៈ ២០០៨ នៅមុខលោកចៅក្រមស៊ើបអង្កេត ។ ខ្ញុំចង់បំពេញបំណងរបស់លោកឱ្យច្បាស់ ក៏ប៉ុន្តែវាហួសសមត្ថភាពខ្ញុំ ។ ការងារជាក់ស្តែងបែបនេះ គេអ្នកធ្វើខាង ក្រោម ។ ក៏ប៉ុន្តែខ្ញុំសុំសន្និដ្ឋានជូនលោកថា ប្រពន្ធលោកប្រហែលជាអាចទៅឯបឹងជើងឯកឯណោះ នេះគឺខ្ញុំសុំសន្និដ្ឋាន ប៉ុណ្ណឹង ។ ទន្ទឹមនេះខ្ញុំក៏ចង់ឱ្យកាន់តែច្បាស់ទៅទៀត សុំអង្វរកចិត្តលោកសាយសេចក្តីមេត្តាដល់មិត្តហ៊ុយ ទៅសួរវាបើសិនជាវាអាចជួយលោកប្រហែលជាមានប្រសិទ្ធភាពជាងខ្ញុំនេះខ្ញុំសុំជម្រាបប៉ុណ្ណឹង។ សូមលោកមេត្តា ទទួលនូវ សេចក្តីគោរពរបស់ខ្ញុំចំពោះវិញ្ញាណក្ខន្ធប្រពន្ធលោក ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

## ប្រតិចារឹកថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩

### ទំព័រ៧២ [បន្ទាត់១១-២១]

នេះខ្ញុំសូមបញ្ជាក់ ជូនជាតិ ប្រជាជនកម្ពុជាថា ឧក្រិដ្ឋកម្មនេះធ្ងន់ធ្ងរណាស់ វាជាឧក្រិដ្ឋកម្មរបស់អ្នកខាងលើក៏ពិតមែន ក៏ប៉ុន្តែកម្លាំងអ្នកខាងក្រោមដែលជាបក្ខជនវានៅមានក្នុងនុ៎ង ក្នុងទូទាំងប្រទេស មនុស្សអស់ជាងមួយលាននាក់ ។ ខ្ញុំក្នុងឋានៈជាបក្ខជនមួយរូបខ្ញុំអត់គេចទេ សុំទទួលខុសត្រូវចំពោះខាងផ្លូវចិត្តចំពោះវិញ្ញាណក្ខន្ធទាំងអស់។ ដោយឡែកនៅមន្ទីរស-២១ជីវិតមនុស្សជាងមួយម៉ឺននាក់ ខ្ញុំទទួលខុសត្រូវខាងផ្លូវច្បាប់ អោនក្បាលជូន អ.វ.ត.ក ជំនុំជម្រះ ខ្ញុំតែម្នាក់ឯងក្នុងក្របខណ្ឌមន្ទីរស-២១ គ្មានឱ្យទាក់ទងដល់កូនចៅណាទេ ។ នេះខ្ញុំទទួលប៉ុណ្ណឹងទាំងស្រុង ។ ហើយ វិញ្ញាណក្ខន្ធអ្នកទាំងអស់នោះ បានអធិដ្ឋានជូនគេជាប់លាប់ជាប្រចាំខ្ញុំអត់ភ្លេចទេ។ ដូច្នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។ និយាយនេះ ដើម្បីមិនមែនគេចកែអំពីទារុណកម្មអំពីឧក្រិដ្ឋកម្មរបស់ខ្លួនទេ និយាយលាតត្រដាងឱ្យវាឃើញថាទទួលស្គាល់ឧក្រិដ្ឋកម្មត្រឹមកម្រិតណា? ហើយនេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

## ប្រតិចារឹកថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩

### ទំព័រ៦៦ [បន្ទាត់១៨-២៥] ដល់ទំព័រ ៦៧ [បន្ទាត់១-៣]

ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់តាម ដែលការខ្ញុំបានស្តាប់សក្ខីកម្មរបស់លោក នង ចាន់ផលនេះ ។ ដំបូងខ្ញុំសូមទទួលស្គាល់ថា សក្ខីកម្មនេះ វាបញ្ចាំងឱ្យឃើញទុក្ខវេទនា ការនិរាសប្រាសព្រាត់របស់លោកនង ចាន់ផល ពិតប្រាកដមែន ។ ដំបូង នៅពេលដែលមុនឹង ឃើញឯកសារជីវប្រវត្តិរបស់លោក នង ចិន ជាឪពុកលោក នង ចាន់ផល ខ្ញុំគិតថា ឧក្រិដ្ឋកម្ម នេះវានៅក្រៅ ស-២១ ទេ ។ ប្រហែលជាលោក នង ចិន រងទុក្ខវេទនា នៅមន្ទីរ នគរបាល មួយផ្សេងទៀត ។ ដល់ឃើញប្រវត្តិរូបរបស់លោកនង ចិន ដែលចុះនៅលេខ TSL បានន័យ ថាទួលស្លែង លេខ 0529 ខ្ញុំទទួលស្គាល់ហើយ ថាលោកនង ចិន ពិតជាមកស្លាប់នៅកន្លែង នេះ ។ ដោយឡែកម្តាយរបស់លោកនង ចាន់ផល អត់ទាន់ឃើញឯកសារអីទេ ។ ដូច្នេះខ្ញុំសូម ញែកបញ្ហានេះជាពីរ ។ ទីមួយ បើសិនជាមានប្រវត្តិរូបអីចឹងមក ទៀត និយាយអំពីម្តាយលោក នង ចាន់ផល លទ្ធភាពវាតែម្យ៉ាង គឺវាត្រូវស្លាប់ទាំងអ្នកមីងមុំ យៅ ហើយវាស្លាប់ទាំង លោកនង ចាន់ផល និងប្អូនផង ។ ស-២១ អត់ដែលទុកកុមារទេ ។ នេះខ្ញុំសូម ជម្រាបលោកដោយត្រង់ ។ នេះ លទ្ធភាពវាទៅអីចឹង ។

## ប្រតិចារឹកថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩

### ទំព័រ៤ [បន្ទាត់២-៦]

ជម្រាបប្រសាសន៍លោកប្រធាន! សូមគោរពអង្គជំនុំជម្រះសាលាដំបូងជាទីគោរព! ឯកសារនេះ ខ្ញុំទទួលស្គាល់ ។ ទីមួយ ជាឯកសារនៅទួលស្លែង ដោយមាន TSL ជាភស្តុតាងស្រាប់ ហើយ ទីពីរអក្សរដៃ ខ្ញុំទទួលស្គាល់ទៀតថា ពិតជាអក្សរដៃបុគ្គលិករបស់មន្ទីរស-២១ ។ ទន្ទឹមនេះ តាមរយៈអង្គសវនាការយើងនេះ ខ្ញុំសូមទោសដល់លោក នង ចាន់ផល ដែលពេលនោះខ្ញុំ មិនទាន់ឃើញឯកសារ ខ្ញុំមានការខុសឆ្គងទៅលើគាត់ខ្លះ ។ ដូច្នេះ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

## ប្រតិចារឹកថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩

### ទំព័រ៨០ [បន្ទាត់១៤-២១]

សរុបមកខ្ញុំជឿថា មិត្តម៉េត ជិន ម៉េត នេះរងទុក្ខវេទនាដែលគេឃុំឃាំងសួរចម្លើយនៅកង ៤៥០ ។ ខ្ញុំនិយាយ យ៉ាងនេះ មិនមែនចង់បដិសេធឧក្រិដ្ឋកម្មខ្លួនឯងទេ ក៏ប៉ុន្តែការបញ្ជូនទៅស-២១ តែ

បញ្ជូនចូលទៅដល់អា មជ្ឈមណ្ឌល គុកនៅភ្នំពេញហើយ អត់ចេញទេ មិត្តម៉េត គឺមិត្តនៅនុំង ខ្ញុំយកទៅដើងឯកហើយ ។ ដូច្នេះខ្ញុំទទួលស្គាល់ថា មិត្តចេញ ពី៤៥០ ទៅចូលព្រៃស ។ នេះ គឺប៉ុណ្ណឹងដូច្នេះបានជាខ្ញុំពិបាកនឹងនេះ ។ សរុបមកខ្ញុំមិនបដិសេធឧក្រិដ្ឋកម្មអីទេ ក៏ប៉ុន្តែ ចង់ បញ្ជាក់ថា ការប្រតិបត្តិជំនាន់នុំងវាអីចឹងចេញ ពីកងពលឱ្យតែទៅចូលក្នុងស-២១ភ្នំពេញ ហើយ អត់មានអ្នកណានៅរស់ទេ គ្មានសល់បានរស់ទេ ស្លាប់អស់ហើយ ។ នេះខ្ញុំគ្រាន់តែសុំបញ្ជាក់ ប៉ុណ្ណេះសុំចប់ ។

## ប្រតិចារឹកថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩

### ទំព័រ៣២ [បន្ទាត់១៦-១៧]

ជម្រាបប្រសាសន៍លោកមេធាវី! ចំពោះករណី មិត្តម៉េត ខ្ញុំអត់ទទួលខុសត្រូវខាងផ្លូវចិត្តទេខ្ញុំ ទទួលខុសត្រូវពេញមុខ ចំពោះឧក្រិដ្ឋកម្មនេះតាមផ្លូវច្បាប់ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។ សូមចប់ ។

## ប្រតិចារឹកថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩

### ទំព័រ៤១ [បន្ទាត់៩-១២]

លោកប្រធានជាទៅគោរព! ខ្ញុំសូមជូនជាសេចក្តីសង្កេតដូចតទៅ៖

ទីមួយ ទុក្ខវេទនារបស់ប្រជាជនកម្ពុជាទូទាំង ប្រទេសជំនាន់នោះ ខ្ញុំអត់គេចទេ ខ្ញុំពិតជា ទទួលខុសត្រូវខាងផ្លូវចិត្ត ។ ដោយឡែកជនរងគ្រោះទាំងឡាយណា ដែលបាត់បង់ជីវិតនៅមន្ទីរ ស-២១ ខ្ញុំទទួលខុសត្រូវទាំងពីរ ទាំងផ្លូវច្បាប់ទាំងផ្លូវចិត្ត ។

## ប្រតិចារឹកថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩

### ទំព័រ៤២ [បន្ទាត់២១-២២]

ខ្ញុំមិនទាមទារឱ្យកូនចៅណាម្នាក់មកជាមួយនិងខ្ញុំ នៅទីនេះប្រឈមមុខនឹងតុលាការទេ ។ ខ្ញុំ ទទួលខុសត្រូវចំពោះមុខ ច្បាប់ និងខាងផ្លូវចិត្តតែម្នាក់ឯងក្នុងក្របខ័ណ្ឌ ស-២១ ។

## ប្រតិចារឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩

### ទំព័រ៤០ [បន្ទាត់២-២៥] ដល់ទំព័រ ៤១ [បន្ទាត់១]

លោកប្រធានជាទីគោរព! សក្ខីកម្មរបស់អ្នកស្រី ប៊ូ ថុន វាចេញមកពីចិត្តក្លាហានរបស់គាត់ ដែលនិយាយការពិត ហើយវាចេញមកពីទុក្ខវេទនាដែលនៅរុំរ៉ៃក្នុងខ្លួនគាត់ច្រើនឆ្នាំហើយ ។ កូនអស់បីបួននាក់ ។ បីនាក់ស្លាប់ដោយ មិន ដឹងរឿង ហើយកូនចុងក្រោយត្រូវស្លាប់នៅក្នុងដៃក្នុងពេលរត់ ។ នេះក៏សន្មតថាអស់បួននាក់ទាំងស្រុង ។ ខ្ញុំទទួលថាទាំងបួននាក់ ។ ប្តីក៏អស់ ។ ខ្ញុំអត់និយាយ លើកកំហុសថា នេះគឺមកពីអ្នកស្រីជាសមាសភាព១៧ មេសា ទេ ។ ជាមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា មនុស្ស១៧ មេសា គេអស់យកប្រើទេ ក៏ប៉ុន្តែប្រហែលជា កុយ ធួន ធ្វើខុសមាគ៌ា ។ ក៏ប៉ុន្តែ ការសម្លាប់មនុស្សដែលមាននៅក្នុងជួរហើយ វាជារឿងមួយស្ថិតនៅក្នុងអាណត្តិដែល ប៉ុល ពត កាន់កាប់ ។ ដូច្នេះ សម្រេចយកលោក ភោគ ហ៊ន យកចេញពីក្រសួងថាមពល ក៏អចិន្ត្រៃយ៍សម្រេច ។ សូមបញ្ជាក់ថា ក្រសួងថាមពលនៅពេលក្នុងឆ្នាំ១៩៧៦ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ ទៅប្តូរអ្នកដឹកនាំហើយ មិនមែននៅលើបង វិទ្ធ តទៅទៀតទេ គឺនៅលើបង អ៊ុក ហើយនិងមិត្តឆុន ។ ក៏ប៉ុន្តែ ប្តូរអ្នកណាក៏ដោយមាគ៌ាវានៅតែជាមាគ៌ារបស់បក្ស ។ ដូច្នេះ កាលដែលយកលោក ភោគ ហ៊ន ចេញមកក៏ជាមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា ហើយប្រគល់មកគឺគ្មាន ប្រគល់ ទៅណាទេ បញ្ជីមានច្បាស់ហើយ ភោគ ហ៊ន នៅចូលមកដល់ស-២១ ។ ដោយឡែកតែកុមារបីនាក់ ដែលជា កូនរបស់លោក ភោគ ហ៊ន និងអ្នកស្រី ប៊ូ ថុន អត់មានបញ្ជីក៏ពិតមែន ខ្ញុំក៏ជឿដូចអ្នកស្រី ប៊ូ ថុន ដែរ ថាអត់ទៅណាទេ នៅនុំង ។

ដូច្នេះ មួយឆ្នាំៗ អ្នកស្រីអញ្ជើញទៅបឹងជើងឯក អត់ខុសទេកន្លែងហ្នឹង សពប្តីអ្នកស្រី សពកូនអ្នកស្រីគឺនៅទីនោះ ។ កំហឹងធ្លាយពេលនេះ គឺពិតជាកំហឹងរបស់ប្រជាជនកម្ពុជាម្នាក់ ។ ក្នុងចំណោមប្រជាជនកម្ពុជារាប់លាននាក់ដែលបាត់បង់ប្តី ស្រី កូន ចៅ នៅពេលនោះ ខ្ញុំទទួល ។ ទឹកភ្នែកនេះ ជាទឹកភ្នែកសុចរិត ។ ខ្ញុំទទួលដោយគោរព បើសិន និយាយពីទោសកំហុសនិងការសោកស្តាយ ចង់ជាតិប្រជាជនកម្ពុជា ចង្អុលមុខខ្ញុំយ៉ាងម៉េច ថ្កោលទោសយ៉ាងម៉េច សូមអញ្ជើញចិត្តប្រជាជនកម្ពុជាលោកធ្វើចុះ។ បើសិនជាមានទំនៀមទម្លាប់ខ្មែរ ដូចជំនាន់ ក្រោយពីព្រះយីស៊ូគ្រីស្តសុគតទៅបន្តិច គេគប់ដុំថ្មទៅលើស្តេហ្វាន់ ទៅលើ អេចែន ។ ប្រជាជនកម្ពុជាលោកធ្វើអ្វីចឹងចំពោះខ្ញុំក៏ខ្ញុំទទួលដែរ ។ ជីវិតខ្ញុំមួយ ប្រៀបធៀបនឹងជីវិតប្រជាជនដែលបាត់បង់ជីវិតទៅនៅក្នុងពេលនោះរាប់លាននាក់ ខ្ញុំអត់មានឃើញជីវិតខ្ញុំ ថ្លៃថ្នូរអីទេ....

## ប្រតិចារិកថ្ងៃទី១៧ សីហា ២០០៩

### ទំព័រ៣៣ [បន្ទាត់៥-២២]

លោកប្រធានជាទីគោរព! ដំបូងខ្ញុំសូមអនុញ្ញាតនិយាយទៅរកអ្នកស្រី លើហ្វីវ ដូចតទៅ៖

ខ្ញុំសូមទទួលស្គាល់ថា ប្រវត្តិរូបរបស់ក្រុមគ្រួសារលោកស្រី វាជាសច្ចធម៌ប្រវត្តិសាស្ត្រ ដែលខ្ញុំនិយាយថា សច្ចធម៌ ប្រវត្តិសាស្ត្រព្រោះវាមានលក្ខណៈអមតៈ ។ បានន័យថា ពេលណាគេចង់ស្រាវជ្រាវអំពីទុក្ខវេទនារបស់ប្រជាជនខ្មែរ គេរត់ទៅរត់ទៅរកឯកសាររបស់អ្នកស្រី លើហ្វីវ នេះពិតប្រាកដ ។ ដូច្នេះសច្ចធម៌ពិតប្រាកដវាប្លែកពីផ្កា ។ ផ្កាវាមាន អាយុកាលរបស់វា វាចេះរីកវាចេះរោយ ឯចំណែកសច្ចធម៌ប្រវត្តិសាស្ត្រវាអត់ចេះរីកចេះរោយទេ វាជាសច្ចធម៌ជារៀងរហូត ។ ទុកវេទនារបស់ប្រជាជនកម្ពុជាក្នុងនោះមានទុក្ខវេទនារបស់អ្នកស្រី លើហ្វីវ ហើយនិងកូនៗ ។ ជាសច្ចធម៌ប្រវត្តិសាស្ត្រដែលមនុស្សលោកបំភ្លេចមិនបាន ។ នេះខ្ញុំសូមទទួលស្គាល់ប៉ុណ្ណេះ ។ តទៅនេះខ្ញុំសូមជម្រាបបញ្ជាក់ជូនអ្នកស្រី លើហ្វីវ ក៏ដូចជាជូនអង្គជំនុំជម្រះ ក៏ដូចជាជូនជាតិប្រជាជនកម្ពុជាថា ខ្ញុំអត់គេចទេ ខ្ញុំដាក់ខ្លួនជូនតុលាការវិនិច្ឆ័យ ។ ឧក្រិដ្ឋកម្មនេះពិតជាមិនអាចអត់ឱនឱ្យបានជាតិប្រជាជនកម្ពុជា លោក ចង្អុលមុខខ្ញុំយ៉ាងម៉េច ចង្អុលចុះ ស្តីបន្ទោសខ្ញុំយ៉ាងម៉េចស្តីបន្ទោសចុះ ថ្កោលទោសយ៉ាងម៉េច ថ្កោលទោសចុះ ។ ឯកចំណែកតុលាការក៏មាននៅទីនេះស្រាប់ ដែលខ្ញុំប្រគល់ខ្លួនជូន ។ ឧក្រិដ្ឋកម្មនៅ ស-២១ ខ្ញុំទទួលខុសត្រូវទាំងខាងផ្លូវច្បាប់ ទាំងខាងផ្លូវចិត្ត ឯចំណែកឧក្រិដ្ឋកម្មទូទាំងប្រទេសខ្ញុំទទួលខុសត្រូវតាមផ្លូវចិត្ត នេះសូមបញ្ជាក់ប៉ុណ្ណឹង ។ ខ្ញុំអត់ប្រកែកទេ មួយជំហាន គឺ អត់ប្រកែកទេ ។ ចំពោះមុខនេះ គឺខ្ញុំសូមទោសអ្នកស្រី លើហ្វីវ ហើយនិងបុត្រី ដែលមានមុខនៅទីនេះ តាមរយៈនេះ ក៏ដូចសូមទោសស្រីមេម៉ាយទាំងអស់នៅកម្ពុជា ហើយនិងកូនកំព្រាទាំងអស់ដែលកំព្រាឪពុកនៅកម្ពុជាដែរ ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ដោយគោរព ។

## ប្រតិចារិកថ្ងៃទី១៧ សីហា ២០០៩

### ទំព័រ៥១ [បន្ទាត់២០-២៥] ដល់ទំព័រ ៥២ [បន្ទាត់១-៦]

លោកប្រធានជាទីគោរព! ខ្ញុំសូមអនុញ្ញាតនិយាយទៅរកកញ្ញា អ៊ុក នារី ដោយផ្ទាល់ ដូចតទៅ៖
ទីមួយខ្ញុំសូមលំឱនកាយចិត្តទទួលស្គាល់សក្ខីកម្មរបស់ អ៊ុក នារី ក្នុងឋានៈជាក្មេងកំព្រាមួយរូបដែលបាត់បង់ឪពុក នៅ ស-២១។ សក្ខីកម្មទាំងអស់នេះ វាមានតម្លៃណាស់ វាជាឯកសារប្រវត្តិសាស្ត្រមួយសម្រាប់ក្មេងជំនាន់ ក្រោយតទៅ ទៀតកុំឱ្យភ្លេច កុំឱ្យមនុស្សជាតិយើងវាធ្លាក់ទៅក្នុងឧក្រិដ្ឋកម្មបែបនេះតទៅទៀតនោះ ។ ទៅថ្ងៃមុខយើងអាច នឹងឮ សក្ខីកម្មរបស់ក្មេងកំព្រាឪពុកជាច្រើនតទៅទៀត ខ្ញុំរង់ចាំទទួលស្តាប់ទាំងអស់ ។ នេះបញ្ហាទីមួយ ។

បញ្ហាទីពីរ គឺឧក្រិដ្ឋកម្មរបស់ស-២១ ទៅលើជាតិប្រជាជនកម្ពុជាខ្ញុំនិយាយហួរហែហើយ ក៏ប៉ុន្តែ ឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើអ្នកនៅរស់ដែលជាក្មេងកំព្រា ខ្ញុំសូមបញ្ជាក់ថាអត់ប្រកែកទេ ខ្ញុំទទួលខុសត្រូវទាំងចំពោះ មុខច្បាប់ ទាំងខាងផ្លូវចិត្តលើឧក្រិដ្ឋកម្មទាំងអស់នេះ នៅចំពោះមុខក្មេងកំព្រាគ្រប់រូបដែល មានមុខនៅទីនេះ ដែលបាន ដាក់បណ្ដឹងប្បវេណីហើយក្ដី ដែលអត់បានដាក់បណ្ដឹងរដ្ឋប្បវេណីក្ដី ខ្ញុំសូមទទួលខុសត្រូវចំពោះមុខ ច្បាប់និងខាង ផ្លូវចិត្ត ។ ខ្ញុំសូមគោរពបញ្ចប់សេចក្ដីបញ្ជាក់របស់ខ្ញុំប៉ុណ្ណេះ ដោយគោរព ។

## ប្រតិចារិកថ្ងៃទី១៧ សីហា ២០០៩

### ទំព័រ៨៤ [បន្ទាត់៣-២៥]

លោកប្រធានជាទីគោរព! ដំបូងខ្ញុំសូមទទួលស្គាល់ថា ទុក្ខសោករបស់គ្រួសារ ហាមីល ទាំងមូលរួមទាំងទុក្ខសោករបស់គ្រួសារ ដូហ៊ើស វាកើតចេញមកពីមរណភាពរបស់ ឃេរី ហើយនិង ចន ដូហ៊ើស នៅស-២១ ។ ទុក្ខសោកនេះធំធេង និងជ្រាលជ្រៅណាស់ ស្លាប់មនុស្សពីរនាក់នៅស-២១ វាបណ្ដាលឱ្យទុក្ខសោក គ្រួសារ ពីរ ។ គ្រួសារមួយទៅ ណូវែលហ្សឺឡង់ គ្រួសារមួយនៅអង់គ្លេស ។ ទុក្ខសោករបស់ប្រជាជនកម្ពុជាធំធេង ។ ទុក្ខ សោករបស់គ្រួសារពីរនេះ វាជាវត្ថុមួយដែលបង្ហាញ ឱ្យឃើញថា ប្រជាជនកម្ពុជាគ្រប់រូប សុទ្ធតែរងទុក្ខរបៀបនេះ គ្រប់គ្នា ។ ក្នុងឋានៈខ្ញុំជាអ្នកដឹកនាំស-២១ ខ្ញុំអត់គេចពីស្មារតីទទួលខុសត្រូវទេ ទទួលខុសត្រូវ ទុកឱ្យជនរងគ្រោះទាំងអស់និងក្រុមគ្រួសារលោកចង្អុលមុខខ្ញុំចុះ ដូច រ៉ូប៊ីត ធ្វើចំពោះខ្ញុំ ខ្ញុំមិនតូចចិត្តទេ ។ អញ្ជើញចុះ ។ នេះជាសិទ្ធិ របស់លោកហើយ ខ្ញុំទទួលដោយគោរព ។

ក្នុងឋានៈខ្ញុំជាអ្នកទទួលខុសត្រូវចំពោះមុខឧក្រិដ្ឋកម្មបែបនេះ ខ្ញុំបាននិយាយជូនអង្គសវនាការរួចមកហើយថា ទោះបីជាតិប្រជាជន លោកគំជុំថ្មខ្ញុំឱ្យស្លាប់ ដូច ស្ដេហ្វាន ដែលបារាំង ហៅថា អ៊ីចៃន ក៏ខ្ញុំទទួល ។ មិនមែនថា ខ្ញុំអស់សង្ឃឹមនឹងជីវិតរកធ្វើអត្តឃាត គឺអត់ទេ ខ្ញុំអត់មានបំណងប្រាថ្នានោះទេ ក៏ប៉ុន្តែយើង មើល ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ អ្នកដែលគេបំពេញភារកិច្ចមិនបានតាមបំណងទេ ដូចជា អេរ៉ែត វ៉ាហ្គុត អ្នកគំនូរ គូរមិនបានតាមចិត្តគាត់ គាត់កាត់ស្លឹកត្រចៀក បិទប៉ង់ស៊ីម៉ង់ត៍ ហើយគូររូបវិញតទៅទៀត ។ នៅជប៉ុនថ្មីៗនេះ ប្រហែលជាមួយឆ្នាំពីរមុននេះ មានអ្នកឯកទេសម្នាក់ គេធ្វើអត្តឃាតព្រោះមើលប្លង់ដែលបន្លំនោះមិនទាន់ ។

ដូច្នេះ ខ្ញុំផ្ទាល់ខ្លួន ដែលធ្វើបដិវត្តន៍គឺដើម្បីរំដោះជាតិ ។ ក៏ប៉ុន្តែ ចុងបញ្ចប់ទៅជាវិនាសអន្តរាយប្រទេសជាតិខ្លួនឯង ។ ជីវិតមនុស្សស្លាប់ជាងមួយលាននាក់ មួយលាននាក់ស្លាប់ តើអ្នករងទុក្ខវេទនាដែលនៅសល់ប៉ុន្មាន ។ ដូច្នេះ ខ្ញុំហ៊ាន ធ្វើខ្ញុំហ៊ានទទួលខុសត្រូវ ទោះបីជាប្រជាជនលោកដាក់ទោសខ្ញុំប៉ុនណា ក៏ខ្ញុំអត់ប្រកែកទេ ដែលខ្ញុំចេញមុខ មកបង្ហាញ ខ្លួន សុំទទួលការជំនុំជម្រះពីអង្គជំនុំជម្រះនេះ ក៏ដោយស្មោះ ដោយស្ម័គ្រ ដោយឈឺចាប់នឹងកំហុសរបស់ខ្លួន នេះ

គឺ និយាយទៅតាមពិត អត់មានកែកាឡៃថា យកពាក្យមកដោះសារដើម្បីប្តូរបាច់ស្អី គឺអត់មានទេ ។ នេះគឺជាសុទ្ធចិត្ត ដែលខ្ញុំសូមលំអោនចំពោះជាតិប្រជាជនកម្ពុជាទាំងមូលមកដាក់ខ្លួនចំពោះមុខតុលាការនេះប៉ុណ្ណោះ។ សូមគោរពបញ្ចប់ប៉ុណ្ណោះ ។

## ប្រតិចារឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩

### ទំព័រ២៧ [បន្ទាត់២-១៨]

លោកប្រធានជាទីគោរព! ដំបូង ខ្ញុំសូមអនុញ្ញាតលោកប្រធានថ្លែងសេចក្តីគោរពយ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកជំទាវ មាស កេត ដែលលោកចាស់ហើយ លោកបានអញ្ជើញមកនៅទីនេះ ។ នេះជាកិត្តិយសមួយសម្រាប់ខ្ញុំ ។ លោក ជំទាវ មាស កេត ចាស់ជាងម្តាយខ្ញុំបីឆ្នាំ ។ លោកអញ្ជើញមក ខ្ញុំសូមអរគុណ ហើយសូមថ្វាយបង្គំលោកពីចម្ងាយ ។ នេះជារឿងមួយ ។ ឯចំណែករឿង ជូឡុង រង្សី ខ្ញុំដឹងតាំងពីខ្ញុំនៅធ្វើអាអនុប្រធានម៉្លេះ ។ ខ្ញុំស្គាល់សំឡេង រង្សី តាំងពីខ្ញុំនៅជាប់គុក ឮសូរសំឡេងតាមវិទ្យុ ។ ដូច្នេះ ជូឡុង រង្សី ចូលមកដល់ស-២១ ខ្ញុំអត់បានទៅអើតមើលមុខគាត់ យ៉ាងម៉េចទេ ខ្ញុំឃើញដែលខ្ញុំឡើងធ្វើប្រធានហើយ ឯកសារគឺចប់បាត់ហើយ ។ ពេលនោះ ខ្ញុំជម្រាបដោយត្រង់ ខ្ញុំស្មានតែមកជាប់តែ រង្សី ទេ លឹមគី ម៉ារី គេនៅឯស្រុកបារាំងឯណោះ ។ ដល់ក្រោយមក ខ្ញុំឃើញឱទាំងពីរនាក់ជាប់ពីអង្គាល់។ នេះពីរឿងផ្ទាល់ខ្លួនខ្ញុំដែលដឹងអំពីរឿងនេះ។ដោយឡែកសក្ខីកម្មរបស់អង់តូនីញ៉ាជាសក្ខីកម្មរស់ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររស់ជាទុក្ខវេទនារបស់ក្រុមគ្រួសារមួយដែលបាត់បង់មនុស្សពីរនាក់ ។ នេះវាជាឯកសារប្រវត្តិសាស្ត្រដែលមានលក្ខណៈអមតៈ ដែលអាចទុកជាកេរដំណែលឱ្យអ្នកស្រាវជ្រាវជំនាន់ក្រោយលោកដឹងថា ឧក្រិដ្ឋកម្មជំនាន់នេះ វាយ៉ាងម៉េច ប៉ះពាល់ដល់គ្រួសារណាខ្លះ គ្រួសារនីមួយៗ វាមានការចុកចាប់ប៉ុនណា ខ្ញុំសូមទទួលស្គាល់ថា នេះជាការពិត ។ ដោយឡែកចំពោះរូបខ្ញុំខ្ញុំនៅតែរក្សាពាក្យដដែលអត់វេចវេរស្មារតីទទួលខុសត្រូវចំពោះមុខឧក្រិដ្ឋកម្មនេះទេ។សូមជម្រាបលោកជំទាវដោយស្មោះ ។ សូមជម្រាបអ្នកស្រីដោយស្មោះ ។សូមគោរព សូមចប់ ។

## ប្រតិចារឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩

### ទំព័រ៤១ [បន្ទាត់១៤-២១] ទំព័រ៤២ [បន្ទាត់៣-១០]

ជម្រាបប្រសាសន៍លោកប្រធាន! ការទទួលខុសត្រូវខាងផ្លូវចិត្តដែលយើងខ្ញុំធ្វើទៅបានយ៉ាងម៉េចធ្វើទាំងអស់ ។

ទីមួយ គឺមិនក្បត់នឹងវិញ្ញាណក្ខន្ធអ្នកដែលស្លាប់ទេ។ អ្នកណាដែលស្លាប់ទៅនៅ ស-២១ ទទួលទាំងអស់ថា គេពិតជាស្លាប់នៅទីនោះមែន ។ គេស្លាប់ដោយទារុណកម្មមុននឹងទៅស្លាប់ ក៏

យើងខ្ញុំទទួល ហើយទទួលរាយការណ៍ជូន ជាតិ ប្រជាជនកម្ពុជាទាំងអស់ ថារឿងនេះវាសាហាវ គឺ ទទួលបែបនេះ ។ ហើយថ្មីៗនេះ អង្គសវនាការឃើញហើយ ដើមបណ្តឹងរដ្ឋប្បវេណីតាំងពីអ្នកស្រី ប៊ូ ថុន រហូតមកដល់ពេលនេះ ខ្ញុំទទួលឱ្យគេបន្ទោស ឱ្យគេថ្កោលទោស ហើយទទួលស្គាល់នូវទុក្ខវេទនារបស់គេទុកជាព្រឹត្តការណ៍ប្រវត្តិសាស្ត្រ ។ ទាំងអស់នេះហើយ ដែលយើងខ្ញុំយល់ថា ជាការទទួល ខុសត្រូវខាងផ្លូវចិត្តដែលត្រូវតែធ្វើជាដំបូង។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

សូមគោរពលោកប្រធាន! ជនរងគ្រោះឈ្មោះ ចិន សៀ អតីតកម្មាភិបាលមកពីហាណូយ ហើយជាអតីតកម្មាភិបាល ដែលជួយការងារនៅសាលាគ-៩២ ក្រោយមកមកជាប់នៅបឹងត្របែក ហើយត្រូវគេចាប់បញ្ជូនមកស-២១ យើងខ្ញុំ ទទួលស្គាល់ ។ ឯកសារ ស-២១ នៅទីនេះ ជាភស្តុតាងស្រាប់ យើងខ្ញុំអត់ប្រកែកទេ ។ គ្រាន់តែសូមបញ្ជាក់បន្តិចថា ប្រវត្តិសាលាគ-៩២ នេះ ខ្ញុំដឹងជាសាលាដែលលោកគ្រូ សុន សេន មេខ្ញុំគាត់ធ្វើ កាលគាត់នៅជាសហប្រធានភូមិភាគឧត្តរ។ដូច្នេះ ព្រឹត្តការណ៍ ប្រវត្តិសាស្ត្រ ដែលខ្ញុំសូមបញ្ជាក់បន្ថែមប៉ុណ្ណឹង ដើម្បីបញ្ជាក់ថា វិញ្ញាណក្ខន្ធលោក ចិន សៀ ហៅ ហាន ពិតជា ទៅស្លាប់នៅមន្ទីរស-២១ មែន។នេះគឺបញ្ជាក់ ហើយទទួលស្គាល់ និងទទួល ខុសត្រូវចំពោះមុខច្បាប់ និងខាងផ្លូវចិត្តក្នុងមរណភាពរបស់លោក ចិន សៀ។

## ប្រតិចារឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩

### ទំព័រ៨៥ [បន្ទាត់២-៩]

លោកប្រធានជាទីគោរព! ដំបូងខ្ញុំសូមបញ្ជាក់ម្តងទៀតថា ខ្ញុំសូមទទួលស្គាល់ថាមិត្ត នេត ប៊ុន ធី នេះមក រងគ្រោះស្លាប់នៅមន្ទីរស-២១ មែន ។ ចូលមកដល់មន្ទីរស-២១ នៅថ្ងៃ២៤ ខែធ្នូ ១៩៧៨ នេះពិត ។ ហើយ រឿងរ៉ាវជាប្រវត្តិសាស្ត្ររវាងបក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពបូព៌ា ខ្ញុំបានបញ្ជាក់ជូន អង្គសវនាការ អម្បាញ់មិញ ហើយ ខ្ញុំអត់និយាយតទៅទៀតទេ ។ ទុក្ខសោករបស់យុទ្ធជននិងកម្មាភិបាលដែលប្រតិបត្តិការនៅ ខាងភូមិ ភាគ បូព៌ាជំផេង។ ទុក្ខវេទនាដែលលោក នេត ផល្លី ហៅ ឆើត ផល្លី ធ្វើសក្ខីកម្មនៅមុខ អង្គជំនុំជម្រះ នេះជា ផ្នែកមួយ នៃទុក្ខសោករបស់យុទ្ធជន និងកម្មាភិបាលភូមិភាគបូព៌ា ពីថ្ងៃ ១៧ មេសា រហូតដល់ថ្ងៃ៧ មករា ១៩៧៩ ។ ខ្ញុំសង្កេត ឃើញសក្ខីកម្មក្នុងរយៈកាលនេះឈរនៅលើសេចក្តីពិតជាមូលដ្ឋាន ។

## ប្រតិចារឹកថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩

### ទំព័រ៣២ [បន្ទាត់១២-២៥] ដល់ទំព័រ ៣៣ [បន្ទាត់១-៥]

សូមគោរពលោកប្រធាន! ខ្ញុំសូមបញ្ជាក់សាជាថ្មីឡើងវិញថា ទីមួយមិត្តភក្តិ មិត្តភក្តិចាស់ដែលធ្លាក់ទៅស-២១ ច្រើន ណាស់។ម្នាក់នោះមិនមែនជាមិត្តភក្តិផង គាត់អាយុច្រើនជាងខ្ញុំប្រហែលជា លោក ជុំ ស៊ីរ៉ាត់ ស្គាល់ដែរ សាស្ត្រា ចារ្យប្រវត្តិវិទ្យានៅលីសេស្តន់ គិន អួន ធ្លាក់ទៅមុនគេហើយ ខ្ញុំអត់ដឹងទេ ទាល់តែឃើញសេចក្តីសារភាពមក បានខ្ញុំ ដឹងថា អ៊ំ! គិន អួន មកហើយ ។ ដូច្នេះ ចំពោះបញ្ហាមិត្តភក្តិដែលខ្ញុំធ្លាប់ស្គាល់ ធ្លាប់គោរព ធ្លាប់ស្រឡាញ់ ខ្ញុំគេចមុខ យកតែរួចខ្លួនទេ អត់បានទៅអើតទេ នេះជម្រាបដោយត្រង់ ។ នេះហើយដែលខ្ញុំហៅថា ក្បត់មិត្ត ក្បត់ភក្តិ ។ ដូច្នេះ ជុំ ណារិត ក៏ចូលក្នុងជំពូកហ្នឹងដែរ គឺអ្នកណាមកប៉ុន្មាននាក់ក៏ខ្ញុំខំបំភ្លេច ខំគេច ខំធ្វើមិនដឹងនេះចំពោះមិត្តភក្តិ ខ្ញុំអត់ មានលទ្ធភាពអីហ្នឹងជួយទេ ដូចលោកជម្រាបហើយគោលការណ៍ អ្នកណាដែលគេចាប់បញ្ជូនមកហើយ ចាត់ទុកជា ខ្មាំងនេះជាបញ្ហាមួយ ។ ឯចំណែកបញ្ហាមួយទៀត លោកមានបញ្ហាអំមិញអំពីភ្នែកបីម៉ឺនជាង ខ្ញុំទទួលស្គាល់បញ្ហា នេះដោយសារបញ្ហានេះបានប៉ុន្មានថ្ងៃនេះ ខ្ញុំនិយាយថាទទួលទាំងអស់សូមដើមបណ្តឹងរដ្ឋប្បវេណី លោកចង្អុល មុខខ្ញុំចុះ លោកថ្កោលទោសខ្ញុំចុះ លោកស្តីបន្ទោសយ៉ាងម៉េចក៏បានដែរ ខ្ញុំទទួល។ ផ្ទាល់ខ្លួនលោក លោកឃើញ ហើយអំមិញ លោកចង្អុលមុខខ្ញុំយ៉ាងម៉េច លោកថ្កោលទោសខ្ញុំយ៉ាងម៉េចខ្ញុំទទួលដោយញញឹម ខ្ញុំអត់ប្រកែក ហើយ អត់តថ្លៃអីនឹងលោកមួយម៉ាត់ទេ។ នេះជាសុទ្ធចិត្ត ដែលខ្ញុំបើកជូនបងប្អូនជនរងគ្រោះទាំងអស់ ដែលបាត់បង់ ឪពុក ម្តាយ ដែលបាត់បង់បងប្អូន ។ រួចខ្ញុំរហូតដល់និយាយប៉ុន្មានថ្ងៃនេះ វាជ្រុលថែមទៀត ខ្ញុំសូមមិនរំឭកបញ្ហានេះទេ ជាតិ ប្រជាជនកម្ពុជា លោកឮហើយ។ ដូច្នេះ សូមលោកបញ្ជាក់ ខ្ញុំសូមបញ្ជាក់ជូនលោកដោយស្មោះត្រង់ ខ្ញុំអត់មានទឹកចិត្តគំនុំសងសឹកនឹងលោក គ្មានចិត្តចង់តបតនឹងលោក គ្មានចិត្តប្រកែកអីនឹងលោកទេ លោកស្តីបន្ទោសខ្ញុំ អញ្ជើញ ខ្ញុំអត់ប្រកែកទេ ទទួលដោយស្មោះ អត់មានពន្យុះប្រសោក ទទួលហ្នឹងទទួលដោយស្មោះ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ដោយស្មោះ ។

## ប្រតិចារឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩

### ទំព័រ៣៧ [បន្ទាត់១៥-១៧]

សូមគោរពលោកប្រធាន! ខ្ញុំទទួលស្គាល់ទុក្ខវេទនាទាំងអស់របស់អ្នកស្រី ជុំ នៅ ដែលរាយការណ៍ក្នុងរយៈពីពេល ដែលអ្នកស្រី ជុំ នៅ ទៅរងទុក្ខវេទនានៅមន្ទីរព្រៃស ដែលហៅថា ស-២៤ រហូតដល់ថ្ងៃ០៧ មករា ១៩៧៧ ហើយក្រោយមកអ្នកស្រី ជុំ នៅ រត់ទៅជាមួយយើងខ្ញុំ ។

## ប្រតិចារឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩

### ទំព័រ៤៩ [បន្ទាត់៥-២៥] ដល់ទំព័រ ៥០ [បន្ទាត់១-៨]

ដោយឡែកខ្ញុំ ជាអ្នកទទួលខុសត្រូវនៅមន្ទីរ ស-២១ ក្នុងឋានៈជាប្រធាននៃយន្តការឧក្រិដ្ឋនេះ ខ្ញុំនៅតែតាំងចិត្តដាច់ខាត ថាទទួលខុសត្រូវគ្រប់ឧក្រិដ្ឋកម្មទាំងអស់ ដែលកើតមាននៅ ស-២១ ទាំងខាងផ្លូវច្បាប់ ទាំងខាងផ្លូវចិត្ត។ ទីពីរ ខ្ញុំបាទ កាំង ហ្កេកអ៊ាវ ហៅ ឌុច មិនមែនជាអ្នកទទួលខុសត្រូវលើមន្ទីរសន្តិបាលទូទាំងប្រទេសទេ ក៏ប៉ុន្តែខ្ញុំបាទ ជាបក្ខជនម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំនៅតែទទួលខុសត្រូវខាងផ្លូវចិត្តលើឧក្រិដ្ឋកម្មទាំងអស់ទៅជាតិ ប្រជាជនកម្ពុជាគ្រប់រូបក្នុងរបបនោះ ជាតិប្រជាជនកម្ពុជាធ្វើខ្ញុំយ៉ាងម៉េចធ្វើចុះ ។ តទៅទៀត ខ្ញុំសូមនិយាយអំពីបញ្ហាជាក់ស្តែងខ្លះ ផ្ទាល់ខ្លួនខ្ញុំ នៅពេលដែលប្រឈមមុខនឹងជនរងគ្រោះ ស្ត្រីមេម៉ាយ កុមារកំព្រា ស្ត្រីមេម៉ាយច្រើនណាស់ដែលអញ្ជើញ មកនៅទីនេះ ថ្កល់ទោសខ្ញុំ ចង្អុលខ្ញុំ ខ្ញុំបានធូរចិត្តហើយ ។ ខ្ញុំបានដាក់ខ្លួនឱ្យ អ្នកផងឃើញថា ខ្ញុំទទួលស្គាល់ទោសឧក្រិដ្ឋរបស់ខ្ញុំហើយ ។ តែសោកស្តាយដែរ ស្រីមេម៉ាយផ្សេង ទៀតអត់បានមក.....

ខ្ញុំសូមគោរព សុំទោសស្ត្រីមេម៉ាយទាំងអស់អំពីចម្ងាយ រួមទាំងម៉ាដាម ចៅ សេង រួមទាំងអ្នកប៉ាន់ ប៉ូលីន ផង ឯចំណែកប្រពន្ធ វត់ គត់ ប្រហែលជាដាច់ពូជហើយ ។ ដោយឡែកកុមារកំព្រាមក ដាក់ ពាក្យបណ្តឹងនៅទីនេះ ច្រើន គួរសម ប៉ុន្តែក៏នៅខ្លះទៀតមិនបានមកថ្លែងក្នុងសវនាការទេ ។ ក៏ប៉ុន្តែមានអ្នកមិនដាក់ពាក្យមក បើតាមខ្ញុំបូកសរុបដប់នាក់ហើយ ដប់នាក់ហើយ គេអត់ដាក់ពាក្យបណ្តឹងមកទេ ។ ដាក់ពាក្យបណ្តឹងឬមិនដាក់បណ្តឹង ខ្ញុំនៅតែទទួលខុសត្រូវ ឱនកាយទទួលស្តាប់ ហើយនៅតែជឿថា គេទទួលឥទ្ធិពលអាក្រក់ខាងផ្លូវចិត្ត ដូចលោកបណ្ឌិត ឈិម សុជារ៉ា លោកមាន ប្រសាសន៍អីចឹង ។ នេះជាឧក្រិដ្ឋកម្មមួយ ដែលទាមទារពេលវេលាយូរណាស់ ដើម្បីដោះស្រាយ ។ ដូច្នេះសរុបមកស្នាដៃជានិក្ខេបបទរបស់ដុកទ័រ ឈឹម សុជារ៉ា ខ្ញុំអត់អីប្រកែកប្រណាំងទេ ទទួលស្គាល់ថា ជាស្នាដៃវិទ្យាសាស្ត្រ ។ សូមគោរព ហើយសូមគោរពបងប្អូនទាំងអស់ ដែលនៅទីនេះ ។

## ប្រតិចារឹកថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩

### ទំព័រ៦៤ [បន្ទាត់៦-២៥] ដល់ទំព័រ ៦៥ [បន្ទាត់១-៥]

ជម្រាបប្រសាសន៍លោកជំទាវ ការទទួលស្គាល់ពិរុទ្ធភាពរបស់ខ្ញុំនៅក្នុងមន្ទីរស២១ ខ្ញុំសូមបញ្ជាក់ថាស-២១វាជាយន្តការមួយដែលមានមនុស្សច្រើនតាមតួលេខដែលយើងត្រូវស្គាល់ទាំងគ្នាជាង២០០០នាក់រួមចំណែកធ្វើ ក៏ប៉ុន្តែមនុស្សអស់នោះ ត្រូវតែគោរពខ្ញុំតែម្នាក់គត់ព្រោះនៅស-២១ខ្ញុំជាតំណាងបក្សកុម្មុយនីស្តកម្ពុជានៅក្នុងមន្ទីរនេះ។ វាគ្រាន់តែគោរពទៅតាមជាន់ថ្នាក់។

ដូច្នេះបុគ្គលិកពិត ប្រាកដទាំងឡាយណារបស់ស-២១ ខ្ញុំពិតជាមានអំណាចទៅលើគេឱ្យប្រព្រឹត្ត ឧក្រិដ្ឋកម្មដោយខានមិនបាន។ គេអត់ហ៊ានប្រកែកទេ ហើយបញ្ហាខ្ញុំកម្រិតណាគេត្រូវតែធ្វើកម្រិត នេះ នេះជាបញ្ហាមួយ។ ឯបញ្ហាទីពីរទៀតដែលខ្ញុំឃើញថាឧក្រិដ្ឋកម្មដែលខ្ញុំអនុវត្តដោយផ្ទាល់ដៃ គឺចារលើឯកសារនេះជាបញ្ហាមួយសំខាន់ណាស់។ ពីលើនោះទៅទៀត គឺខ្ញុំបង្រៀន ខ្ញុំកម្ចាត់ ទស្សនៈត្រឹមត្រូវ ខ្ញុំកសាងទស្សនៈឧក្រិដ្ឋទៅឱ្យគេ ដូចខ្ញុំបានជម្រាបលោកជំទាររួចហើយ។តាមខ្ញុំ ចាំការណែនាំរបស់ខ្ញុំ ពីថ្ងៃ១៨ កុម្ភៈ ១៩៧៦ ខ្ញុំណែនាំគេថា «មនុស្សដែលបក្សចាប់មកហើយត្រូវ កំណត់ថាជាខ្មាំង បើមិត្តមិនកំណត់ថាជាខ្មាំងទេ មិត្តសួរចម្លើយមិនចេញទេ» ។ គេជាបញ្ញាជន គេឃើញមនុស្ស គេគិតតើគ្នាខុសអីចឹងមែនឬមិនមែន?ៗៗ យើងបណ្តោយឱ្យបញ្ញាជន គិតបែប នេះ យូរៗបញ្ញា ជនអស់ហ្នឹង ទៅជាមានទស្សនៈមួយប្រឆាំងនឹងបក្សខ្លួនឯង។ បើបញ្ញាជន ទាំង អស់នោះ គេប្រឆាំងនឹងបក្សខ្លួនឯងហើយ ខ្ញុំដែលទទួលខុសត្រូវពីលើហ្នឹង ក៏ត្រូវទទួល ទារុណ កម្មដែរ ខានមិនបានទេ ខាងផ្លូវបក្ស គឺខ្ញុំត្រូវទទួលខុសត្រូវអីចឹង ។ ដូច្នេះការអប់រំនេះជាឧក្រិដ្ឋ កម្មទីពីរ ។ ឯចំណែក ឧក្រិដ្ឋកម្មដែលខ្ញុំមើលជារួម គឺខ្ញុំកសាងអ្នកបន្តដៃ ដូចខ្ញុំបានជម្រាប លោកជំទារអំមិញអីចឹង ។ ខ្ញុំតែម្នាក់ឯងស្មោះត្រង់ជាមួយនឹងបក្សបានតែមួយទេ បើខ្ញុំកសាង អ្នកផ្សេងទៀតបាន២០ គេអរ ឧក្រិដ្ឋកម្មវាកាន់តែទូលាយ និងជម្រៅឱ្យគេ ។ សរុបមកពាក្យ ដែល ខ្ញុំថាធ្វើការម៉ត់ចត់ ពាក្យ ដែលថាខ្ញុំឧស្សាហ៍ ពាក្យដែលខ្ញុំថាព្យាយាមខ្នះខ្នែងសព្វ បែបយ៉ាង ទាំងអស់នេះ។ បើនិយាយនៅក្នុងរដ្ឋាភិបាលមួយ ដែលស្នេហាជាតិពិតប្រាកដ វាជាគុណធម៌ របស់ខ្ញុំ ដែលខ្ញុំ ត្រូវតែទទួល ក៏ប៉ុន្តែដល់រដ្ឋាភិបាលនេះវាជាយន្តការឧក្រិដ្ឋ ដ៏សែនឃោរឃៅ សម្រាប់សតវត្សនេះ ការងារទាំងប៉ុន្មានដែលខ្ញុំធ្វើនេះ វាទៅជារឿងមួយរំលឹកឡើងពេលណាគួរ ឱ្យឈឺចាប់ ហើយនិងខ្មាស់ អៀន ពេលនោះ ។ នេះជម្រាបលោកជំទារយ៉ាងនេះ ។ ខ្ញុំសូម បញ្ចប់ ចម្លើយខ្ញុំត្រឹមប៉ុណ្ណេះ ។

## ប្រតិចារឹកថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩

### ទំព័រ៦៦ [បន្ទាត់៥-១១] ទំព័រ ៦៦ [បន្ទាត់២៣-២៥] ដល់ទំព័រ ៦៧ [បន្ទាត់១-៥]

ជម្រាបប្រសាសន៍លោកជំទារវិប្បដិសារីរបស់ខ្ញុំមាន ហើយវាមានការវិវឌ្ឍន៍ ត្រង់ដែលសាស្ត្រាចារ្យ ស៊ីរ៉ូនី មើលខ្ញុំ ទាន់ឬមិនទាន់ ខ្ញុំមិនបានជាពិនិត្យពិច័យការសិក្សាវិភាគរបស់គាត់ទេ ។ ចំណែកខ្ញុំ ខ្ញុំដឹងថាខ្ញុំមានការវិវឌ្ឍន៍ ទៅមុខ ខាងវិប្បដិសារីរបស់ខ្លួនដែលបានប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុង មន្ទីរស-២១។ លោកជំទារឃើញនឹងភ្នែកស្រាប់ហើយ ជនរងគ្រោះពិតប្រាកដចង្អុលមុខខ្ញុំចុះ! ថ្កោលទោសខ្ញុំចុះ! ខ្ញុំអត់ហ៊ានប្រកែកនឹងគេមួយមាត់ទេ ខ្ញុំឱនលំទោន ទទួលការស្តីបន្ទោស ដោយស្មោះ នេះវាវិវឌ្ឍន៍ទៅអីចឹង។ [....] ដូច្នេះវិប្បដិសារីវាមាននៅក្នុងអំពើប្រព្រឹត្តដូចដែល ខ្ញុំនិយាយហូរហែមក ទោះបីជាតិប្រជាជនកម្ពុជា លោកដាក់ទោសខ្ញុំយ៉ាងម៉េច ខ្ញុំអត់ប្រកែក ទេ ។ នេះវិប្បសារីវាស្តែងចេញមកពីអីចឹង ទាំងអស់ឱ្យសូមទោស សូមទោស បើកទ្វារឱ្យ សូមទោសម៉ោងណា ខ្ញុំសូមទោសម៉ោងហ្នឹង។ ចង្អុលមុខខ្ញុំនៅក្នុងអង្គសវនាការក្តី នៅឯណា

ក្តី ខ្ញុំអត់ប្រកែកទេ ។ នេះវិប្បដិសារី វាស្តែងចេញមកអំពីមកអំពើជាក់ស្តែងបែបនេះ។ ហើយចុងបញ្ចប់ខ្ញុំនិយាយ នៅពេលដែលអ្នកជំនាញខាងចិត្តសាស្ត្រទាំងពីរ លោកសាស្ត្រាចារ្យទាំងពីរលោកនេះ ខ្ញុំថាសូមមេត្តាជួយផ្តល់យោបល់យ៉ាងម៉េចដល់ខ្ញុំផងឱ្យមនុស្សជាតិទាំងមូល លោកទទួលស្គាល់ខ្ញុំជាមនុស្សម្នានឹងគេផង។ នេះក៏ជាសម្តែងចេញអំពី ការសោកស្តាយរបស់ខ្ញុំមកជាអំពើប្រព្រឹត្តជាក់ស្តែងរួចហើយ។ នេះសូមគោរពរាយការណ៍ជូនលោកជំទាវ ប៉ុណ្ណេះ។

## ប្រតិចារឹកថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩

### ទំព័រ៦៨ [បន្ទាត់៣-១២]

សរុបមក ទោះបីមានបាតុភាពយ៉ាងនេះក៏ដោយ ទោះបីមានចម្រៀង ដូចដែលខ្ញុំបានធ្លាប់រាយការណ៍ ជូនចៅក្រមស៊ើបអង្កេតក៏ដោយ អំពីរឿងអាគីងចង្រៃ ចម្រៀងឈ្មោះ អាគីងចង្រៃហ្នឹងក៏ដោយ ។ បើពាក្យស្លោករបស់បក្សកុម្មុយនីស្តកម្ពុជាថា «បំណុលឈាម ត្រូវតែសងដោយឈាមក៏ដោយ» ក៏ការទទួលភារកិច្ចជាប្រធានមន្ទីរនគរបាលតាំងពីម-១៣ រហូតមក វាស្ថិតនៅក្នុងក្របខណ្ឌមួយដែលជៀសមិនរួច ។ ហើយវាស្ថិតនៅក្នុងក្របខណ្ឌមួយ ដែលខ្ញុំអង្វរកគេ ដែលគេក៏សុខចិត្ត មិនបង្ខំឱ្យខ្ញុំសម្លាប់មនុស្សដោយដៃឯង ។ មិនទាមទារចាប់អ្នកនេះឬចាប់អ្នកនោះទាល់តែសោះ ទោះបីមានហេតុផលបែបនេះក៏ដោយ ក៏ឧក្រិដ្ឋកម្មដែលឯងឹតឯងល់បំផុត ខ្ញុំពិតជាទទួលថា វាពិតជាឯងឹតឯងល់មែន សកម្មភាពដែលខ្ញុំធ្វើចន្លោះពី ១៧ មេសា រហូតដល់ ៦ មករា ដោយចាប់ផ្តើមពី ១៨ សីហា ខ្ញុំ ៧៥ ខ្ញុំជាអនុប្រធាន ហើយពីខែមីនា ១៩៧៦ ខ្ញុំជាប្រធាន ។ ដូច្នេះឧក្រិដ្ឋកម្មទាំងនេះ វាពិតជាឯងឹតឯងុល ខ្ញុំទទួលស្គាល់ពេញទី ។ ខ្ញុំសូមបញ្ចប់សេចក្តីរាយការណ៍របស់ខ្ញុំប៉ុណ្ណេះ សូមគោរព ។

## ប្រតិចារិកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩

### ទំព័រ២៧ [បន្ទាត់១៩-២៥] ដល់ទំព័រ ២៨ [បន្ទាត់ ១-៥]

ការអប់រំរបស់បក្សកុម្មុយនីស្តកម្ពុជា ជនទាំងឡាយណាដែលគេចាប់បញ្ជូនទៅ ស២១ ជាខ្មាំង ។ ត្រូវតែកម្ទេច ព្រោះជាមនុស្សមានទោស ព្រោះជាមនុស្សប្រឆាំងនឹងគេ ។ នៅពេលដែលខ្ញុំនិយាយថា ខ្ញុំសូមទោសជនរងគ្រោះ សូមទោសគ្រួសារជនរងគ្រោះរហូតដល់សូមទោសបុគ្គលិករបស់ខ្ញុំ។ ពេលនុ៎ងខ្ញុំអត់មានចាត់ទុកអ្នក ដែលស្លាប់ទៅទាំងអស់នុ៎ងថាជា ឧក្រិដ្ឋជនជាជនមានកំហុសត្រូវតែស្លាប់នោះទេ គឺបក្សកុម្មុយនីស្តកម្ពុជារបស់ខ្ញុំនេះវិញទេ ដែលជាជនឧក្រិដ្ឋ។ ដូច្នេះកំហុសដែលខ្ញុំធ្វើទៅលើជាតិ ប្រជាជនខ្ញុំ ខ្ញុំត្រូវតែសូមទោស ដោយខានមិនបាន ព្រោះខ្ញុំដឹងខ្លួនថា ខ្ញុំខុស ពិតជាខុស ។ អត់យកអ្វីមកកែប្រែបានទេ គឺខ្ញុំសូមទោសដោយសុទ្ធចិត្ត ។

អ្នកដែលគេមិនព្រមសូមទោសប្រជាជនកម្ពុជា គេនៅតែតាំងខ្លួនថា ឧក្រិដ្ឋកម្មរបស់គេជាការត្រឹមត្រូវ ស្នេហាជាតិ អាហ្នឹងវាជារឿងមួយដោយឡែក។ ដូច្នេះសូមជាតិ ប្រជាជនលោកថ្លឹងមើលចុះ តើខ្ញុំសូមទោសដោយសុទ្ធចិត្ត ឬក៏ជាការក្លែងបន្លំ សារជាតិវានៅត្រង់ហ្នឹង ។ សារជាតិនៅហ្នឹង ដែលខ្ញុំទទួលថា ជនដែលស្លាប់ទៅហ្នឹងគ្មានកំហុស គ្មានទោសពៃរ៍។ នេះខ្ញុំសូមទោស។

## ប្រតិចារិកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩

### ទំព័រ២៩ [បន្ទាត់១៨-២៤] ដល់ទំព័រ៣០ [បន្ទាត់១-១០]

ខ្ញុំបាននិយាយហើយថា ខ្ញុំធ្វើបដិវត្តន៍ ដើម្បីរំដោះជាតិ ប្រជាជនខ្ញុំ សងគុណជាតិ ប្រជាជនខ្ញុំ សងគុណមាតាបិតាខ្ញុំ ដែលខំបង្កើតខ្ញុំ ហើយនិងចិញ្ចឹមបីបាច់ថែរក្សាខ្ញុំ ។ តែបែរជាមកធ្លាក់ឱ្យជាតិ ប្រជាជន អន្តរាយរកទីបំផុតគ្មាន ។ គ្រាន់តែអាយុជីវិតមនុស្សបាត់បង់រហូតទៅជាងមួយលាននាក់ ។ សេដ្ឋកិច្ចរលំរលាយ វប្បធម៌ខ្ទេចខ្ទី សព្វបែបយ៉ាង ខ្ទេចទាំងអស់ ។ តើឱ្យខ្ញុំឆ្លើយ ទម្លាក់ កំហុស ទៅលើអ្នកណា ខ្ញុំកើតមកជាកូនប្រុស កើតមកជាអ្នកស្រលាញ់យុត្តិធម៌ ខ្ញុំឆ្លើយដាក់ទៅលើអ្នកណា មិនកើតទេ ទទួលស្គាល់ហើយថានេះ គឺជាស្នាដៃរបស់បក្សកុម្មុយនីស្តកម្ពុជាដែលក្នុងនោះមាន ខ្ញុំជាសមាជិកមួយរូប ។ ដូច្នេះហើយបានជាខ្ញុំនិយាយថា ឧក្រិដ្ឋកម្មទាំងអស់នៅកម្ពុជា ខ្ញុំសូមទទួលខុសត្រូវខាងផ្លូវចិត្តជាតិ ប្រជាជនខ្ញុំ លោកថ្កោលទោសយ៉ាងម៉េច? លោកចង្អុលទោស មុខខ្ញុំយ៉ាងម៉េច? លោកថាយ៉ាងម៉េច ថាចុះ ។ ខ្ញុំទទួលដោយឱនលំទោន ហើយដោយស្មោះ ។

ដោយឡែក ឧក្រិដ្ឋកម្មនៅ ស-២១ ដែលខ្ញុំជាប្រធាន ខ្ញុំទទួលតែម្នាក់ឯង អត់មានទាក់ទងនឹងកូនចៅណាម្នាក់ទេ ទាំងខាងផ្លូវច្បាប់ ទាំងខាងផ្លូវចិត្ត សូមទោសជនរងគ្រោះ សូមទោសក្រុមគ្រួសារជនរងគ្រោះ ទទួលសេចក្តីវិនិច្ឆ័យរបស់អង្គជំនុំជម្រះដោយស្មោះ។ នេះជាការប្តេជ្ញាចិត្តរបស់ខ្ញុំ ចំពោះមុខប្រវត្តិសាស្ត្រជាតិ ដែលខ្ញុំបានចូលរួមទៅក្នុងអំពើខុសឆ្គងរួមមកហើយនោះ ។ នេះជាបញ្ហាធំ ហើយនៅចុងបញ្ចប់ខ្ញុំបានសួរដែរ អ្នកជំនាញខាងចិត្តសាស្ត្រ ខ្ញុំសួរថា តើៗត្រូវឱ្យខ្ញុំធ្វើដូចម្តេច ដើម្បីឱ្យមនុស្សជាតិ លោកទទួលខ្ញុំ ស្គាល់ខ្ញុំជាមនុស្សម្នាឡើងវិញ ។ ខ្ញុំចោទបញ្ហានេះ ។ ខ្ញុំចោទបញ្ហានេះជាប់ជានិច្ច ។ នេះសូមជម្រាបបញ្ជាក់ជូនប៉ុណ្ណោះ ។

## ប្រតិចារិកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩

### ទំព័រ៣៤ [បន្ទាត់២-៧]

នៅពេលដែលខ្ញុំសម្រេចចិត្តនេះ ខ្ញុំនឹកឃើញដល់វិញ្ញាណក្ខន្ធមួយម៉ឺននាក់ជាង ។ ខ្ញុំនឹងឃើញដល់ជីវិតកុមារ ដែលគេសម្លាប់ ហើយអាចសម្លាប់ដោយវិធីមួយ គួរឱ្យខ្លើមរអើមបំផុត គឺចាប់ជើងគ្នាបោកនឹងក្បាលទៅនឹងគល់ឈើ ។

ខ្ញុំតាំងចិត្តថា ត្រូវតែទៅ ។ ទៅដើម្បីលុតជង្គង់ ថ្វាយបង្គំ សូមទោសវិញ្ញាណក្ខន្ធទាំងអស់នោះ ។ ហើយក៏ទៅដើម្បីអធិដ្ឋានចំពោះវិញ្ញាណក្ខន្ធអ្នកទាំងអស់នោះ ក្នុងឋានៈខ្ញុំជាគ្រិស្តស្ទៀនមួយរូប ។ ដូច្នេះខ្ញុំទៅនេះក្នុងអារម្មណ៍បែបនេះ សកម្មភាពខ្ញុំ ដែលធ្វើនៅទីនេះក៏នៅក្នុងអារម្មណ៍បែបនេះ។

## ប្រតិចារិកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩

### ទំព័រ៣៦ [បន្ទាត់២-២៥] ដល់ទំព័រ ៣៧ [បន្ទាត់១-២៤]

[បញ្ចាំងខ្សែវីដេអូ D48/2 ដែលបានថតក្នុងអំឡុងពេលស៊ើបអង្កេតដល់កន្លែងកើតហេតុនៅមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨]

លោក កាំង ហ្កេកអ៊ាវ៖ លោកចៅក្រមទាំងពីរជាទីគោរព! លោកនិងលោកស្រីសហព្រះរាជអាជ្ញាជាទីគោរព! ខ្ញុំរន្ធត់ក្នុងចិត្តឥតឧបមា នៅពេលដែលបានឈានជើងចូលមកដល់ទីនេះ ហើយបានឃើញសភាពការណ៍ចាស់ដែលជាសភាពការណ៍គួរឱ្យខ្លោចផ្សាបំផុត សម្រាប់ជាតិប្រជាជនខ្ញុំ ក៏ដូចជាសម្រាប់រូបខ្ញុំដែរ ។ ទីមួយ ខ្ញុំនឹកទៅដល់ជនរងគ្រោះដ៏អភ័ព្វ និងក្រុមគ្រួសាររបស់គេ ។ គេទាំងឡាយបានរងទុក្ខវេទនា រងទារុណកម្ម រងការប្រមាថមើលងាយដ៏សែនមហាអមនុស្សធម៌រាប់មិនអស់ មុននឹងបាត់បង់ជីវិតរលត់សង្ខារទៅ ។ ខ្ញុំមានវិប្បដិសារីជ្រាលជ្រៅដែលមិនអាចថ្លាថ្លែងបាន គឺវិប្បដិសារី ដែលសុខចិត្តឱនក្បាលទទួលការជំនុំជម្រះតែម្នាក់ឯងក្នុងក្របខ័ណ្ឌស-២១ ហើយប្ដេជ្ញាចិត្តយ៉ាងមុតមាំថានឹងធ្វើអ្វីៗទាំងអស់ ដើម្បីឱ្យជាតិប្រជាជនខ្ញុំ និងជនរងគ្រោះ និងក្រុមគ្រួសាររបស់គេបានស្គាល់នូវពន្លឺយុត្តិធម៌។ ព្រមជាមួយនេះ ខ្ញុំក៏មានការសោកស្ដាយបំផុតចំពោះបុគ្គលិកទាំងអស់របស់ស-២១ ដែលត្រូវបានគេចាប់បង្ខំឱ្យបំពេញភារកិច្ចជាមួយខ្ញុំ គឺភារកិច្ចដែលសាមីខ្លួនរបស់គេស្អប់ខ្ពើម ដែលមាតាបិតារបស់គេស្អប់ខ្ពើម ហើយក្នុងនោះក៏មានបុគ្គលិកមួយចំនួនបានធ្លាក់ខ្លួនរងគ្រោះថ្នាក់នៅទីនេះឯងតែម្ដង ។រឿងអស់នេះ ខ្ញុំនឹកឃើញពេលណា ខ្ញុំខ្លោចផ្សាពេលនោះ ។ ខ្ញុំមានការសោកស្ដាយដោយស្មោះដោយបានសុខចិត្តចុះចាញ់ទស្សនៈរបស់គេ និងដោយបានទទួលយកភារកិច្ចឧក្រិដ្ឋ ដែលគេប្រគល់ឱ្យខ្ញុំ ។

សកម្មភាពរបស់ខ្ញុំ ពិតជាគួចចូលទៅក្នុងចរន្តមួយ ដែលបាននាំមកនូវគ្រោះមហន្តរាយធ្ងន់ធ្ងរ រ៉ាំរ៉ៃដល់ជាតិប្រជាជនខ្ញុំ ។ នេះហើយជាបញ្ហាដែលខ្ញុំនៅតែនឹកឃើញជានិច្ច នឹកមិនភ្លេចសោះ នឹកឡើងណា ដំបូងខ្ញុំខឹងនឹងក្បាលម៉ាស៊ីនដឹកនាំបក្ស ដែលបានប្រើគ្រប់មធ្យោបាយអូសទាញ ចលនានេះ ដែលទៅតាមផ្លូវសោកនាដកម្មទាំងស្រុង និងដាច់ខាត ។ បន្ទាប់មកខ្ញុំខឹងនឹងរូបខ្ញុំ ខ្លួនឯង ដែលសុខចិត្តចុះចាញ់ទស្សនៈរបស់គេ ម្ល៉ោះហើយគោរពបទបញ្ជាឧក្រិដ្ឋរបស់គេទាំង ងងឹតងងល់ ។ នេះហើយជាគន្លឹះដែលនាំឱ្យខ្ញុំទទួលស្គាល់ ដោយខានមិនបានថា ក្នុងឋានៈខ្ញុំ ជាប្រធានស-២១ បានរួមចំណែកក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងក្របខ័ណ្ឌនៃស-២១ ទាំងមូល ។

លោកចៅក្រមទាំងពីរជាទីគោរព! លោក និងលោកស្រីសហព្រះរាជអាជ្ញាជាទីគោរព! ខ្ញុំសូម គោរពអរគុណលោក ដែលបាននាំខ្ញុំមកដល់ទីនេះ ។ សូមលោកទាំងបួនអនុញ្ញាត ឱ្យខ្ញុំសុំទោស ជនរងគ្រោះចំពោះទុក្ខវេទនាលោក ការ សារុត្ថ៖ គាត់អានលែងកើត ។

**លោក ម៉ាសែល ឡឺម៉ុងដ៍៖** បើអ៊ីចឹងបញ្ចប់ប៉ុណ្ណឹងហើយបើសិនជា-- អានេះគឺឯកសារហ្នឹងអាច បញ្ចូលនៅក្នុងសំណុំរឿង ហើយភាគីទាំងអស់អាចមើលបាន ។

**លោក កាំង ហ្គេកអ៊ាវ៖** ឱ្យខ្ញុំសូមទោសជនរងគ្រោះ ចំពោះទុក្ខវេទនាដ៏មហាខ្លោចផ្សាទាំងប៉ុន្មាន ដែលគេបានទទួលរងនៅទីនេះ រហូតដល់ថ្ងៃបាត់បង់ជីវិត ឬរហូតដល់ថ្ងៃ៧ មករា ១៩៧៩ ។ ឱ្យខ្ញុំសុំទោសក្រុមគ្រួសារជនរងគ្រោះ ដែលបានរស់នៅក្នុងទុក្ខសោកយ៉ាងក្រំក្រា ដោយបាត់បង់ បុគ្គលជាទីស្រឡាញ់របស់ខ្លួនចំនួន៣៣ឆ្នាំហើយ ហើយមិនទាន់បានទទួលពន្លឺយុត្តិធម៌នៅ ឡើយ ។ ខ្ញុំដឹងហើយថា វិប្បដិសារីរបស់ខ្ញុំ ទោះបីចុកចាប់យ៉ាងណាក៏ដោយ ក៏នៅតែជាទឹក មួយដំណក់ក្នុងមហាសាគរជំធេង និងជ្រាលជ្រៅនៃទុក្ខវេទនាដ៏សែនខ្លោចផ្សារបស់ជនរងគ្រោះ និងក្រុមគ្រួសារ ។ ខ្ញុំសូមលោកចៅក្រម លោក និងលោកស្រីព្រះរាជអាជ្ញាដែលជាអ្នកស្វែងរក យុត្តិធម៌ជូនជនទាំងអស់ខាងលើនេះ អនុញ្ញាតឱ្យខ្ញុំចូលសុំទោសគេទាំងឡាយនោះ ដោយ ស្មារតីលំឱនបំផុត និងដោយវិប្បដិសារីចុកចាប់យ៉ាងគ្រាំគ្រា ។ សូមលោកមេត្តាទុកទ្វារនេះឱ្យ នៅចំហជានិច្ច។ ពេញមួយថ្ងៃហើយដែលខ្ញុំបានទៅមើលស្ថានទីនោះ ដូច្នេះខ្ញុំសូមអរគុណ លោកទាំងបួនដែលបាននាំខ្ញុំមកដល់ទីនេះ ហើយបានឃើញមុខជនរងគ្រោះជាដំបូង ហើយខ្ញុំ សូមទោស ។

**លោក ជុំ មុី៖** ខ្ញុំសុំមានមតិបន្តិចបានទេ?

**ឆ្លើយ៖** ខ្លីៗបំផុត ។

**លោក ជុំ មុី៖** ខ្ញុំសូមគោរពលោកចៅក្រម សូមគោរពលោកព្រះរាជអាជ្ញា សូមគោរពលោក

លោកស្រី អានេះហើយដែលការខ្ញុំចង់បាន។ ដែលខ្ញុំចង់បានៗរកអារឿងសិទ្ធិសេរីភាព ពេលនេះសិទ្ធិសេរីភាពខ្ញុំមានមកដល់ហើយ ។ ពីមុនឡើយខ្ញុំអត់មានសិទ្ធិសេរីភាពនឹងតវ៉ារបៀបនេះទេ បើហ៊ានអ្នកណាមួយហ៊ានតវ៉ា គឺថាក្បាលត្បូងចប ក្បាលគល់ឫស្សី ក្បាលផ្លូវរទេះ ។ អ៊ីចឹងខ្ញុំអរគុណលោក ឌុច ណាស់ដែលគាត់មកឆ្លើយចំពោះមុខតុលាការទាំងអស់ គាត់ទទួលកំហុសគាត់ ហើយខ្ញុំក៏មិនបានទៅចងគំនុំគុំកួនអីនឹងគាត់ដែរ ខ្ញុំគ្រាន់តែស្វែងរកដើម្បីយុត្តិភាព សន្តិភាពសម្រាប់ប្រជាជនខ្ញុំជាងមួយលាននាក់ដែលស្លាប់ទៅ។ ខ្ញុំអរគុណណាស់ ខ្លាចតែគាត់មិនឆ្លើយស្មោះត្រង់ចំពោះមុខតុលាការ ខ្ញុំអរគុណណាស់ ។

## ប្រតិចារិកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩

### ទំព័រ៤៦ [បន្ទាត់១០-២៥] ដល់ទំព័រ ៤៨ [បន្ទាត់១] សេចក្តីថ្លែងចុងក្រោយរបស់ ឌុច អំពីគោលជំហរ និងអាកប្បកិរិយារបស់ខ្ញុំ

I) ចំពោះប្រជាជនកម្ពុជាទូទាំងប្រទេស

មុនថ្ងៃជម្នះរបស់ខ្លួន បក្សកុម្មុយនីស្តកម្ពុជាបានប្រកាសជាឱឡារិកថាត្រូវនឹងកាត់ទោសតែជនមហាក្បត់តែប្រាំពីរនាក់ទេ។ ជាក់ស្តែង បក្សបានជម្លៀសប្រជាជនទាំងបង្ខំ ព្រមទាំងបានសម្លាប់មនុស្សរាប់សែននាក់។ គឺមនុស្សដែលមិនបានប្រព្រឹត្តបទល្មើសអ្វីក្រោយ ១៧ មេសា សោះ។ ការកាប់សម្លាប់បានបន្តម្តងហើយម្តងទៀត ឥតស្រាកស្រាន្តរហូតអស់ជាងមួយលាននាក់។ ក្នុងចំណោមប្រជាជនក្រៅជួរ គេកាប់សម្លាប់អ្នកណាដែលពុំព្រមដាក់ខ្លួនឱ្យទៅជាកសិករ កម្មករ ឬក៏ធ្វើទៅពុំរួច។ រីឯអ្នកនៅក្នុងជួរវិញ គេចាប់ចងកាប់សម្លាប់បក្ខជនខ្មែរផ្សេង ដែលមិនមែនជាខ្មែររបស់គេ ដើម្បីដាក់កម្លាំងគេជំនួសវិញ។ មហាវិនាសកម្ម ទាំងក្នុងជួរនិងក្រៅជួរ ពិតជាឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាតែម្នាក់ឯងគត់។

ខ្ញុំនៅតែស្មោះត្រង់ និងសេចក្តីប្រកាសរបស់ខ្ញុំ ក្នុងអង្គសវនការនេះ ដែលខ្ញុំបានអះអាងថា ប៉ុល ពត ហ៊ានភ្លើតភ្លើនលើកមាគ៌ាមហាឧក្រិដ្ឋយ៉ាងនេះ គឺមកពីគាត់អាងលើកម្លាំង ជាពិសេស គឺកម្លាំងបក្ស ដែលមានកម្លាំងបក្ខជនរាប់ម៉ឺននាក់ស្តាប់បញ្ជាគាត់។ ខ្ញុំនៅតែទទួលស្គាល់ថា ក្នុងចំណោមកម្លាំងទាំងអស់នេះរបស់ ប៉ុល ពត មានខ្ញុំម្នាក់។ ក្នុងស្មារតីនេះហើយ ដែលខ្ញុំសូមទទួលខុសត្រូវខាងផ្លូវចិត្តចំពោះប្រជាជនកម្ពុជាទូទាំងប្រទេសដែលបានស្លាប់បាត់បង់ជីវិតពី ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩ ខ្ញុំពិតជាមានវិប្បដិសារីយ៉ាងធ្ងន់ធ្ងរ និងតក់ស្លុតឥតឧបមាចំពោះមហាវិនាសកម្មនេះ។

ខ្ញុំយល់ថា ខ្ញុំយល់ច្បាស់ថា ទ្រឹស្តីមនោគមវិជ្ជាណាក៏ដោយ ដែលនិយាយអំពីស្នេហាប្រជាជនទៅតាមទស្សនៈវណ្ណៈនិងតស៊ូវណ្ណៈ ពិតជានាំឱ្យហិនហោចខ្លោចផ្សាកទីបំផុតគ្មាន។ ខ្ញុំនៅតែ

ប្រកាន់ថា ការសម្រេចជ្រើសរើសផ្លូវដើរ គឺសម្រេចតែមួយដង្ហើមទេ បើខុស គឺឈឺចាប់ខ្លោចផ្សាពោរពេញទៅដោយវិប្បដិសារីអស់មួយជីវិត ជំនឿដែលជឿថា បានរួមចំណែករំដោះជាតិ ប្រជាជន បម្រើប្រជាជន ម្ល៉ោះហើយ បានឧទ្ទិស កម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញា ព្រមទាំងបានលះបង់អ្វីៗទាំងអស់ រហូតដល់ត្រៀមលះបង់អាយុជីវិត ដើម្បីជាតិប្រជាជន តែបែរជាធ្លាក់ខ្លួនក្នុងអង្គការឧក្រិដ្ឋមួយ ដែលកម្ទេចប្រជាជនខ្លួនឯងយ៉ាងរង្គោះរង្គាល និងដកខ្លួនថយក៏ថយមិនរួច ដូចស្ពឺមួយគ្រាប់ក្នុងតួម៉ាស៊ីនដែលកំពុងដើរ។

## II) ចំពោះជនរងគ្រោះនៅស-២១ និងក្រុមគ្រួសារ

ខ្ញុំនៅតែប្រកាសទទួលខុសត្រូវតែម្នាក់ឯងគត់ លើការបាត់បង់អាយុជីវិតយ៉ាងតិច ១២.៣៨០ នាក់ អស់លោកទាំងអស់នេះមុននឹងស្លាប់ទៅពិតជាបានរងទុក្ខវេទនាដ៏រ៉ាំរ៉ៃ និងអមនុស្សធម៌រាប់មិនអស់។ ខ្ញុំនៅតែសុំខមាទោសចំពោះវិញ្ញាណក្ខន្ធនៃអ្នកដែលស្លាប់បាត់បង់ទៅ ដោយសេចក្តីគោរពលំអុតលំឱនបំផុត។ ខ្ញុំបានអធិដ្ឋានចំពោះព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់វិញ្ញាណក្ខន្ធទាំងអស់នោះ ដោយព្រះទ័យអនុគ្រោះ។ ចំពោះអ្នកដែលរួចជីវិតផុតពីសេចក្តីស្លាប់ ខ្ញុំនៅតែទទួលស្គាល់ថា ឧក្រិដ្ឋកម្មទាំងអស់របស់ស-២១ ទៅលើអស់លោក ទទួលស្គាល់ទាំងខាងផ្លូវច្បាប់ ទាំងខាងផ្លូវចិត្ត ចំពោះក្រុមគ្រួសារជនរងគ្រោះ ខ្ញុំនៅតែប្រកាន់អាកប្បកិរិយាឱនលំទោន សូមអនុញ្ញាតទុកទ្វារសូមទោសឱ្យនៅចំហ ហើយនិងសូមរំលែកទុក្ខសោកដ៏សែនខ្លោចផ្សារ៉ាំរ៉ៃរបស់អស់លោកគ្រប់ពេលវេលា។

## III) ដើម្បីសម្តែងវិប្បដិសារីដ៏សែនចុកចាប់ទាំងអស់នេះ

ខ្ញុំបានសហការពេញទំហឹង ជាមួយតុលាការដោយស្មោះត្រង់ និងគ្រប់ពេលវេលាអស់ចំនួន ១០ឆ្នាំ ៦ខែ ១៧ខែ រួចមកហើយ ទាំងក្នុងរយៈកាលស៊ើបសួរ រួមទាំងការស៊ើបសួរនៅតុលាការយោធាផង ទាំងក្នុងរយៈកាលសវនាការនេះផង។ ចុងបំផុត ខ្ញុំបានលើកសំណូមពរដោយសុទ្ធចិត្តចំពោះអ្នកជំនាញខាងចិត្តសាស្ត្រ ដើម្បីយល់ថា ខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីឱ្យមនុស្សជាតិទាំងមូល លោកទទួលស្គាល់ខ្ញុំជាមនុស្សម្នាឡើងវិញ? ដើម្បីរួមចំណែករំលែកទុក្ខសោករបស់ប្រជាជនកម្ពុជា ខ្ញុំសូមសន្យាថា ទៅថ្ងៃមុខទោះជាក្នុងករណីណាក៏ដោយ ខ្ញុំនឹងធ្វើអ្វីៗទាំងអស់ដែលប្រជាជនខ្ញុំត្រូវការ ដើម្បីប្រជាជនខ្ញុំ សូមតុលាការមេត្តាពិចារណា និងសម្រេចសេចក្តីលើបញ្ហាបន្ថែមនេះ ដោយយោបល់អនុគ្រោះ។

## ប្រតិចារិកថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១១

### ទំព័រ ១១៣ [បន្ទាត់ ២៣-២៥] ដល់ទំព័រ ១១៤ [បន្ទាត់១-២]
### សេចក្តីថ្លែងចុងក្រោយរបស់ ឌុច

បន្តទៅនេះ ខ្ញុំសូមបញ្ជាក់អំពីគោលជំហររបស់ខ្ញុំចំពោះប្រជាជនកម្ពុជាទូទាំងប្រទេស។

បញ្ជាក់ទីមួយ គឺខ្ញុំនៅរក្សាគោលជំហរខាងផ្លូវច្បាប់ចំពោះជនរងគ្រោះនៅមន្ទីរស ២១ និង ទទួលខុសត្រូវខាងផ្លូវចិត្ត ចំពោះជនរងគ្រោះទូទាំងប្រទេស។ ខ្ញុំនៅតែរក្សាគោលជំហរសុំខមាលទោស ចំពោះវិញ្ញាណក្ខន្ធជនរងគ្រោះទាំង ១២.២៧៣ នាក់ ដែលបានស្លាប់បាត់បង់ជីវិត នៅស ២១ ព្រមទាំងសុំគ្រួសារអស់លោកទាំងនោះអនុញ្ញាតឱ្យខ្ញុំសុំចូលសុំទោសនៅថ្ងៃណាមួយសមរម្យ។




# ៨. ការបញ្ជូន ឌុច ទៅ អនុវត្តទោសនៅពន្ធនាគារ ខេត្តកណ្ដាល

00787428

F29

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អយ្យការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Office of the Co-Prosecutors of the Extraordinary Chambers in the Courts of Cambodia
Parquet auprès des Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Mar-2012, 15:48
CMS/CFO: Uch Arun

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក

Case File/Dossier N°. 001/18-07-2007-ECCC-TC/SC

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧- អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក |
| ដាក់ទៅ | : | ក្រសួងមហាផ្ទៃ |
| ថ្ងៃដាក់ | : | ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ:

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើសុំការអនុវត្តទោស

---

**អ្នកដាក់ឯកសារ:**
ការិយាល័យសហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ
ក្រសួងមហាផ្ទៃ

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥) -២៣-២១៩-៨១៤ ទូរសារ: (៨៥៥) -២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, Phnom Penh, P.O. Box 71, Phnom Penh Tel:+855(0)23 219814 Fax:023 219841 Web: www.eccc.gov.kh

00787429 F29

*សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក-អ.ជ.ស.ផ/អ.ជ.ត.ក*

**ចម្លងជូន:**

**អង្គជំនុំជម្រះតុលាការកំពូល**

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុម១**

លោកស្រី ទី ស្រ៊ីនណា

លោក Karim KHAN

លោក Alain WERNER

លោក Brianne McGONIGLE

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុម២**

លោក គង់ ពិសី

លោក ហុង គីមសួន

លោក យ៉ុង ផានិត

កញ្ញា Silke STUDZINSKY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុម៣**

លោក គីម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោកស្រី Annie DELAHAIE

លោក Philippe CANNONE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Fabienne TRUSSES-NAPROUS

លោកស្រី Christine MARTINEAU

**ទណ្ឌិត:**

កាំង ហ្គេកអ៊ាវ *ហៅ* “ឌុច”

**មេធាវីការពារក្តីទណ្ឌិត:**

លោក ការ សាវុត្ថ

លោក កង ឫទ្ធារី

**ប្រធានការិយាល័យរដ្ឋបាលស្តីទី**

ឯកឧត្តម ក្រាញ់ តូនី

**អនុប្រធានការិយាល័យរដ្ឋបាល**

Knut ROSANDHAUG

**ប្រធានមន្ទីរឃុំឃាំង អ.វ.ត.ក**

ម៉ៅ សុភារម្យ

**មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការពារក្តី**

Nisha VALABHJI

# យើង សហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អវតក")

**កត់សំគាល់ឃើញថា** ការចេញសាលដីកាសង្ខេបលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿងលេខ: ០០១/១៨-០៧-២០០៧/អវតក/អជតក (ករណី កាំង ហ្គេកអ៊ាវ)[1] (ដែលហៅកាត់ថា "សេចក្តីសង្ខេប") ដែលបានប្រគល់នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ដែលនៅក្នុងនោះ អង្គជំនុំជម្រះបានដាក់បញ្ចូលនូវឃ្លាមួយដែលផ្តន្ទាទោសអស់មួយជីវិត[2] ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច។

**កត់សំគាល់ឃើញថា** ច្បាប់ចម្លងដែលមានការចុះហត្ថលេខាជាផ្លូវការបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម នៃសេចក្តីសង្ខេបដែលចែងថា សាលដីកាលើបណ្តឹងសាទុក្ខនេះបានចូលជាស្ថាពរនៅថ្ងៃទី៣ខែកុម្ភៈ ឆ្នាំ២០១២[3]។

**កត់សំគាល់ឃើញថា** វិធាន១១៣(១) នៃវិធានផ្ទៃក្នុង ("វិធាន") ដែលបានចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "[]ការអនុវត្តទោសត្រូវធ្វើតាមការផ្តួចផ្តើមគំនិតរបស់សហព្រះរាជអាជ្ញា" និងវិធាន១១៣(២) នៃវិធានផ្ទៃក្នុងដែលចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "សហព្រះរាជអាជ្ញាត្រូវធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសំរេចរបស់អង្គជំនុំជម្រះបានចូលជាស្ថាពរ"។

**ដោយមានសេចក្តីព្រួយបារម្ភថា** ការផ្ទេរបញ្ជូនទណ្ឌិតឈ្មោះ កាំង ហ្គេកអ៊ាវ ពីមន្ទីរឃុំឃាំងនៅ អវតក ទៅកាន់ពន្ធនាគារអាចនឹងធ្វើឱ្យមានភាពស្មុគ្រស្មាញដល់ការចូលរួមរបស់គាត់ ក្នុងនាមជាសាក្សីនៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អវតក។

**សូមស្នើ** អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ សុំឱ្យទណ្ឌិតឈ្មោះ កាំង ហ្គេកអ៊ាវ ចាប់ផ្តើមអនុវត្តទោសរបស់គាត់ដែលនៅសល់ពីទោសដែលបានកំណត់។

**សូមស្នើបន្ថែមទៀតថា** សុំឱ្យបន្តការឃុំឃាំង ទណ្ឌិតឈ្មោះ កាំង ហ្គេកអ៊ាវ នៅក្នុងមន្ទីរឃុំឃាំងរបស់ អវតក តទៅទៀតរហូតដល់ពេល៖ (ក) ការចូលរួមរបស់គាត់នៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អវតក លែងមានការចាំបាច់តទៅទៀត ឬមួយក៏ការផ្ទេរបញ្ជូនរបៀបនេះ មិនមានចោទជាបញ្ហាដែលធ្វើឱ្យមានលំបាក ដល់ដំណើរ

---

[1] **F26/3** , សង្ខេបនៃសាលដីកាលើបណ្តឹងសាទុក្ខ, ៣ កុម្ភៈ ២០១២ ("សេចក្តីសង្ខេប")។

[2] **F26/3**, កំណត់សំគាល់ *ខាងដើម* លេខ១ ត្រង់ទំព័រ១៥។

[3] **F26/3**, *ដដែលដូចខាងលើ,* ត្រង់ទំព័រ១៨, ដាក់ភ្ជាប់ជាឧបសម្ព័ន្ធ ១។

ការនីតិវិធីរបស់ អវតក ដូចដែលសហព្រះរាជអាជ្ញា បានកំណត់, និង (ខ) សុំឱ្យ សហព្រះរាជអាជ្ញា និង អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ យល់ព្រមជាមួយគ្នាស្ដីពី ពន្ធនាគារដែលសមស្របសម្រាប់ការដាក់ឃុំខ្លួន កាំង ហ្កេកអ៊ាវ ដើម្បីអនុវត្តទោសរបស់គាត់ដែលនៅសល់ពីទោស ដែលបានកំណត់៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |



# ៩. សេចក្តីប្រកាស ព័ត៌មានអំពីមរណភាព របស់ ឌុច

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០

## សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាជាតិ
## អំពីមរណភាពរបស់ទណ្ឌិត កាំង ហ្គេកអ៊ាវ ហៅ ឌុច

សហព្រះរាជអាជ្ញាជាតិ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ទណ្ឌិត កាំង ហ្គេកអ៊ាវ ហៅ ឌុច បានទទួលមរណភាព នៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត វេលាម៉ោង ០០:៥១ នាថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ២០២០ នេះ។

ទណ្ឌិត កាំង ហ្គេកអ៊ាវ ហៅ ឌុច កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ សញ្ជាតិខ្មែរ មុខរបរគ្រូបង្រៀន ជាប្រធានមន្ទីរសន្តិសុខ ស-២១។ គាត់ត្រូវបានចាប់ និងឃុំខ្លួននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ហើយនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ត្រូវបានផ្ទេរមកឃុំខ្លួនក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងអំពើទារុណកម្ម និងមនុស្សឃាត ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការដើម្បីជំនុំជម្រះលើ កាំង ហ្គេកអ៊ាវ ហៅ ឌុច ហើយបានធ្វើសវនាការដេញដោលភស្តុតាង ស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចំណាយពេលវេលាអស់រយៈពេល ៧២ថ្ងៃ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ សាលក្រមត្រូវបានប្រកាស ដោយបានរកឃើញថា កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាអ្នកទទួលខុសត្រូវមន្ទីរសន្តិសុខ ស-២១ អស់រយៈពេលជាង ៣ ឆ្នាំ ដែលបណ្តាលឱ្យមានការសម្លាប់ជនរងគ្រោះជាង ១២២៧២ នាក់។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចផ្តន្ទា

ទោស កាំង ហ្កេកអ៊ាវ ហៅ ឌុច ដាក់ពន្ធនាគាររយៈពេល ៣៥ ឆ្នាំ ពីបទការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ និងសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ នៃបទបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។

សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនេះ ត្រូវបានសហព្រះរាជអាជ្ញា ដើមបណ្ដឹងរដ្ឋប្បវេណី និង កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូល បានចេញសាលដីកាសម្រេចផ្ដន្ទាទោស កាំង ហ្កេកអ៊ាវ ហៅ ឌុច ដាក់ពន្ធនាគារអស់មួយជីវិត។

កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានបញ្ជូនទៅពន្ធនាគារខេត្តកណ្ដាល នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១៣ ដើម្បីអនុវត្តទោស បន្ទាប់ពីការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល។

ថ្ងៃនេះ សហព្រះរាជអាជ្ញាជាតិ ជូនដំណឹងថា កាំង ហ្កេកអ៊ាវ ហៅ ឌុច បានទទួលមរណភាព ដោយផ្អែកតាមរបាយការណ៍របស់មន្ត្រីពាក់ព័ន្ធ ហើយចំពោះការស៊ើបអង្កេតពាក់ព័ន្ធនឹងមូលហេតុនៃមរណភាពរបស់ទណ្ឌិត កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាសមត្ថកិច្ចរបស់អាជ្ញាធរជាតិ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ
**លោក នេត្រ ភក្ត្រា**
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យសាលាក្ដីខ្មែរក្រហម
ទូរស័ព្ទចល័តៈ +៨៥៥ (០)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.phektra@eccc.gov.kh




សាលសវនាការ

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

អាសយដ្ឋាន៖ អគារលេខ៤០ មហាវិថីសហព័ន្ធរុស្ស៊ី
ខណ្ឌ ៧ មករា រាជធានីភ្នំពេញ P.O. Box ៧១, Postal Code ១២០៣០៦
ទូរស័ព្ទ៖ ០២៣ ៨៦១ ៥០០
ទូរសារ៖ ០២៣ ៨៦១ ៥៥៥
គេហទំព័រ៖ www.eccc.gov.kh

សម្រាប់ចែកចាយដោយឥតគិតថ្លៃ - ហាមលក់

9 789924 974789 >